ជាមួយនឹង
ព្យាការីនៃក្តីមេត្តា



ការបង្ហាញអោយ
ស្គាល់ព្យាការីមូហាំម៉ាត់

មាតិកា

<u>ចំណងជើង</u> **<u>ទំព័រ</u>**

សេចក្តីផ្តើម

សេចក្តីសរសើរទាំងឡាយសំរាប់អល់ឡោះជាម្ចាស់នៃសកលលោកទាំងមូល ទ្រង់បានបញ្ជូនពួកអ្នកនាំសារដ៏មហាថ្លៃថ្លា ដើម្បីមកបង្ហាញ និងបំភ្លឺផ្លូវត្រូវដល់មនុស្សលោក។

សូមពរជ័យសិរីសួស្តីកើតមានចំពោះព្យាការីមូហាំម៉ាត់ ដែលព្រះបញ្ជូនមកជាក្តីមេត្តាដល់សកលលោកទាំងមូល ហើយសូមជូនពរចំពោះក្រុមគ្រួសារគាត់ និងពួកសហាការីរបស់គាត់ដ៏ថ្លៃថ្លា។

ពិតប្រាកដ បានផុសឡើងនូវអ្នកបដិរូប(អ្នកកែប្រែសង្គម)ដ៏ឧត្តមម្នាក់ក្នុងប្រវត្តិសាស្ត្រ។ ក្នុងកំឡុងពេលដ៏ខ្លី គាត់អាចសាបព្រោះឥទ្ធិពលរបស់គាត់ក្នុងសង្គមរស់នៅរបស់មនុស្ស ហើយចម្លងពួកគេទៅកាន់ជីវិតមួយថ្មី... បុគ្គលដែលមានលក្ខណៈបែបនេះ គឺមូហាំម៉ាត់ កូន អាប់ឌុលឡោះ ជាអ្នកនាំសាររបស់ព្រះជាម្ចាស់នៃសកលលោក ហើយជាព្យាការីនៃក្តីមេត្តា។ គាត់បានទទួលចំណេះដឹង និងការត្រាស់បង្គាប់ពីអល់ឡោះជាម្ចាស់ ហើយព្រះអង្គបានប្រទានចំពោះគាត់នូវក្បួនច្បាប់ ដែលពេញលក្ខណៈ ល្អសុក្រឹត ជាមគ្គុទ្ទេសក៏ទៅកាន់ផ្លូវល្អ និងឧត្តមភាព។ និយាយពីបុគ្គលិកលក្ខណៈរបស់ព្យាការីវិញ គ្មានបុគ្គលិកលក្ខណៈណាអាចប្រៀបប្រដូចបានឡើយ ទោះនៅសម័យមុន ឬសម័យក្រោយ ហើយមានតែបុគ្គលិកលក្ខណៈគាត់តែមួយគត់ ដែលអល់ឡោះជាម្ចាស់ទ្រង់បានសរសើរ និងលើកតំកើង។ អល់ឡោះជាម្ចាស់បានបន្ទូលពណ៌នាពីភារកិច្ច និងចរិតលក្ខណៈនៃបេសកកម្ម ឬសាររបស់គាត់ថា:

﴿ وَمَآ أَرۡسَلۡنَٰكَ إِلَّا رَحۡمَةٗ لِّلۡعَٰلَمِينَ ١٠٧ ﴾ سورة الأنبياء / الآية: ١٠٧

មានន័យថា: (យើងគ្មានបញ្ជូនអ្នកឯងមក លើកលែងតែជាក្ដីមេត្តាករុណាដល់ពិភពលោកទាំងមូល)។

បើសិនជា អល់ឡោះជាម្ចាស់ទ្រង់លើកតំកើងមនុស្សម្នាក់ដែលទ្រង់បានបង្កើត និងសរសើរពីគុណសម្បត្តិដ៏ឧត្តមរបស់គេ គឺបានសេចក្ដីថា ព្យាការីមូហាំម៉ាត់ជាមនុស្សមានឋានៈខ្ពង់ខ្ពស់ចំពោះព្រះអង្គ។ ដូច្នេះ ចាំបាច់លើមនុស្សលោក ត្រូវមានជំនឿ និងប្រតិបត្តិតាមគាត់ ហើយសិក្សាពីមាគ៌ា និងជីវប្រវត្តិរបស់គាត់ ដើម្បីទទួលបាននូវក្ដីមេត្តាករុណាពីព្រះជាម្ចាស់ ជាប្រយោជន៍ដើម្បីរៀបចំ និងតំរង់ទិសជីវិតរបស់ពួកគេ។

សៀវភៅមួយច្បាប់នេះ ចងក្រងឡើងដើម្បីបកស្រាយចំណុចគោលសំខាន់ៗ ដែលនាំអោយស្គាល់ពីបុគ្គលិកលក្ខណៈរបស់ព្យាការីមូហាំម៉ាត់ កូន អាប់ឌុលឡោះ ស្គាល់ពីការអំពាវនាវ និងស្គាល់ពីចរិតលក្ខណៈនៃលទ្ធិរបស់គាត់ដែលព្រះជាម្ចាស់បានបញ្ជូនមក និងស្គាល់ពីវិធីសាស្ត្រក្នុងការដោះស្រាយបាតុភូត ហេតុការណ៍ទាំងឡាយដែលកើតឡើងនៅចំពោះមុខ។ម្យ៉ាងវិញទៀត ជាការទ្រទ្រង់ចំពោះអ្នកដែលប្រាថ្នា និងស្វែងរកសេចក្ដីល្អដើម្បីកសាងភពផែនដីអោយក្លាយជាភពមួយប្រកបដោយសេចក្ដីសុខ សុភមង្គលដែលជាសេចក្ដីប្រាថ្នារបស់មនុស្សទូទៅ។

***

ពង្សាវតាររបស់ព្យាការីមូហាំម៉ាត់

គាត់មានឈ្មោះ អាពុលកសិម មូហាំម៉ាត់ កូន អាប់ឌុលឡោះ កូនអាប់ឌុលមូតាឡិប ពូជពង្សរបស់គាត់ជាប់ត្រកូលអ័ដណាន ជាកូនរបស់ព្យាការីអ៊ិស្មាឯល កូនព្យាការីអ៊ីព្រហីម។ ម្ដាយគាត់ឈ្មោះ អាមីណះ កូន វ៉ាហាប់ ក៏មានពូជពង្សជាប់ត្រកូលអ័ដណាន ជាកូនរបស់ព្យាការីអ៊ិស្មាឯល កូនរបស់ព្យាការីអ៊ីព្រហីម។ ព្យាការីមូហាំម៉ាត់បានប្រសាសន៍តំកើងពីពូជពង្សដ៏ឧត្ដមរបស់គាត់ថា:

عَنْ أَبِي عَمَّارٍ شَدَّادٍ أَنَّهُ سَمِعَ وَاثِلَةَ بْنَ الْأَسْقَعِ يَقُولُ سَمِعْتُ رَسُولَ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ يَقُولُ : (إِنَّ اللَّهَ اصْطَفَى كِنَانَةَ مِنْ وَلَدِ إِسْمَعِيلَ وَاصْطَفَى قُرَيْشًا مِنْ كِنَانَةَ وَاصْطَفَى مِنْ قُرَيْشٍ بَنِي هَاشِمٍ وَاصْطَفَانِي مِنْ بَنِي هَاشِمٍ) صحيح مسلم

មានន័យថា: (ពិតប្រាកដ អល់ឡោះជាម្ចាស់បានជ្រើសកីណាណះពីកូនចៅអ៊ិស្មាឯល ទ្រង់បានជ្រើសគូរេស្សពីកីណាណះ និងបានជ្រើសពីកុលសម្ព័ន្ធគូរេស្ស កូនចៅហាសិម ហើយទ្រង់បានជ្រើសរើសខ្ញុំពីកូនចៅហាសិម)។ តាមរយៈពង្សាវតារនេះ គាត់ជាមនុស្សដែលមានពូជពង្សខ្ពស់ប្រសើរលើសគេទូទាំងសកលលោក ។

***

កំណើតព្យាការីមូហាំម៉ាត់

គាត់បានកើតនៅឆ្នាំ ៥៧១គ.ស ក្នុងកុលសម្ព័ន្ធគូរេស្ស ជាកុលសម្ព័ន្ធមួយដែលពួកអារ៉ាប់នាំគ្នាគោរព និងលើកតំកើងយ៉ាងខ្លាំងនាសម័យនោះ។ គាត់កើតនៅនគរម៉ឹក្កះដែលគេចាត់ទុកជាមជ្ឈមណ្ឌលសាសនាសំរាប់ឧបទ្វីបអារ៉ាប់ទាំងមូល ក្នុងនោះមាន វិហារកៈហ្បះដ៏ឧត្តុង្គឧត្តមដែលបានកសាងឡើងដោយបិតានៃពួកព្យាការី គឺព្យាការីអ៊ីព្រហីម និងកូនរបស់គាត់ឈ្មោះអ៊ិស្មាឯល សូមសន្តិភាពកើតមានដល់លោកទាំងពីរ។ នៅទីនោះ ដែលជនជាតិអារ៉ាប់នាំគ្នាធ្វើធម្មយាត្រា និងប្រារព្ធបុណ្យហាជ្ជ។ ឪពុករបស់គាត់បានស្លាប់តាំងពីគាត់នៅក្នុងពោះម្តាយ ហើយក្រោយពេលកើត ម្តាយក៏បានស្លាប់ចោលទៀត។ ដូច្នេះ គាត់រស់ក្នុងនាមជាកូនកំព្រា ក្រោមការចិញ្ចឹមបីបាច់របស់ជីតាគាត់ឈ្មោះអាប់ឌុលមូតាឡិប។ លុះក្រោយមក ជីតារបស់គាត់បានស្លាប់ចោល ហើយឪពុកមារបស់គាត់ឈ្មោះ អាពូតាឡិប ជាអ្នកចិញ្ចឹមបីបាច់បន្ត។ កាលពីកុមារភាពមានហេតុការណ៍ចាប់ពុះទ្រូងកើតឡើងចំពោះគាត់ ខណៈដែល គាត់នៅជាមួយមេដោះ ក្នុងកុលសម្ព័ន្ធហ្ពានីសាអ័ដ។ ហេតុការណ៍នេះ ជាសញ្ញាមួយនៃសញ្ញាជាច្រើន ដែលបញ្ជាក់ពីការជ្រើសរើសរបស់អល់ឡោះជាម្ចាស់ អោយគាត់ទទួលភារកិច្ចសំខាន់។ ពិតប្រាកដ ក្នុងសៀវភៅសហេះ អ៊ីមុាំមូស្លីមបាននិទានពីព្រឹត្តិការណ៍ពុះទ្រូងនេះថា:

عَنْ أَنَسِ بْنِ مَالِكٍ : (أَنَّ رَسُولَ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ أَتَاهُ جِبْرِيلُ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ وَهُوَ يَلْعَبُ مَعَ الْغِلْمَانِ فَأَخَذَهُ فَصَرَعَهُ فَشَقَّ عَنْ قَلْبِهِ فَاسْتَخْرَجَ الْقَلْبَ فَاسْتَخْرَجَ مِنْهُ عَلَقَةً فَقَالَ هَذَا

حَظُّ الشَّيْطَانِ مِنْكَ ثُمَّ غَسَلَهُ فِي طَسْتٍ مِنْ ذَهَبٍ بِمَاءِ زَمْزَمَ ثُمَّ لَأَمَهُ ثُمَّ أَعَادَهُ فِي مَكَانِهِ وَجَاءَ الْغِلْمَانُ يَسْعَوْنَ إِلَى أُمِّهِ يَعْنِي ظِئْرَهُ فَقَالُوا إِنَّ مُحَمَّدًا قَدْ قُتِلَ فَاسْتَقْبَلُوهُ وَهُوَ مُنْتَقِعُ اللَّوْنِ قَالَ أَنَسٌ وَقَدْ كُنْتُ أَرَى أَثَرَ ذَلِكَ الْمِخْيَطِ فِي صَدْرِهِ) . صحيح مسلم.

មានន័យថា: (ពិតប្រាកដ ព្យាការីមូហាំម៉ាត់ត្រូវទេវតាជីព្រីលចាប់ផ្តួលលើដី ខណ:ដែលគាត់កំពុងរត់លេងជាមួយក្មេងៗដទៃទៀត រួចក៏បានពុះទ្រូងយកបេះដូងចេញក្រៅ បានខ្វេះឈាមកកមួយដុំចេញរួចនិយាយថា: នេះជាចំណែកបិសាចស្បៃតនក្នុងខ្លួនឯង។ បន្ទាប់មកបានយកគាត់លាងក្នុងចានដែកមាស នឹងទឹកហ្សាំហ្សាំ(زَمْزَم)រួចផ្គុំចូលឡើងវិញ ហើយដេរភ្ជិតដូចដើម។ កាលនោះ ពួកក្មេងៗរត់ឆ្លេឆ្លាមករកមេដោះ យំផងស្រែកផងថា គេបានសំលាប់មូហាំម៉ាត់។ ពួកគេនាំគ្នាទៅទទួលគាត់ ក៏ស្រាប់តែឃើញគាត់ស្លេកស្លាំង។ អាណាសបាននិយាយថា ពិតប្រាកដ ខ្ញុំធ្លាប់ឃើញស្នាមថ្នេរដេរលើទ្រូងគាត់)។

មួយជីវិតរបស់ព្យាការីមូហាំម៉ាត់ពោរពេញដោយសច្ចភាព និងទៀងត្រង់។ គេមិនដែលសំគាល់ថា គាត់ក្បត់កិច្ចសន្យា បោកប្រាស់ក្បត់នឹងសេចក្តីទុកចិត្ត និងមានល្បិចកលឡើយ។ មនុស្សទូទៅស្គាល់ថា គាត់ជាមនុស្សទៀងត្រង់(الأَمِيْن)ពួកគេតែងយករបស់ទ្រព្យមកផ្ញើជាមួយគាត់ នៅពេលពួកគេត្រូវចេញដំណើរឆ្ងាយ។ គេហៅគាត់ថា ជាមនុស្សប្រកាន់ពាក្យសច្ច:(الصَّادِق) ព្រោះ គេស្គាល់តាមរយ:ពាក្យសំដីដ៏ស្មោះត្រង់របស់គាត់ និយាយយ៉ាងម៉េចធ្វើអញ្ចឹង។ គាត់មានអត្តចរិតប្រពៃ សំដីពីរោះ ប្រសប់និយាយ គាត់ពេញចិត្តចង់ឱ្យតែមនុស្សទទួលបាននូវភាពចំរុងចំរើន ដូច្នេះ ពួកគេក៏ស្រលាញ់គាត់។ អ្នកផងទាំងពួង ទោះជិត ទោះឆ្ងាយ តែងលើកតំកើងគាត់។ គាត់មាន

រូបរាងសង្ហា គេមិនដែលជិនណាយនឹងគន់មើលសំរស់របស់គាត់។ គាត់ល្អស្អាតទាំងរូបសម្បត្តិ និងចរិយាសម្បត្តិ គ្មានទាស់ត្រង់ណាឡើយ។ ដូចអល់ឡោះជាម្ចាស់ទ្រង់បានបន្ទូលសរសើរគាត់ថា:

﴿ وَإِنَّكَ لَعَلَىٰ خُلُقٍ عَظِيمٍ ﴿٤﴾ ﴾ سورة القلم / الآية : ٤

មានន័យថា: (មូហាំម៉ាត់! ពិតប្រាកដ ឯងកំពុងឋិតលើចរិយាសម្បត្តិដ៏ប្រពៃឧត្តុង្គឧត្តមជាទីបំផុត)។

នៅសម័យនោះ កុលសម្ព័ន្ធរបស់ព្យាការីមូហាំម៉ាត់ ព្រមទាំងពួកកុលសម្ព័នផ្សេងទៀតដែលនៅជុំវិញ នាំគ្នាគោរពបូជារូបបដិមាដែលផលិតពីឈើ ដុំថ្ម មាស រួចយកទៅដាក់តាំងនៅជុំវិញវិហារក:ហ្ពះ។ ពួកគេមានជំនឿថា រូបបដិមាទាំងនោះមានអានុភាពសក្តិសិទ្ធិក្នុងការផ្តល់ផលប្រយោជន៍ ឬបង្កគ្រោះថ្នាក់។ រីឯព្យាការីមូហាំម៉ាត់វិញ គាត់ស្អាតស្អំពីអ្វីដែលសាសន៍របស់គាត់កំពុងតែប្រព្រឹត្តនូវអំពើពាលាទាំងនោះ។ គាត់ពុំដែលសេពគ្រឿងស្រវឹង ពុំដែលក្រាបបង្គំចំពោះរូបបដិមា ឬស្បថស្បែ ឬបន់ស្រន់ ជូនតង្វាយ ដូចដែលសាសន៍របស់គាត់នៅធ្វើនោះឡើយ។ គាត់ធ្លាប់ឃ្វាលពពែអោយគេ គាត់បានមានប្រសាសន៍ថា:

عَنْ أَبِي هُرَيْرَةَ رَضِيَ اللَّهُ عَنْهُ عَنْ النَّبِيِّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ: (مَا بَعَثَ اللَّهُ نَبِيًّا إِلَّا رَعَى الْغَنَمَ) ، فَقَالَ : أَصْحَابُهُ وَأَنْتَ فَقَالَ : (نَعَمْ كُنْتُ أَرْعَاهَا عَلَى قَرَارِيطَ لِأَهْلِ مَكَّةَ) صحيح البخاري

មានន័យថា: (អល់ឡោះជាម្ចាស់ទ្រង់គ្មានតែងតាំងព្យាការីណាម្នាក់លើកលែងតែព្យាការីនោះ ធ្លាប់ឃ្វាលពពែអោយគេ។ ពួកសហការី

របស់គាត់លាន់មាត់ថា ទាំងលោកដែរមែនទេ? គាត់ថា ពិតណាស់ ខ្ញុំធ្លាប់ស៊ីឈ្នួលអ្នកមឹក្កះឃ្វាលពពែ)។

***

ចាប់ផ្តើមទទួលព្រះបន្ទូល និងតែងតាំងជាអ្នកនាំសារ

មុននឹងទទួលការតែងតាំង គាត់ចូលចិត្តនៅម្នាក់ឯង គាត់ទៅធ្វើសក្ការៈយូរ រាប់យប់នៅក្នុងរូងភ្នំ (غارُ حِراء)។ លុះគាត់មានអាយុគំរប់សែសិបឆ្នាំ ព្រះបន្ទូលត្រូវបានប្រទានចុះពីលើមេឃមកអោយគាត់ខណៈដែលគាត់កំពុងធ្វើសក្ការៈក្នុងរូងភ្នំនៅទឹកដីមឹក្កះដូចសព្វដង។ អាអ៊ីសះ មាតានៃពួកអ្នកមានជំនឿ ភរិយារបស់គាត់បាននិយាយថាៈ (ព្រះបន្ទូលដំបូង ដែលផ្តើមជាមួយព្យាការីមូហាំម៉ាត់ គឺសុបិនល្អ សុបិននោះ និម្មិតឃើញច្បាស់ដូចជាពន្លឺអារុណរះ។ បន្ទាប់មក គាត់ចូលចិត្តនៅតែឯង គាត់ទៅនៅរូងភ្នំ ធ្វើសក្ការៈទីនោះមានកំណត់ចំនួនច្រើនយប់ មុននឹងវិលមកផ្ទះវិញ។ ក្រោយមក គាត់បានវេចបង្វេចទៅសក្ការៈម្តងទៀត រួចហើយត្រលប់មកផ្ទះវិញ ហើយវេចបង្វេចទៅម្តងទៀត ធ្វើបែបនេះ រហូតការពិតបានស្តែងឡើងចំពោះគាត់នៅក្នុងរូងភ្នំ។ ទេវតាជីព្រីលបានមកដល់ រួចនិយាយថា ចូរសូត្រចុះ គាត់តបវិញថា ខ្ញុំឥតចេះសូត្រទេ។ គាត់បានប្រសាសន៍បន្តថាៈ ទេវតាបានចាប់ខ្ញុំអោបរឹតរហូតដល់ខ្ញុំថប់ដង្ហើម ទើបលែងខ្ញុំវិញ រួចនិយាយថាៈ ចូរឯងសូត្រចុះ! ខ្ញុំតបវិញថា ខ្ញុំឥតចេះសូត្រទេ។ ចាប់ខ្ញុំ

អោបរឹតលើកទីពីរ រហូតដល់ខ្ញុំថប់ដង្ហើម ទើបលែងខ្ញុំវិញ ហើយនិយាយថាៈ ចូរសូត្រចុះ! ខ្ញុំនិយាយថាៈ ខ្ញុំឥតចេះសូត្រទេ។ ចាប់ខ្ញុំអោបរឹតលើកទីបី រួចលែងខ្ញុំវិញ ហើយក៏សូត្រថាៈ

﴿ ٱقۡرَأۡ بِٱسۡمِ رَبِّكَ ٱلَّذِي خَلَقَ ١ خَلَقَ ٱلۡإِنسَٰنَ مِنۡ عَلَقٍ ٢ ٱقۡرَأۡ وَرَبُّكَ ٱلۡأَكۡرَمُ ٣ ﴾ سورة العلق/الآية:١-٣

មានន័យថាៈ (នៃមូហាំម៉ាត់! ចូរឯងសូត្រគម្ពីរអាល់គួរអាន ដែលបានប្រទានចុះមក ផ្តើមដោយព្រះនាមរបស់ព្រះជាម្ចាស់ដែលបានបង្កើតសត្វលោកដោយឯកអង្គ ទ្រង់បង្កើតមនុស្សពីឈាមមួយដុំ។ ចូរសូត្រចុះនូវព្រះបន្ទូលដែលបានប្រទានចុះមក ព្រោះទ្រង់មហាករុណា មហាសណ្តោសប្រណី)។ បន្ទាប់ពីនោះ ព្យាការីមូហាំម៉ាត់បានត្រលប់មកផ្ទះវិញ ទាំងខ្លួនភ័យ ញ័រតត្រាក់ គាត់បានរត់ទៅរកខទីហ្ជះប្រពន្ធរបស់គាត់ ហើយប្រាប់ប្រពន្ធថាៈ (ដណ្តប់ខ្ញុំផង! ដណ្តប់ខ្ញុំផង!) ។ គេបានដណ្តប់ជួយគាត់រហូតបាត់ភ័យ គាត់បានរៀបរាប់ប្រាប់ខទីហ្ជះ ហើយនិយាយថាៈ (ខ្ញុំមានការព្រួយបារម្ភចំពោះខ្លួនឯងណាស់!)។ ខទីហ្ជះបានតបវិញថាៈ មិនអីទេ! កុំភ័យ សូមស្បថចំពោះអល់ឡោះ ទ្រង់នឹងមិនធ្វើអោយអ្នកអាប់អោនជាដាច់ខាត ព្រោះអ្នកតែងរាប់អានញាតិសណ្តាន តែងជួយសង្គ្រោះអ្នកទន់ខ្សោយ តែងជួយទំនុកបំរុងអ្នកទីទ័លក្រ តែងទទួលភ្ញៀវ ហើយតែងជួយសង្គ្រោះអ្នកមានវិបត្តិ ។ ខទីហ្ជះបាននាំគាត់ទៅជួបវ៉ារ៉កោះ ពិននូហ្វាល់ (**وَرَقَة بن نوفل**) ជាបងជីដូនមួយរបស់ខទីហ្ជះ។ បុរសនេះ បានចូលសាសនាគ្រិស្តនៅសម័យបុព្វកាលអវិជ្ជា (**الجاهِلِيَّة**) គាត់ជាអ្នកនិពន្ធសៀវភៅជាភាសាហេព្រឺ គាត់សរសេរគម្ពីរសញ្ញាណថ្មី (**الإنْجيل**)

ជាភាសាហេព្រឺ គាត់ជាចាស់ជរា ហើយពិការភ្នែក។ ខទីហ្វះបាន និយាយថា: នៃលោក! ចាំស្តាប់ប្អូនជីដូនមួយនិយាយប្រាប់។ វ៉ារ៉ាកោះ បានសួរថា: តើឯងបានឃើញអ្វី? ពេលនោះ ព្យាការីមូហាំម៉ាត់ ក៏បាន រៀបរាប់ប្រាប់គាត់តាមដំណើរហេតុការណ៍ដែលគាត់ប្រទះក្នុងរូងភ្នំ។ ស្តាប់ហើយ វ៉ារ៉ាកោះបាននិយាយថា: នោះជាទេវតាដែលអល់ឡោះ ទ្រង់ធ្លាប់បានបញ្ជូនមកកាន់ព្យាការីមូសា។ គួរអោយស្តាយណាស់! បើខ្ញុំនៅរឹងមាំដូចមុន គួរអោយស្តាយណាស់ បើខ្ញុំនៅមានជីវិត ខណៈ ដែលសាសន៍របស់ឯង បំបរបង់ឯង។ ព្យាការីបានសួរថា: (តើពួកគេ បំបរបង់ខ្ញុំចោលឬ? គាត់ឆ្លើយថា ពិតមែន គ្មានបុរសណាម្នាក់បាន នាំមកនូវអ្វីដែលឯងបាននាំមក លើកលែងតែត្រូវគេរារាំង។ បើខ្ញុំទាន់ សម័យឯង ខ្ញុំនឹងជួយគាំទ្រឯងយ៉ាងពេញទំហឹង។ មិនយូរប៉ុន្មាន វ៉ារ៉ាកោះបានស្លាប់ ហើយរឿងព្រះបន្ទូលនោះក៏បានស្ងប់ស្ងាត់)។ ព្រះ បន្ទូលខាងលើជាការចាប់ផ្តើម ជាសញ្ញាសំគាល់នៃការតែងតាំងជា អ្នកនាំសារ។

***

ការអំពាវនាវលើកដំបូង

លុះក្រោយមក ព្រះជាម្ចាស់បានត្រាស់បង្គាប់ព្យាការីមូហាំម៉ាត់ថា: ﴿ يَٰٓأَيُّهَا ٱلۡمُدَّثِّرُ ١ قُمۡ فَأَنذِرۡ ٢ وَرَبَّكَ فَكَبِّرۡ ٣ وَثِيَابَكَ فَطَهِّرۡ ٤ وَٱلرُّجۡزَ فَٱهۡجُرۡ ٥ ﴾

سورة المدثر / الآية: ١-٥

មានន័យថា: (ឱអ្នកដែលកំពុងដេកដណ្ដប់ភួយ! ចូរក្រោកពីដំណេក រួចទៅដាស់តឿនមនុស្សឱ្យប្រុងប្រយ័ត្នពីទារុណកម្មរបស់អល់ឡោះ។ ចូរឧទ្ទិសការលើកតំកើង និងការគោរព ថ្វាយចំពោះអល់ឡោះតែមួយគត់។ ចូរជំរះសំលៀកបំពាក់ឯងពីភាពកខ្វក់ ពីព្រោះភាពស្អាតស្អំខាងក្រៅជាកត្តាបំពេញនូវភាពស្អាតស្អំខាងក្នុង។ ចូរបោះបង់ការបូជារូបសំណាក និងរាល់ទង្វើពហុទេពនិយមទាំងឡាយ)។

នេះជាជំពូកដំបូង ជាសារមួយដែលព្រះជាម្ចាស់ត្រាស់បង្គាប់ឱ្យព្យាការីមូហាំម៉ាត់ ចាប់ផ្ដើមអំពាវនាវសាសន៍របស់គាត់នៅមឹក្កះ។ គាត់បានទទួលរងការបៀតបៀន ព្យាបាទ ពីសំណាក់ពួកគេ ដែលជំទាស់នឹងការអំពាវនាវរបស់គាត់។ ដោយសារ គាត់បាននាំមកនូវការអំពាវនាវដ៏ចម្លែកសំរាប់ពួកគេ ការអំពាវនាវនេះគ្របដណ្ដប់លើសង្គមរស់នៅរបស់ពួកគេទាំងមូល ទាំងវិស័យសាសនា នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច។ ការអំពាវនាវរបស់គាត់ ពុំត្រឹមតែហៅមនុស្សឱ្យគោរពសក្ការៈចំពោះអល់ឡោះ ហើយបោះបង់ការគោរពបូជារូបបដិមាប៉ុណ្ណោះទេ ថែមទាំងហាមប្រាមនូវអ្វីដែលជាប្រភពនៃសេចក្ដីសុខ និងជាមោទនភាពរបស់ពួកគេ គាត់ហាមចងការប្រាក់ ហាមល្បែង ស្រា ស្រី។ល។ លើសពីនេះ គាត់បានអំពាវនាវឱ្យប្រកាន់

ភាពសច្ចៈ និងយុត្តិធម៌ចំពោះមនុស្សទូទៅ មិនប្រកាន់ស្រទាប់វណ្ណៈ បែងចែកពណ៌សម្បុរ ហើយអ្នកដែលប្រសើរជាងគេគឺអ្នកដែលគោរព បាននូវវិន័យសាសនា។ នេះជាបញ្ហា ដែលសាសន៍របស់គាត់ ជាពិសេសពួកមេដឹកនាំ មានការខឹងសម្បារ កើតទុក្ខមិនសុខចិត្ត ពុំព្រមទទួលយកនូវសមភាពរវាងវណ្ណៈពួកខ្លួននិងវណ្ណៈតូចទាបដទៃទៀត។

ជំហាររបស់ពួកគេ មិនត្រឹមតែបដិសេធចំពោះការអំពាវនាវរបស់ព្យាការីមូហាំម៉ាត់ប៉ុណ្ណោះទេ តែពួកគេថែមទាំងបានព្យាបាទជេរប្រមាថ ចោទប្រកាន់អាក្រក់ៗ មួលបង្កាច់ដាក់គាត់ថា គាត់ជាមនុស្សបោកប្រាស់ ជាមនុស្សឆ្កួត ជាគ្រូមន្តអាគម និងពាក្យចោទប្រកាន់ផ្សេងៗទៀត ដែលពួកគេពុំទាន់បានចោទ មុននឹងគាត់ប្រកាសការអំពាវនាវដោយបើកចំហ។ លើសពីនេះ ពួកគេហ៊ានប្រើហិង្សាប៉ះពាល់ដល់រូបរាងកាយរបស់គាត់។ អាប់ឌុលឡោះ ពិន ម៉ាសស៊្អូតបានអោយដឹងថាៈ (ខណៈដែលព្យាការីមូហាំម៉ាត់គាត់កំពុងឈរថ្វាយបង្គំនៅឯកៈហ្បះ ហើយពួកគូរេស្សកំពុងជួបជុំគ្នា ពេលនោះមានម្នាក់និយាយថាៈ មើលនោះ តើឃើញអ្នកចង់បានមុខមាត់ទេ? តើមាននរណាទៅកន្លែងកុងស៊ីកាប់អូដ្ឋ ឬពពែ ហើយកើបយកទាំងអាចម៍ លាមក ឈាម ចាំមើលគេភ្លេចខ្លួន គេក្រាបដល់ដី ចាំយកទៅចាក់លើខ្លួនរបស់គេ? មានម្នាក់ដែលសាហាវជាងគេ សុខចិត្តធ្វើ។ ពេលគាត់កំពុងតែក្រាបថ្វាយបង្គំ ម្នាក់នោះបានយកទៅចាក់លើខ្លួនរបស់គាត់។ ទោះជាយ៉ាងនេះក្តី គាត់នៅតែក្រាបថ្វាយបង្គំយ៉ាងស្ងាបាប់។ ឃើញបែបនេះ ពួកគេនាំគ្នាសើចចំអកក្អាកក្អាយ។ ពេល

នោះ មានគេទៅប្រាប់ហ្វាតីម៉ះកូនស្រីរបស់គាត់ ហើយកាលនោះ ហ្វាតីម៉ះនៅតូចនៅឡើយ ហ្វាតីម៉ះបានរត់ទៅរកឪពុក ទៅដល់ឃើញ ឪពុកកំពុងតែក្រាបថ្វាយបង្គំ ហើយហ្វាតីម៉ះក៏បានយកលាមកនោះ ចេញ រួចរត់ទៅស្ដីបន្ទោសអោយពួកគេ)។

លោកមូណីប អាល់អាហ្សទីយ៏ បាននិយាយថា: ខ្ញុំបានឃើញ ព្យាការីមូហាំម៉ាត់នៅសម័យបុព្វកាលអវិជ្ជា គាត់កំពុងហៅអំពាវនាវ មនុស្សថា: (នៃមនុស្សទាំងឡាយ! ចូរពោលចុះថា គ្មានព្រះដែលត្រូវ គេគោរពសក្ការៈយ៉ាងពិតប្រាកដ លើកលែងតែអល់ឡោះ នោះពួក អ្នកនឹងបានជោគជ័យ)។ អ្នកខ្លះបានស្ដោះទឹកមាត់ដាក់មុខគាត់ ខ្លះ ទៀតបាចធុលីដាក់គាត់ អ្នកខ្លះជេរប្រមាថគាត់ រហូតដល់ថ្ងៃត្រង់។ កូនស្រីគាត់ បានយកទឹកមួយផ្ដិលធំទៅឱ្យគាត់លាងមុខ និងដៃ។ គាត់និយាយថា: (នៃកូនស្រី កុំបាច់បារម្ភខ្លាចឪពុកអាប់អោន ឬអាម៉ាស់មុខអី!)។

អួរវ៉ះ ពិន អាហ្ស៊ូប៉ៀរបាននិយាយថា: ខ្ញុំបានសុំអោយអាប់ ឌុលឡោះ ពិន អាំរូ ពិន អាលអើស្វ និយាយប្រាប់ខ្ញុំពីទង្វើដ៏អាក្រក់ បំផុតដែលពួកគូរេស្សបានធ្វើចំពោះព្យាការីមូហាំម៉ាត់ គាត់បានប្រាប់ ថា: (អុកហ្ពះ ពិន អាពី មូអែតបានសំដៅទៅរកព្យាការីមូហាំម៉ាត់ ខណៈដែលគាត់កំពុងថ្វាយបង្គំនៅកៈហ្ពះ គេបានយកអាវរឹតកគាត់ យ៉ាងតឹង។ ឃើញដូច្នេះ អាពូហ្ពាកើរបានចាប់ស្មាគេ រុញបំបែកពី ព្យាការីមូហាំម៉ាត់ ហើយស្ដីអោយថា តើឯងដាច់ចិត្តសម្លាប់បុរស

ដែលនិយាយថា អល់ឡោះជាម្ចាស់របស់ខ្ញុំ ហើយគាត់ពិតជាបាននាំមកបង្ហាញជូនពួកអ្នកនូវភស្តុតាងពីអល់ឡោះជាម្ចាស់?)។

ជាមួយនឹងការចងកំហឹងដ៏បើកចំហ ពួកគេនៅខំព្យាយាមរាំងខ្ទប់ការអំពាវនាវរបស់គាត់ ដោយធ្វើការចរចាឱ្យបញ្ឈប់សកម្មភាពនេះ ប្តូរយកផលប្រយោជន៍ កិត្តិយស និងបុណ្យសក្តិ ដែលពួកគេជឿជាក់ថា អាចមានឥទ្ធិពល ទិញទឹកចិត្តរបស់ព្យាការីមូហាំម៉ាត់ ហើយអាចប្តូរឥរិយាបថ និងបញ្ឈប់សកម្មភាពអំពាវនាវ។ ពួកគេបានស្នើអោយគាត់ធ្វើជាស្តេចគ្រប់គ្រងពួកគេ ឬប្រគល់ទ្រព្យសម្បត្តិឱ្យក្លាយជាអភិជនស្តុកស្តម្ភជាងគេ ឬនឹងរើសកូនក្រមុំស្អាតជាងគេរៀបការឱ្យគាត់ តែគាត់បែរជាបដិសេធនឹងសំណើទាំងនោះ។ បន្ទាប់មកពួកគេនិយាយថា: (យើងគោរពសក្ការៈព្រះរបស់ឯងមួយថ្ងៃ ហើយឯងគោរពព្រះយើងមួយថ្ងៃវិញ)។ គាត់ក៏បដិសេធនឹងសំណើនេះផងដែរ។ ពួកគេនៅតែ ព្យាយាមស្នើម្តងហើយម្តងទៀត ចង់ប្រគល់បុណ្យសក្តិ មាសប្រាក់ឱ្យគាត់ ហើយស្នើទៀតថា បើគាត់មានជំងឺដោយសារខ្មោចអារក្សចូល ពួកគេអាចជួយព្យាបាលអោយជា។ ព្យាការីមូហាំម៉ាត់បានឆ្លើយតបទៅពួកគេវិញថា: (ខ្ញុំពុំត្រូវការរបស់ទាំងនោះឡើយ! ខ្ញុំមកនេះ ពុំមែនមកសុំមាសប្រាក់ បុណ្យសក្តិ កិត្តិយស ឬចង់ក្លាយជាស្តេចគ្រប់គ្រងពួកអ្នកនោះទេ។ ក៏ប៉ុន្តែ អល់ឡោះជាម្ចាស់បានតែងតាំងខ្ញុំជាអ្នកនាំសារ ទ្រង់បានប្រទានគម្ពីរឱ្យមកខ្ញុំ ហើយត្រាស់បង្គាប់ខ្ញុំឱ្យក្លាយជាបុគ្គលដែលនាំដំណឹងល្អមកផ្សព្វផ្សាយ និងដាស់តឿនមនុស្សលោកអោយប្រុងប្រយ័ត្នពីទារុណកម្មរបស់ទ្រង់។

ដូច្នេះ ខ្ញុំមានតួនាទីនាំសារនេះ មកបង្រៀន និងណែនាំបង្ហាញផ្លូវដល់ពួកអ្នក បើពួកអ្នកព្រមទទួលនូវអ្វីដែលខ្ញុំបាននាំមកនោះ ពួកអ្នកនឹងមានសំណាងល្អទាំងនៅលោកីយ៍ និងបរលោក បើពួកអ្នកបដិសេធចំពោះខ្ញុំនោះ ខ្ញុំនឹងអត់ធ្មត់លើការអំពាវនាវនេះរហូតដល់អល់ឡោះទ្រង់សំរេចសេចក្តីរវាងខ្ញុំ និងពួកអ្នកទាំងអស់គ្នា)។

ក្រោយពីបរាជ័យនូវគ្រប់មធ្យោបាយដែលពួកគេបានព្យាយាម ពួកគេមានគំនិតថ្មីមួយទៀត គឺសំលាប់គាត់ចោលតែម្តង ដើម្បីកុំអោយស្មុគស្មាញ។ ពួកគេបានស្នើសុំពីកុលសម្ព័ន្ធរបស់គាត់ ប្រគល់គាត់ឱ្យពួកគេដើម្បីយកទៅប្រហារជីវិត ក៏ប៉ុន្តែត្រូវកុលសម្ព័ន្ធរបស់គាត់បដិសេធនឹងសំណើនេះ។ បន្ទាប់មក ពួកគេបានសំរេចឯកភាពគ្នាដាក់ទណ្ឌកម្ម ហ៊ុំព័ទ្ធសេដ្ឋកិច្ច ផ្តាច់ការទំនាក់ទំនងជាមួយគាត់ជាមួយពួកអ្នកឥស្លាម ព្រមទាំងក្រុមអ្នកគាំទ្រគាត់នៃមនុស្សក្នុងកុលសម្ព័ន្ធ។ ពួកគេបានចុះកិច្ចព្រមព្រៀងមួយដែលចែងថា មិនផ្សារភ្ជាប់សាច់ឈាមជាមួយពួកគេ មិនធ្វើការលក់ដូរជាមួយពួកគេ កាត់ផ្តាច់ទាំងស្រុងនូវស្បៀងទាំងឡាយដែលអាចទៅដល់ពួកគេ មិនចរចាជាមួយពួកគេ ត្រូវប្រើហិង្សាក្នុងការប្រាស្រ័យទាក់ទងជាមួយពួកគេរហូតទាល់តែ កុលសម្ព័ន្ធរបស់គាត់ព្រមប្រគល់ខ្លួនគាត់ ដើម្បីប្រហារជីវិត។ ការដាក់ទណ្ឌកម្មត្រូវបានអនុវត្តចំពោះព្យាការីមូហាំម៉ាត់ ព្រមទាំងពួកអ្នកនៅជាមួយគាត់អស់រយៈកាលបីឆ្នាំ ដែលធ្វើឱ្យពួកគេរងនូវវិបត្តិយ៉ាងធ្ងន់ធ្ងរ។ ដោយគាត់បានឃើញនូវទុក្ខវេទនារបស់ពួកសហការី ហើយខ្លួនគាត់គ្មានលទ្ធភាពនឹងសង្គ្រោះ បញ្ចៀសពួកគេពី

វិបត្តិនេះ គាត់ក៏បានប្រសាសន៍ថាៈ (ពួកអ្នកគួរភៀសខ្លួនទៅប្រទេស ហាប់ស្សះ(អេធ្យូពី) ព្រោះស្តេចប្រទេសនោះ មិនប្រើអំណាចជិះជាន់នរណាម្នាក់ឡើយ ហើយជាទឹកដីដែលប្រកបដោយសច្ចភាព សង្ឃឹមថា នៅទីនោះ ព្រះជាម្ចាស់នឹងប្រទានដំណោះស្រាយដល់ពួកអ្នកឱ្យរួចផុតពីវិបត្តិនេះ)។ ខណៈនោះ ពួកអ្នកឥស្លាមក៏បាននាំគ្នាភៀសខ្លួនទៅទឹកដីហាប់ស្សះ គឺសុទ្ធតែពួកសហាការីរបស់គាត់ សរុបចំនួនប្រហែលជាងប៉ែតសិបប្លាយនាក់។ ឯព្យាការីមូហាំម៉ាត់ក៏បានភៀសខ្លួនទៅទីក្រុងតាអិហ្វ(**الطَّائِف**) ដើម្បីស្វែងរកការគាំទ្រពីពួកកុលសម្ព័ន្ធនៅទីនោះ ហើយសង្ឃឹមថា ពួកគេនឹងទទួលស្វាគមន៍គាត់ ព្រមទទួលនូវអ្វីដែលគាត់ពាំនាំពីព្រះជាម្ចាស់មកអោយពួកគេ។ ផ្ទុយទៅវិញ ពួកគេមិនត្រឹមតែមិនស្វាគមន៍គាត់ប៉ុណ្ណោះទេ តែថែមទាំងបង្កហិង្សា យកដុំថ្មគប់ ដេញគាត់ចេញ ធ្វើអោយជើងទាំងពីររបស់គាត់ហូរឈាម បែកក្បាលរាប់ថ្នេរ។ គាត់ក៏បានត្រលប់មកទឹកដីមឹក្កះវិញ សង្ឃឹមថា នឹងមានដំណោះស្រាយពីអល់ឡោះជាម្ចាស់ចំពោះគាត់។

***

អព្ភូតហេតុដំណើរឡើងលើមេឃ

ព្រឹត្តិការណ៍ឡើងលើមេឃជាអព្ភូតហេតុរបស់ព្រះដ៏មហាឧត្តម ដែលទ្រង់បានផ្ដល់កិត្តិយសដល់ព្យាការីមូហាំម៉ាត់។ អព្ភូតហេតុនេះ កើតឡើងមុនភៀសខ្លួនទៅទីក្រុងម៉ាឌីណះ។ អត្ថន័យនៃដំណើរ គឺ ការចេញដំណើរពេលយប់ ចេញពីវិហារអាល់ហារ៉ាមនៅម៉ឹក្កះទៅកាន់ វិហារអាល់អឹកសនៅទីក្រុងពិសិដ្ឋ។ ឯពាក្យឡើង គឺជាដំណើរឡើង លើមេឃតាមជាន់នីមួយៗរហូតដល់ជាន់ខ្ពស់បំផុត ហៅថាសេដរ៉ តុលមុនតាហា (سِدْرَةُ الْمُنْتَهَى) ជាដែនផុតដាច់ពីមនុស្សលោក ពួកបិ សាច និងពួកទេវតា។ អព្ភូតហេតុនេះ កើតឡើងក្នុងកំឡុងពេលមួយ យប់ ទៅទាំងវិញ្ញាណ និងខ្លួនប្រាណរបស់ព្យាការីមូហាំម៉ាត់។

លោកអាល់ពូខរី និងមូស្លីម បាននិទានពីអព្ភូតហេតុនេះថា:

-ក្នុងអព្ភូតហេតុនេះគេបានបញ្ជូនសត្វអស្វពាហ៍ម្យ៉ាងឈ្មោះពូរ៉ក (البُراق) ជាសត្វពាហនៈ ទ្រង់ទ្រាយសជាងលាតូចជាងសេះទេស ម្ដងជាយផុតកន្ទុយភ្នែក។

-ក្នុងនោះ ព្យាការីមូហាំម៉ាត់បានចូលទៅថ្វាយបង្គំក្នុងវិហារអាល់ អឹកសចំនួនពីររឹកក្អាត់ ហើយទេវតាជីព្រីលបានមកដល់ ព្រម ទាំងនាំមកជាមួយនូវកែវស្រា និងកែវទឹកដោះ។ ពេលនោះ ព្យាការី គាត់បានជ្រើសយកកែវទឹកដោះមកផឹក ទេវតាជីព្រីល និយាយថា: ឯងបានជ្រើសយករបស់ដែលមកពីធម្មជាតិ។

-គាត់ត្រូវជីព្រីលនាំឡើងដល់មេឃជាន់ទីមួយ ទីពីរ ទីបី រហូត ដល់ជាន់ខ្ពស់បំផុត ហៅថា សេដរ៉តុលមុនតាហា(سِدْرَةُ الْمُنْتَهَى)

នៅទីនោះ ព្រះជាម្ចាស់ ទ្រង់បានត្រាស់បង្គាប់ចំពោះព្យាការីមូហាំម៉ាត់។ ទ្រង់បានត្រាស់បង្គាប់ឱ្យអ្នកឥស្លាមថ្វាយបង្គំប្រាំពេលក្នុងមួយថ្ងៃ។

***

ព្យាការីមូហាំម៉ាត់ភៀសខ្លួនទៅម៉ាឌីណះ

ការចងកំហឹង និងការបង្កហិង្សា នៅតែបន្តកាន់តែខ្លាំងឡើងៗពីសំណាក់ពួជសាសន៍របស់គាត់។ ក៏ប៉ុន្តែ ឧបសគ្គទាំងនេះ ពុំអាចបំភ័យ ឬ រារាំងគាត់ពីការបន្តសកម្មភាពអំពាវនាវរបស់គាត់ឡើយ។ ព្យាការីមូហាំម៉ាត់គាត់តែងទៅបង្ហាញខ្លួននៅចំពោះពួកកុលសម្ព័ន្ធទាំងឡាយ ដែលបានមកធ្វើបុណ្យហាជ្ជនៅទឹកដីម៉ឹក្កះ។ ដូច្នេះ មានមួយក្រុមតូច នៃពួកអ្នកស្រុកយ៉ាស្រិប (يَثْرِب) មានជំនឿចំពោះគាត់ ដែលបច្ចុប្បន្នគេស្គាល់ថាជាទីក្រុងម៉ាឌីណះ (المَدِيْنَةُ المُنَوَّرَة)។ ពួកគេបានសន្យាថានឹងជួយគាំទ្រ និងការពារគាត់ បើសិន ជាគាត់ព្រមភៀសខ្លួនទៅរកពួកគេ។ ដើម្បីផ្សព្វផ្សាយសាសនាឥស្លាមដល់មនុស្សនៅតំបន់នោះ គាត់បានបញ្ជូនទៅជាមួយពួកគេ សហការីរបស់ គាត់ម្នាក់ជាយុវជន ឈ្មោះ មូស្អាប់ ពិន អ៊ូមែរ (مُصْعَبُ بْنُ عُمَيْر) បង្រៀនពួកគេពីក្បួនវិន័យឥស្លាម ហើយមូស្អាប់អាចផ្សព្វផ្សាយឥស្លាមនៅក្នុងទឹកដីនេះបានដោយសេរី។ និយាយពីទឹកដីម៉ឹក្កះវិញ ដោយសារការបង្កហិង្សា ការជិះជាន់ធ្វើបាបនៅតែបន្តពីសំណាក់ពូជសាសន៍របស់គាត់ចំពោះគាត់ ព្រមទាំងពួកអ្នកមានជំនឿវណ្ណៈតូចទាប ព្រះជាម្ចាស់ក៏បានអនុញ្ញាតអោយគាត់ភៀសខ្លួនទៅម៉ាឌីណះ បន្ទាប់ពីសាសនាឥស្លាមបានរីកសុះសាយ និងក្រោយពីមាន

អ្នកឥស្លាមភៀសខ្លួនទៅរស់នៅទីនោះយ៉ាងច្រើនកោះករ។ ពួកគេបានទទួលអបអរសាទរស្វាគមន៍គាត់យ៉ាងកក់ក្ដៅ។ តាំងពីនោះមក ម៉ាឌីណះមូណាវ៉ារ៉ោះ (المدينة المنورة) បានក្លាយជាមូលដ្ឋានផ្សព្វផ្សាយសាសនា ជារដ្ឋធានីនៃរដ្ឋឥស្លាមដ៏រុងរោចន៍។ ព្យាការីមូហាំម៉ាត់បានតាំងនៅជាអចិន្ត្រៃយ៍ក្នុងទឹកដីនេះ គាត់ចាប់ផ្ដើមបង្រៀនគម្ពីរអាល់គួរអាន ច្បាប់វិន័យឥស្លាមដល់ពួកគេ។ ពួកគេបានគ្រាប់តាមឥរិយាបថដ៏ប្រពៃ លក្ខណៈសម្បត្តិដ៏ល្អឥតខ្ចោះរបស់គាត់ ពួកគេស្រលាញ់គាត់ខ្លាំងជាងស្រលាញ់ខ្លួនឯង។ ពួកគេតែងប្រជែងគ្នាបំរើគាត់ សុខចិត្តលះបង់ទ្រព្យមានតំលៃដើម្បីទ្រទ្រង់ការផ្សព្វផ្សាយរបស់គាត់។ ពួកគេរស់នៅក្នុងសង្គមពោរពេញដោយជំនឿផ្លូវចិត្ត ប្រកបដោយភាពសុខដុមរមនា។ ស្ដែងឡើងនូវចំណងមេត្រីភាព មិត្តភាព ភាតរភាពរវាងបុគ្គលនឹងបុគ្គលក្នុងសង្គម រហូតដល់អ្នកមាន អ្នកក្រ អ្នកមានបុណ្យសក្ដិ អ្នកគ្មានបុណ្យសក្ដិ ស្បែកស ស្បែកខ្មៅ អារ៉ាប់ មិនអារ៉ាប់ មានសិទ្ធិស្មើគ្នាក្រោមដំបូលសាសនាឥស្លាមដ៏ឧត្ដុង្គឧត្ដមនេះ។ គ្មានតំលៃអ្វីប្រសើរជាងគ្នា លើកលែងតែចរិយាធម៌ និងការគោរពវិន័យប៉ុណ្ណោះ ទើបធ្វើអោយមនុស្សមានតំលៃ។ លើសពីនេះ ព្យាការីមូហាំម៉ាត់បានគិតគូរពីការរៀបចំគ្រប់វិស័យនៃកិច្ចការក្នុងទីក្រុងម៉ាឌីណះអោយមានច្បាប់មានទម្លាប់ ទើបគាត់បានចែងច្បាប់សរសេរជាលាយលក្ខណ៍អក្សរ ដើម្បីរៀបចំ និងគ្រប់គ្រងសង្គមឥស្លាមដំបូងបង្អស់នៅលើទឹកដីនេះ។

***

ការរំដោះទឹកដីមឹក្កះ

មួយឆ្នាំក្រោយ បន្ទាប់ពីព្យាការីមូហាំម៉ាត់គាត់រស់នៅក្នុងទឹកដីម៉ាឌីណះ ការប្រឈមមុខដាក់គ្នាបានចាប់ផ្តើមរវាងគាត់ និងពួជសាសន៍របស់គាត់ ដែលបានដេញគាត់ចេញពីមឹក្កះ ហើយពួកគេខ្វល់ខ្វាយពីការផ្សព្វផ្សាយសាសនារបស់គាត់។ ការប្រឈមមុខនេះ ចុងក្រោយបណ្តាលឱ្យកើតការច្បាំងរាំងជល់លើកដំបូង ក្នុងប្រវត្តិសាស្រ្តឥស្លាម គឺចម្បាំងបា្តទើរ (بَدْر)។ ចម្បាំងរវាងគូប្រជែងដែលគ្មានតុល្យភាពទាំងបរិមាណ និងយុទ្ធភណ្ឌ។ កាលនោះ អ្នកឥស្លាមមានចំនួនតែបីរយដប់បួននាក់។ ឯទ័ពសត្រូវមានចំនួនមួយពាន់នាក់។ ព្រះជាម្ចាស់បានគាំទ្រអ្នកនាំសាររបស់ទ្រង់ ព្រមទាំងពួកអ្នកមានជំនឿ ពួកគេបានយកឈ្នះលើសត្រូវយ៉ាងចាស់ដៃ។ ចម្បាំងនៅតែបន្តឥតឈប់ឈររវាងពួកអ្នកឥស្លាម និងពួជសាសន៍របស់ខ្លួនដែលជាពួកអ្នកជឿលើពហុទេព។ ប្រាំបីឆ្នាំក្រោយ ព្យាការីមូហាំម៉ាត់ អាចរៀបចំកងទ័ពបានចំនួនមួយម៉ឺននាក់ ដើម្បីទៅរំដោះទឹកដីមឹក្កះ។ គាត់បាននាំទ័ពសំដៅទៅមឹក្កះ ហើយអាចរំដោះបានយ៉ាងជោគជ័យ គាត់អាចផ្តួលរំលំពួកកុលសម្ព័ន្ធ និងពួជសាសន៍របស់គាត់ដែលធ្លាប់តែធ្វើទុក្ខបុកម្នេញ ជិះជាន់ធ្វើបាបអ្នកទន់ខ្សោយ ដែលដើរតាមគាត់ អោយបរាជ័យ។ គាត់បានទទួលជ័យជំនះពីពួកគេទាំងស្រុង ហើយក៏បានហៅឆ្នាំនោះថា ជាឆ្នាំរំដោះ។ អល់ឡោះជាម្ចាស់ទ្រង់បានបន្ទូលថា:

﴿إِذَا جَآءَ نَصۡرُ ٱللَّهِ وَٱلۡفَتۡحُ ۝١ وَرَأَيۡتَ ٱلنَّاسَ يَدۡخُلُونَ فِي دِينِ ٱللَّهِ أَفۡوَاجٗا ۝٢ فَسَبِّحۡ بِحَمۡدِ رَبِّكَ وَٱسۡتَغۡفِرۡهُۚ إِنَّهُۥ كَانَ تَوَّابَۢا ۝٣﴾ **سورة النصر / الآية: ١–٣**

មានន័យថា: (នែមូហាំម៉ាត់! ខណៈដែលឯងបានទទួលជោគជ័យលើពួកគូរស្ស និងបានរំដោះទីក្រុងមឹក្កះ និងខណៈដែល ឯងបានឃើញមនុស្សជាច្រើន នាំគ្នាមកចូលសាសនាឥស្លាមទាំងក្រុមៗ។ ដូច្នេះ ចូរឯងត្រៀមខ្លួនជួបនឹងព្រះជាម្ចាស់ ″ស្លាប់″ ដោយចំរើននូវការសក្ការៈតំកើង និងបួងសួងសុំក្តីខន្តីអភ័យទោស ព្រោះទ្រង់មហាខន្តីចំពោះអ្នកណាដែលលើកតំកើង និងសុំការខន្តីអភ័យទោសចំពោះព្រះអង្គ)។

ក្រោយពីទទួលបានជ័យជំនះ គាត់បានប្រមូលទាំងអស់ពួកអ្នកជឿលើពហុទេពនៅមឹក្កះ រួចសួរពួកគេថា: (តើពួកអ្នកបានឃើញខ្ញុំធ្វើយ៉ាងម៉េចខ្លះចំពោះពួកអ្នក? ពួកគេឆ្លើយថា ល្អ.. ជាបងប្អូនល្អជាក្មួយល្អ។ ព្យាការីមូហាំម៉ាត់បានប្រសាសន៍ទៅពួកគេថា: សូមអញ្ជើញទៅវិញចុះ ពួកអ្នកទាំងអស់សុទ្ធតែមានសេរីភាព)។

ដោយសារតែភាពអត់អោន និងការសំដែងអកប្បកិរិយាល្អរបស់គាត់ក្នុងការប្រាស្រ័យទាក់ទងជាមួយពួកគេ និងចិត្តមេត្តារបស់គាត់ចំពោះពួកគេ ទើបជាហេតុ ដែលពួកគេភាគច្រើនចូលសាសនាឥស្លាម។ ក្រោយពេលរំដោះ គាត់បានត្រលប់មកម៉ាឌីណះវិញ។ លុះមួយរយៈក្រោយមក គាត់បានមកមឹក្កះម្តងទៀត ក្នុងគោលបំណងប្រារព្ធបុណ្យហ៍ជ្ជ មានពួកសហការីចំនួនដប់មួយម៉ឺនបួនពាន់នាក់អមដំណើរជាមួយ។ បុណ្យហ៍ជ្ជនេះ គេហៅថា បុណ្យហ៍ជ្ជលាដំណើរ

(حَجَّةُ الوَداع) ព្រោះហាក់បីដូចជាមកលាដំណើរពួកអ្នកឥស្លាម ដោយសារព្យាការីមូហាំម៉ាត់គាត់ជិតដល់វេលាត្រូវលាចាកលោកយើងនេះ។

***

មរណភាពរបស់ព្យាការីមូហាំម៉ាត់

ក្រោយពេលព្យាការីមូហាំម៉ាត់ គាត់បានបំពេញបុណ្យហ័ជ្ជរួចរាល់ ក៏ត្រលប់មកម៉ាឌីណះវិញ។ គាត់ធ្លាក់ខ្លួនឈឺ ផ្តើមឡើងដោយឈឺក្បាល ក្តៅខ្លួនខ្លាំង។ ជំងឺរបស់គាត់កាន់តែធ្ងន់ធ្ងរឡើងពីមួយថ្ងៃទៅមួយថ្ងៃ រហូតដល់អស់សង្ខារនៅថ្ងៃចន្ទទី១២ ខែរ៉ពីអុលអាវ៉ាល់ ឆ្នាំទី១១ ហ.ស។ គេបញ្ចុះសពគាត់នៅម៉ាឌីណះ គាត់បានទទួលមរណៈក្នុងជន្មាយុ៦៣ឆ្នាំ។ គាត់បានរស់នៅម៉ឹក្កះ៤០ឆ្នាំមុននឹងទទួលព្រះបន្ទូល ហើយក្រោយពេលតែងតាំងជាព្យាការី គាត់នៅទីនោះរយៈកាល១៣ឆ្នាំទៀត ដើម្បីអំពាវនាវមនុស្សមករកជំនឿឯកទេវៈ។ បន្ទាប់មក គាត់បានភៀសខ្លួនមកម៉ាឌីណះ ហើយរស់នៅទីនោះរយៈកាល ១០ឆ្នាំ។ ព្រះបន្ទូលត្រូវបានប្រទានចុះមកជាបន្តបន្ទាប់នៅម៉ាឌីណះ រហូតបានបញ្ចុះជាគម្ពីរអាល់គួរអានមួយទាំងមូល និងជាក្បួនច្បាប់ឥស្លាមដ៏សុក្រឹត។ មរណភាពរបស់គាត់ធ្វើអោយពួកអ្នកឥស្លាមកើតចលាចល អ្នកខ្លះមិនជឿពីដំណឹងមរណៈរបស់គាត់។ ពេលនោះអាពូហ្គាកើរ(أبو بَكْرٍ رضي اللَّهُ عنه) បានឡើងថ្លែងទៅកាន់មហាជនទាំងមូល ដើម្បីជំរាបពួកគេពីការពិតដែលព្យាការីមូហាំម៉ាត់បានទទួលមរណៈ ដូចជាមនុស្សទូទៅ ព្រមទាំងព្យាការីដទៃទៀតមិនអាចជៀសផុតពី

សេចក្ដីស្លាប់នេះជាដាច់ខាត ភ្លាមនោះ គាត់ក៏បានសូត្រព្រះបន្ទូលរបស់អល់ឡោះជាម្ចាស់:

﴿ وَمَا مُحَمَّدٌ إِلَّا رَسُولٌ قَدْ خَلَتْ مِن قَبْلِهِ ٱلرُّسُلُ ۚ أَفَإِيْن مَّاتَ أَوْ قُتِلَ ٱنقَلَبْتُمْ عَلَىٰٓ أَعْقَـٰبِكُمْ ۚ وَمَن يَنقَلِبْ عَلَىٰ عَقِبَيْهِ فَلَن يَضُرَّ ٱللَّهَ شَيْـًٔا ۗ وَسَيَجْزِى ٱللَّهُ ٱلشَّـٰكِرِينَ ﴿١٤٤﴾ ﴾ سورة آل عمران / الآية: ١٤٤

មានន័យថា: (ហើយមូហាំម៉ាត់ គ្មានអ្វីក្រៅពីមានតួនាទីជាអ្នកនាំសារដូចគ្នានឹងពួកអ្នកនាំសារសម័យមុនផងដែរ បើមូហាំម៉ាត់ត្រូវស្លាប់ ឬត្រូវគេសំលាប់ តើពួកអ្នកនឹងបកក្រោយបោះបង់សាសនានេះចោលឬ? ចំពោះនរណាដែលបកក្រោយ គឺអល់ឡោះគ្មានខាតបង់អ្វីបន្តិចសោះឡើយ។ អល់ឡោះនឹងតបស្នងចំពោះពួកអ្នកដែលដឹងគុណ)។

ព្រះបន្ទូលនេះ ជាការដាស់សតិអោយអ្នកឥស្លាមភ្ញាក់រលឹកដឹងថា ព្យាការីមូហាំម៉ាត់ ពិតជាបានស្លាប់ដូចមនុស្សដទៃឯទៀតមែន។ ក្រោយពេលព្យាការីមូហាំម៉ាត់បានលាចាកលោកទៅ សហការីទាំងអស់ ដែលស្មោះស្ម័គ្រនឹងគាត់ និងមានសទ្ធាជ្រះថ្លាចំពោះអល់ឡោះជាម្ចាស់ ពួកគេបានបន្តផ្សព្វផ្សាយជំនឿឥស្លាមដ៏សុក្រឹតនេះអោយរីកសុះសាយពេញទាំងសកលលោក ក្រោមការផ្ទុកផ្ដាក់និងការគាំទ្រពីអល់ឡោះជាម្ចាស់ចំពោះពួកគេ។

***

គោលសំខាន់ខ្លះៗនៃជំនឿចំពោះព្យាការីមូហាំម៉ាត់ អ្នកឥស្លាម ចាំបាច់ត្រូវជឿជាក់ថា ព្យាការីមូហាំម៉ាត់បានទទួលជោគជ័យក្នុងការ បណ្តុះបណ្តាលអប់រំក្រុមជំនាន់ទីមួយដែលជឿតាមគាត់។ គាត់បាន អប់រំពួកគេលើមាគ៌ាអាល់គួរអានដ៏សុក្រឹត ត្រឹមត្រូវ។ ទើបសហការី របស់គាត់(**صَحابَة**) ដែលបន្តវេនពីគាត់ ក៏ទទួលជោគជ័យយ៉ាងធំធេង ក្នុងការពាំនាំសាសនារបស់អល់ឡោះ ផ្តល់ឱ្យមនុស្សជំនាន់ក្រោយ រហូតសាសនានេះ បានមកដល់ពួកយើងសព្វថ្ងៃ ហើយសាសនានេះ នឹងឋិតនៅគង់វង្សរហូតដល់ថ្ងៃបរលោក។ អល់ឡោះទ្រង់បានមាន ព្រះបន្ទូលបញ្ជាក់ថា:

﴿ لَقَدْ مَنَّ ٱللَّهُ عَلَى ٱلْمُؤْمِنِينَ إِذْ بَعَثَ فِيهِمْ رَسُولًا مِّنْ أَنفُسِهِمْ يَتْلُوا۟ عَلَيْهِمْ ءَايَـٰتِهِۦ وَيُزَكِّيهِمْ وَيُعَلِّمُهُمُ ٱلْكِتَـٰبَ وَٱلْحِكْمَةَ ﴾ **سورة آل عمران / الآية: ١٦٤**

មានន័យថា: (ពិតប្រាកដ អល់ឡោះជាម្ចាស់ទ្រង់បានប្រទានពរជ័យ ចំពោះពួកអ្នកមានជំនឿ ខណៈដែលទ្រង់បានបញ្ជូនអ្នកនាំសារម្នាក់ ទៅកាន់ពួកគេ ជាជាតិរបស់ពួកគេ អ្នកនាំសារនោះសូត្រគម្ពីរអាល់គួរ អានឱ្យពួកគេស្តាប់ ជម្រះសម្អាតពួកគេពីជំនឿពហុទេព និងអំពើ អសីលធម៌ ហើយបង្រៀនពួកគេពីគម្ពីរអាល់គួរអាន និងស៊ុណ្ណះ)។

ពិតប្រាកដ ព្យាការីមូហាំម៉ាត់ គាត់បានបំពេញភារកិច្ចនេះបាន យ៉ាងល្អប្រសើរ ហើយផ្លែផ្កានៃការបង្រៀនអប់រំបណ្តុះបណ្តាលរបស់ គាត់ បណ្តុះបាននូវជំនាន់ពួកសហការីតែមួយគត់គ្មានគូប្រៀបដែល

ពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រ។ នេះជាអ្វីដែលអ្នកឥស្លាមគ្រប់រូប ដែលព្រមទទួលអល់ឡោះជាព្រះ ឥស្លាមជាសាសនា និងមូហាំម៉ាត់ជាព្យាការី និងជាអ្នកនាំសារ គួរគប្បីជឿជាក់។ មានអំណះអំណាងជាច្រើនដែលអះអាងថា ពួកសហាការី(**صَحابَة**)របស់គាត់ជាមនុស្សប្រសើរឧត្តុង្គឧត្តមជាងគេបន្ទាប់ពីពួកព្យាការី និងពួកអ្នកនាំសាររបស់ព្រះ។ ហើយក៏មានអំណះអំណាងជាច្រើនដែលលើកតំកើង សរសើរពីពួកគេទាំងក្នុងគម្ពីរអាល់គួរអាន និងប្រសាសន៍របស់ព្យាការីមូហាំម៉ាត់ដែលបានត្រាស់ដឹងពីព្រះជាម្ចាស់។ ព្រះជាម្ចាស់ទ្រង់បន្ទូលសរសើរពីពួកអ្នកភៀសខ្លួន និងហៅពួកគេថា ជាពួកអ្នកស្មោះត្រង់ (**الصّادِقون**) ដូចទ្រង់បានមានព្រះបន្ទូលបញ្ជាក់ថា:

﴿ لِلْفُقَرَآءِ ٱلْمُهَٰجِرِينَ ٱلَّذِينَ أُخْرِجُوا۟ مِن دِيَٰرِهِمْ وَأَمْوَٰلِهِمْ يَبْتَغُونَ فَضْلًا مِّنَ ٱللَّهِ وَرِضْوَٰنًا وَيَنصُرُونَ ٱللَّهَ وَرَسُولَهُۥٓ ۚ أُو۟لَٰٓئِكَ هُمُ ٱلصَّٰدِقُونَ ﴿٨﴾ ﴾ **سورة الحشر / الآية : ٨**

មានន័យថា: (ក៏ដូចគ្នាដែរ ទ្រង់បានប្រទានទ្រព្យជ័យភណ្ឌសម្រាប់ពួកអ្នកក្រីក្រភៀសខ្លួនដែលត្រូវគេបង្ខិតបង្ខំឱ្យចាកចេញពីផ្ទះសំបែង និងចោលទ្រព្យសម្បត្តិ ពួកគេចង់បានក្តីប្រទាន និងការគាប់ព្រះទ័យរបស់អល់ឡោះ ពួកគេជួយគាំទ្រសាសនារបស់អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ពួកគេជាពួកអ្នកដែលស្មោះត្រង់)។

ទ្រង់បានសរសើរពួកអ្នកគាំទ្រជនភៀសខ្លួន ហើយទ្រង់បានហៅថា ជាពួកអ្នកដែលជោគជ័យ (**المُفْلِحون**) ដូចទ្រង់បានមានព្រះបន្ទូលបញ្ជាក់ថា:

﴿ وَٱلَّذِينَ تَبَوَّءُو ٱلدَّارَ وَٱلْإِيمَٰنَ مِن قَبْلِهِمْ يُحِبُّونَ مَنْ هَاجَرَ إِلَيْهِمْ وَلَا يَجِدُونَ فِي صُدُورِهِمْ حَاجَةً مِّمَّآ أُوتُواْ وَيُؤْثِرُونَ عَلَىٰٓ أَنفُسِهِمْ وَلَوْ كَانَ بِهِمْ خَصَاصَةٌۚ وَمَن يُوقَ شُحَّ نَفْسِهِۦ فَأُوْلَٰٓئِكَ هُمُ ٱلْمُفْلِحُونَ ﴿٩﴾ ﴾ سورة الحشر / الآية : ٩

មានន័យថាៈ (ពួកអ្នករស់នៅស្រុកម៉ាឌីណាៈ ហើយមានជំនឿមុននឹងពួកជនភៀសខ្លួនមកដល់ ពួកគេស្រលាញ់ ជួយរំលែកទុក្ខ និងផ្តល់ទ្រព្យសម្បត្តិដល់ពួកជនភៀសខ្លួន ពួកគេគ្មានចិត្តច្រណែនចំពោះពួកជនភៀសខ្លួនដែលបានទទួលទ្រព្យជ័យភណ្ឌ ពួកគេជួយបំពេញតំរូវការពួកជនភៀសខ្លួនដោយពុំគិតពីខ្លួនឯង ទោះជា ពួកគេមានការខ្វះខាតក៏ដោយ។ អ្នកដែលចាកផុតពីចិត្តរិះកំណាញ់នោះ គឺជាពួកអ្នកដែលជោគជ័យ)។

អល់ឡោះទ្រង់បានសំរេចសព្វព្រះទ័យចំពោះពួកសហាការីរបស់ព្យាការីមូហាំម៉ាត់ ដូចទ្រង់បានមានព្រះបន្ទូលៈ

﴿ وَٱلسَّٰبِقُونَ ٱلْأَوَّلُونَ مِنَ ٱلْمُهَٰجِرِينَ وَٱلْأَنصَارِ وَٱلَّذِينَ ٱتَّبَعُوهُم بِإِحْسَٰنٍ رَّضِيَ ٱللَّهُ عَنْهُمْ وَرَضُواْ عَنْهُ وَأَعَدَّ لَهُمْ جَنَّٰتٍ تَجْرِي تَحْتَهَا ٱلْأَنْهَٰرُ خَٰلِدِينَ فِيهَآ أَبَدًاۚ ذَٰلِكَ ٱلْفَوْزُ ٱلْعَظِيمُ ﴿١٠٠﴾ ﴾ سورة التوبة / الآية : ١٠٠

មានន័យថាៈ (ពួកអ្នកដែលមានជំនឿមុនដំបូងគេបង្អស់នៃពួកជនភៀសខ្លួន និងពួកអ្នកគាំទ្រជនភៀសខ្លួន ហើយនិងពួកអ្នកប្រកាន់តាមពួកគេយ៉ាងខ្ជាប់ខ្ជួនទាំងកាយ វាចា ចិត្ត ពួកគេប្រាថ្នាចង់បានការសព្វព្រះរបស់អល់ឡោះ។ ដូច្នេះ ទ្រង់បានសព្វព្រះទ័យចំពោះពួកគេ ហើយពួកគេក៏ពេញចិត្តចំពោះព្រះអង្គ ទ្រង់បានរៀបចំសំរាប់ពួកគេ

នូវឋានសួគ៌ដែលមានទន្លេហូរពីក្រោម ពួកគេរស់នៅជាអមតៈក្នុងឋានសួគ៌នោះ។ នេះ គឺជាជោគជ័យមួយដ៏ឧត្តុង្គឧត្តម)។

ជាមួយនោះ អល់ឡោះជាម្ចាស់ទ្រង់បានសរសើរពីឋានៈ និងការគោរពសក្ការៈរបស់សហាការីព្យាការីមូហាំម៉ាត់ ដូចទ្រង់បានមានព្រះបន្ទូលថាៈ

﴿ تَرَىٰهُمْ رُكَّعًا سُجَّدًا يَبْتَغُونَ فَضْلًا مِّنَ ٱللَّهِ وَرِضْوَٰنًا ۖ سِيمَاهُمْ فِى وُجُوهِهِم مِّنْ أَثَرِ ٱلسُّجُودِ ۚ ﴿٢٩﴾ ﴾ سورة الفتح / الآية : ٢٩

មានន័យថាៈ (ឯងនឹងឃើញពួកគេក្រាបថ្វាយបង្គំចំពោះព្រះជាម្ចាស់ប្រាថ្នាចង់បានក្តីប្រទាន និងការសព្វព្រះទ័យរបស់អល់ឡោះ សញ្ញាសំគាល់របស់ពួកគេនៅនឹងមុខរបស់ពួកគេ គឺស្នាមក្រាបបង្គំ)។

ឯព្យាការីមូហាំម៉ាត់គាត់បានសរសើរពួកគេ និងបញ្ជាក់ប្រាប់ពីតំលៃរបស់ពួកគេមានក្នុងប្រសាសន៍ជាច្រើន។ ក្នុងនោះ គាត់បានមានប្រសាសន៍ថាៈ

عَنْ عِمْرَانَ بْنَ حُصَيْنٍ رَضِيَ اللَّهُ عَنْهُمَا قال قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ : (خَيْرُ أُمَّتِي قَرْنِي ثُمَّ الَّذِينَ يَلُونَهُمْ ثُمَّ الَّذِينَ يَلُونَهُمْ) صحيح البخاري

មានន័យថាៈ (ប្រជាជាតិខ្ញុំដែលប្រសើរជាងគេ គឺនៅជំនាន់ខ្ញុំ ពួកជំនាន់បន្ទាប់ និងពួកជំនាន់បន្ទាប់មកទៀត)។

គាត់ក៏បានប្រសាសន៍ការពារពីតំលៃ និងឋានៈរបស់ពួកគេថាៈ

عَنْ أَبِي سَعِيدٍ الْخُدْرِيِّ رَضِيَ اللَّهُ عَنْهُ قَالَ قَالَ النَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ : (لَا تَسُبُّوا أَصْحَابِي فَلَوْ أَنَّ أَحَدَكُمْ أَنْفَقَ مِثْلَ أُحُدٍ ذَهَبًا مَا بَلَغَ مُدَّ أَحَدِهِمْ وَلَا نَصِيفَهُ) صحيح البخاري

មានន័យថា: (ចូរពួកអ្នកកុំជេរប្រមាថសហាការីរបស់ខ្ញុំ បើទោះជាពួកអ្នកចំណាយមាសប៉ុនភ្នំអូហុឌធ្វើល្អ ក៏មិនមានតំលៃស្មើនឹងមួយក្បង់ដៃ ឬពាក់កណ្តាលក្បង់ដៃរបស់ពួកគេដែរ)។

ព្រះបន្ទូល និងប្រសាសន៍ខាងលើ បញ្ជាក់យ៉ាងច្បាស់ថា គោលសំខាន់នៃជំនឿដ៏ត្រឹមត្រូវរបស់អ្នកឥស្លាម គឺត្រូវជឿជាក់ថា ពួកសហាការី មានតំលៃ និងឋានៈដ៏ពិសេសបំផុតនៅចំពោះអល់ឡោះជាម្ចាស់។ អល់ឡោះជាម្ចាស់ ទ្រង់បានជ្រើសរើសពួកគេពីក្នុងចំណោមមនុស្ស ដើម្បីធ្វើជាសហាការីព្យាការី ឬអ្នកនាំសាររបស់ព្រះអង្គ។ លើសពីនេះ ព្យាការីមូហាំម៉ាត់បានបណ្តុះបណ្តាល និងអប់រំពួកគេដោយផ្ទាល់ ជាការអប់រំដ៏ពិសេស។ ដោយមានការសព្វព្រះទ័យពីអល់ឡោះជាម្ចាស់ និងការពេញចិត្ត ពេញថ្លើមរបស់ព្យាការីចំពោះពួកគេ ទើបពួកគេស្អាតស្អំពីលក្ខណៈអសកម្ម ឬគុណវិបត្តិណាមួយដែលមិនគប្បី។ លើសពីនេះ ជាគោលសំខាន់នៃជំនឿផងដែរ គឺអ្នកឥស្លាមគ្រប់រូបគប្បី លើកតំកើងពួកគេ គោរពតំលៃរបស់ពួកគេ ពេញចិត្តនឹងពួកគេ ត្រូវបួងសួងឱ្យពួកគេថា: (សូមអល់ឡោះសព្វព្រះទ័យ និងមេត្តាប្រណីចំពោះពួកគេ) ហើយសំដែងសក្ការៈចំពោះអល់ឡោះជាម្ចាស់ដោយការគោរពស្រលាញ់ចំពោះពួកគេ។ ពីព្រោះ អល់ឡោះជាម្ចាស់ទ្រង់បានជ្រើសរើសពួកគេ ដើម្បីមកជួយគាំទ្រព្យាការីរបស់ព្រះអង្គ និងជួយគាំទ្រដល់ការផ្សព្វផ្សាយរបស់គាត់។ ពួកគេពិតជាស្មោះត្រង់មែន ដោយសារ ខណៈដែលមនុស្សទាំងអស់នាំគ្នាប្រឆាំងជំទាស់នឹងព្យាការីមូហាំម៉ាត់ ពួកគេបែរជាមានជំនឿ ជួយជ្រោមជ្រែង

និងគាំទ្រគាត់ទៅវិញ។ កាលគាត់នៅរស់ ពួកគេបានជួយគាំទ្រ រហូតដល់ការផ្សព្វផ្សាយសាសនារបស់គាត់បានរីកសុះសាយ រឹងមាំ ហើយនៅពេលគាត់លាចាកលោកនេះទៅ ក៏ពួកគេនៅតែជាហេតុធ្វើអោយសាសនានៅមានជីវិតគង់វង្ស ហើយបានផ្សព្វផ្សាយអោយរីកចំរើនសុះសាយទូទាំងសកលលោក។

យោងតាមការបកស្រាយខាងលើ បានសេចក្តីថាៈ នរណាហ៊ានប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ កិត្តិយស ចោទប្រកាន់ពាក្យមិនពិតមួលបង្កាច់ពួកគេ គឺស្មើនឹងការប្រមាថអល់ឡោះជាម្ចាស់។ ពីព្រោះគេកំពុងតែបំពានលើសេចក្តីកោតសរសើររបស់អល់ឡោះចំពោះពួកសហការី ដែលទ្រង់ផ្ទាល់ជាអ្នកជ្រើសរើស និងផ្ទុកផ្តាក់ពួកគេ ដើម្បីជួយព្យាការីរបស់ព្រះអង្គ។ ម្យ៉ាងវិញទៀត គេពិតជាមានចេតនាចោទប្រកាន់ថា ព្យាការីមូហាំម៉ាត់ជាមនុស្សប្រហែសពុំបានគិតឱ្យជិតដល់យល់ឱ្យបានច្បាស់ពីមនុស្សដែលនៅជាមួយខ្លួន អប់រំដោយខ្លួនឯងផ្ទាល់។ លើសពីនេះ គេគឺជាអ្នកបដិសេធចំពោះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ លើគោលគ្រឹះដ៏សំខាន់នៃសាសនាឥស្លាម ដែលគ្មានចំណុចណាគួរជជែក ឬវែកញែកនោះឡើយ។ ចំពោះបុគ្គលដែលហ៊ានប្រមាថចំពោះពួកសហការីព្យាការីមូហាំម៉ាត់ ចាំបាច់ត្រូវទទួលកំហុស និងកែខ្លួនមកទទួលការពិត ដែលមានក្នុងអាល់គួរអាន និងលំអានរបស់ព្យាការី បញ្ជាក់ពីការសព្វព្រះទ័យរបស់ទ្រង់ និងការពេញចិត្តរបស់ព្យាការីចំពោះពួកគេ។

***

ព្យាការីមូហាំម៉ាត់គាត់មានប្រពន្ធ១២នាក់។ ប្រពន្ធរបស់គាត់ទាំងអស់សុទ្ធតែជាស្ត្រីមេម៉ាយចាស់ មានអាយុច្រើន លើកលែងតែអាអ៊ីសះ កូនស្រី អាពូបាក្កើរ តែមួយគត់ ជាប្រពន្ធក្រមុំរបស់គាត់។ ប្រពន្ធទីមួយ ដែលគាត់រៀបការ មុននឹងគាត់ក្លាយជាព្យាការី គឺលោកស្រីខទីហ្ជះ មានអាយុ៤០ឆ្នាំ ហើយកាលនោះ ព្យាការីមូហាំម៉ាត់គាត់ទើបមានអាយុ២៥ឆ្នាំ។ គាត់ពុំបានយកប្រពន្ធផ្សេងទៀតរហូតដល់គាត់មានអាយុ៥២ឆ្នាំ បន្ទាប់ពីប្រពន្ធទីមួយរបស់គាត់ឈ្មោះខទីហ្ជះបានស្លាប់។ សូមបញ្ជាក់ថា ការយកប្រពន្ធចំនួនដ៏ច្រើននេះ ជាច្បាប់ដោយឡែកចំពោះតែព្យាការីមូហាំម៉ាត់ប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត គាត់យកប្រពន្ធច្រើនបែបនេះ ពុំមែនដោយសារតំរូវការតណ្ហា ឬយកដោយខ្ជះខ្ជាយនោះទេ គឺមានគោលបំណង និងមូលហេតុផ្លូវច្បាប់សំខាន់ៗនាសម័យកាលនោះ។ បើសិនជា យើងសិក្សាលំអិតពីដំណាក់កាលនីមួយៗ នៃជិវិតអាពាហ៍ពិពាហ៍របស់គាត់ ឃើញថាតណ្ហាពុំមែនជាតួនាទីសំខាន់ក្នុងជីវិតរបស់គាត់។ ដើម្បីលាតត្រដាងពីការពិត ចូរអានការវិភាគដូចខាងក្រោម:

១-គាត់នៅដល់អាយុ២៥ឆ្នាំជាកំលោះបរិសុទ្ធរហូតដល់សាសន៍របស់គាត់ហៅគាត់ថា ជាមនុស្សមានសច្ចៈទៀងត្រង់(الصّادِقُ الأمِين)។

២-ប្រពន្ធទី១របស់គាត់ ក្នុងវ័យ២៥ឆ្នាំ ជាវ័យពោរពេញដោយតណ្ហាពុះកញ្ជ្រោល គាត់បែរជាយកស្ត្រីវ័យបងគាត់១៥ឆ្នាំធ្វើជាប្រពន្ធហើយជាស្ត្រីមេម៉ាយធ្លាប់មានប្ដីពីរដង ព្រមទាំងមានកូនចៅទៀត

ផង។ គាត់រួមរស់ជាមួយប្រពន្ធរយៈកាល២៥ឆ្នាំ រហូតដល់អាយុគាត់គំរប់៥០ឆ្នាំ មានតែប្រពន្ធទី១នេះមួយគត់ ពុំមានប្រពន្ធផ្សេងឡើយ ថ្វីត្បិតគាត់នៅក្មេង រាងកាយមាំមួន និងកំលាំងនៅពេញក៏ដោយ។

៣-ប្រពន្ធទី១របស់គាត់ឈ្មោះខទីហ្ជះបានស្លាប់ចោលនៅពេលគាត់មានអាយុ៥០ឆ្នាំ។ គាត់រស់នៅជាពោះម៉ាយរយៈកាលពីរឆ្នាំមិនយកប្រពន្ធ ព្រោះគាត់នៅនឹកស្រណោះដល់ប្រពន្ធទី១របស់គាត់។

៤-ចាប់ពីអាយុ៥២ដល់៦០ឆ្នាំ គាត់បានរៀបការជាមួយប្រពន្ធផ្សេងជាច្រើននាក់ ដោយមានមូលហេតុខុសៗគ្នាពាក់ព័ន្ធនឹងស្ថានភាពនៃការផ្សព្វផ្សាយសាសនាដែលនឹងបកស្រាយដូចខាងក្រោម។

បន្ទាប់ពីបានបង្ហាញបួនចំណុចខាងលើ គួរត្រិះរិះពិចារណាអោយបានជិតដល់នូវខ្លឹមសារដូចតទៅៈ-

-តើសមហេតុផលទេ ស្រាប់តែតណ្ហាបានពុះកញ្ជ្រោលចំពោះព្យាការីមូហាំម៉ាត់ភ្លាមៗនៅពេលគាត់មានអាយុ៥២ឆ្នាំ?

-តើសមហេតុផលទេ បុគ្គលដែលពោរពេញដោយតណ្ហា បែរជាទៅយកប្រពន្ធមេម៉ាយ គឺលោកស្រីខទីហ្ជះដែលធ្លាប់មានប្តីពីរដង ហើយរស់នៅជាមួយគ្នាអស់រយៈកាល២៥ឆ្នាំ ដោយពុំបានយកប្រពន្ធផ្សេងទៀត? មិនតែប៉ុណ្ណោះ ក្រោយពីប្រពន្ធស្លាប់ គាត់នៅជាពោះម៉ាយរយៈកាលពីរឆ្នាំ មិនយកប្រពន្ធ ជាការគោរពដល់ប្រពន្ធទី១របស់គាត់។

-បន្ទាប់ពីប្រពន្ធទី១បានស្លាប់ ព្យាការីមូហាំម៉ាត់បានរៀបការ
ជាមួយសាវហ្វះ កូនស្រី ហ្យាំអះ ដែលមានអាយុ៥០ឆ្នាំ បាន
រស់នៅជាប្រពន្ធមួយប្ដីមួយរយៈពេលបីឆ្នាំ។ ជាស្ត្រីមេម៉ាយ
ទី១ក្នុងឥស្លាម ហើយព្យាការីមូហាំម៉ាត់គាត់ចង់ផ្តល់កិត្តិយស
ដល់ស្រ្តីរូបនេះ និងស្រ្តីមេម៉ាយផ្សេងទៀត ដោយខ្លួនគាត់
ផ្ទាល់ចាប់ផ្តើមអនុវត្ត មិនប្រើអ្នកដទៃអោយរៀបការជាមួយ
នោះឡើយ។ គាត់បានផ្តល់កិត្តិយសដល់ស្រ្តីមេម៉ាយគ្មានទី
ពឹង ដោយខ្លួនគាត់ផ្ទាល់ ដើម្បីជាគំរូល្អដល់អ្នកជំនាន់ក្រោយ។
បើគាត់ល្មោភតណ្ហា គាត់ពិតជាមិនចំណាយជីវិតយុវវ័យរបស់
គាត់ជាមួយតែស្រ្តីវ័យចំណាស់ទាំងពីរ មិនព្រមយកប្រពន្ធ
ក្មេងៗ ហើយជារឿងងាយបំផុតចំពោះគាត់ តែគាត់មិនធ្វើ។

ឯចំណែកមូលហេតុពិតប្រាកដ ដែលព្យាការីមូហាំម៉ាត់គាត់យកប្រពន្ធច្រើន គឺមានការពាក់ព័ន្ធយ៉ាងស៊ីជំរៅទៅនឹងបេសកកម្មរបស់គាត់ដែលអល់ឡោះជាម្ចាស់ទ្រង់បានបញ្ជូនគាត់ ដើម្បីបង្រៀនមនុស្សពីគោលសីលធម៌នៃក្តីអាណិត និងក្តីស្រលាញ់ដល់មនុស្សជាតិ និងអប់រំឱ្យពួកគេចេះអាណិតស្រលាញ់គ្នា សាមគ្គីគ្នា ដែលស្តែងឡើងតាមរយៈឥរិយាបថ និងកាយវិការរបស់គាត់ ដូចទ្រង់បានមានព្រះបន្ទូលថាៈ

﴿ وَمَآ أَرۡسَلۡنَٰكَ إِلَّا رَحۡمَةٗ لِّلۡعَٰلَمِينَ ١٠٧ ﴾ **سورة الأنبياء / الآية: ١٠٧**

មានន័យថាៈ (យើងគ្មានបញ្ជូនអ្នកឯងមក លើកលែងតែជាក្តីមេត្តាករុណាដល់ពិភពលោកទាំងមូល)។

ពិតប្រាកដ អល់ឡោះជាម្ចាស់បានកំណត់នូវកាតព្វកិច្ចចាំបាច់សំរាប់ព្យាការីមូហាំម៉ាត់ក្នុងការរស់នៅ និងហេតុផលដែលទ្រង់បានបញ្ជូនគាត់មក ទ្រង់បានមានព្រះបន្ទូលថាៈ

﴿ هُوَ ٱلَّذِى بَعَثَ فِى ٱلْأُمِّيِّـۧنَ رَسُولًا مِّنْهُمْ يَتْلُوا۟ عَلَيْهِمْ ءَايَٰتِهِۦ وَيُزَكِّيهِمْ وَيُعَلِّمُهُمُ ٱلْكِتَٰبَ وَٱلْحِكْمَةَ وَإِن كَانُوا۟ مِن قَبْلُ لَفِى ضَلَٰلٍ مُّبِينٍ ﴿٢﴾ ﴾ **سورة الجمعة / الآية : ٢**

មានន័យថាៈ (ទ្រង់ជាព្រះដែលបានបញ្ជូនទៅកាន់ពួកអ្នកមិនចេះអក្សរនូវអ្នកនាំសារម្នាក់ពីចំណោមពួកគេ អ្នកនាំសារនោះសូត្រគម្ពីរអាល់គួរអានអោយពួកគេស្តាប់ ជម្រះសម្អាតពួកគេពីជំនឿពហុទេព និងអំពើអសីលធម៌ បង្រៀនពួកគេពីគម្ពីរអាល់គួរអាន និងស៊ុណ្ណះ ថ្វីត្បិតពីមុន ពួកគេបិតក្នុងក្តីវង្វេង)។

ដូច្នេះ កាតព្វកិច្ចសំខាន់របស់ព្យាការីមូហាំម៉ាត់មានការកំណត់ច្បាស់លាស់ ពុំអាចទៅរវល់នឹងរឿងផ្សេងបានឡើយ។ ជីវិតរបស់គាត់ ពោរពេញដោយផែនការច្បាស់លាស់ ហើយប្រើផែនការទាំងនោះ ដើម្បីសំរួលដល់ការអំពាវនាវមនុស្សមករកព្រះជាម្ចាស់ បង្រៀនពួកគេពីអ្វីដែលជាប្រយោជន៍សំរាប់ជីវិត និងជាប្រយោជន៍សំរាប់ថ្ងៃបរលោក ហើយគ្រប់សកម្មភាពរបស់គាត់ សុទ្ធតែបញ្ជាក់ពីការពិត។ កាតព្វកិច្ចនេះ ទាមទារអោយគាត់ជ្រើសយកស្ត្រីមួយចំនួន ដើម្បីក្រេបយកចំណេះដឹងពីគាត់ ជាទូតនាំសារទៅកាន់ស្ត្រីដូចគ្នា ដើម្បីបង្រៀន បង្ហាញ និងណែនាំផ្លូវដល់ពួកគេ ឆ្ពោះទៅកាន់ត្រើយសុភមង្គលពិតក្នុងគ្រួសារ និងសង្គមទាំងមូល។ ការអំពាវនាវតាមរយៈប្រពន្ធៗរបស់គាត់ ធ្វើឱ្យព្យាការីមូហាំម៉ាត់ មានឥទ្ធិពលចំពោះ

ពួកស្ត្រី ដែលជាចំណែកដ៏សំខាន់នៃសង្គម។ ជាពិសេស មានស្ត្រីជាច្រើននាំគ្នាមកផ្ទះរបស់គាត់ ក្នុងគោលបំណងដើម្បីក្រេបយកចំណេះដឹង សួរគាត់ និង សួរប្រពន្ធរបស់គាត់ ពីរឿងរ៉ាវសាសនា និងបញ្ហាការរស់នៅប្រចាំថ្ងៃ។

នៅមានមូលហេតុសំខាន់ៗផ្សេងទៀត ដែលនាំអោយគាត់យកប្រពន្ធច្រើន ក្នុងនោះ ដោយសារបុព្វហេតុសាសនា សង្គម និងនយោបាយ ដែលនឹងធ្វើការសង្ខេបជូនដូចតទៅ:

ទី១-ដើម្បីបង្រៀនមនុស្សលោកឱ្យយល់ពីឥស្លាម និងយល់ពីការអំពាវនាវរបស់គាត់ ដោយលំអិតពីខ្លឹមសារ លក្ខណៈពិសេស និងចំណុចផ្សេងៗទៀត ទាក់ទងនឹងរបៀបគោរពសក្ការៈដែលជាកាតព្វកិច្ច។ ដូច្នេះ ចាំបាច់ត្រូវមានអ្នករស់នៅក្នុងផ្ទះជាមួយគាត់ ដើម្បីពាំនាំសេចក្តីលំអិតទាំងនោះមកបង្រៀនមនុស្ស ដែលអាចប្រព្រឹត្តទៅបានតាមរយៈអ្នកដែលជិតស្និទ្ធជាងគេ គឺពួកប្រពន្ធៗរបស់គាត់នេះឯង។ ឧទាហរណ៍ដូចជា ប្រពន្ធរបស់គាត់អាអុីសះ (**عائِشَة**) មានសមត្ថភាពខ្ពង់ខ្ពស់ក្នុងការក្រេបយកចំណេះដឹង ទន្ទេញពាក្យសំដី និងប្រសាសន៍របស់គាត់ ហើយជាស្ត្រីដែលមានចំណេះដឹងខ្ពង់ខ្ពស់ជាងគេខាងផ្នែកហ្វារទូ និងស៊ូណិត។ គាត់នៅរស់ ក្រោយពីព្យាការីមូហាំម៉ាត់បានស្លាប់ រយៈកាល៤២ឆ្នាំ ហើយបានជួយផ្សព្វផ្សាយចំណេះដឹងរបស់ព្យាការីមូហាំម៉ាត់។ ប្រសាសន៍របស់ព្យាការីសរុបទាំងអស់ចំនួនបីពាន់ដែលប្រពន្ធៗរបស់គាត់បានទន្ទេញចាំ ទាក់ទង

នឹងប្រធានបទផ្សេងៗ ហើយមានប្រសិទ្ធិភាពបំផុតក្នុងការស្វែងយល់ពីសាសនាឥស្លាម។

ទី២- ដើម្បីពង្រឹង និងរឹតចំណងទាក់ទងរវាងពួកសហការីដែលនាំមកនូវសាមគ្គីភាព និងមេត្រីភាពក្នុងសង្គម ។ ដូច្នេះ គាត់បានរៀបការជាមួយកូនស្រីអាពូហ្គាកើរ និងកូនស្រីរបស់អ៊ូមើរ ហើយគាត់បានការកូនស្រីគាត់ទាំងពីរអោយទៅអូស្មាន និងការកូនស្រីទីបីរបស់គាត់អោយទៅអាលី។

ទី៣- ដើម្បីឱ្យច្បាប់ឥស្លាមមានសុពលភាព ត្រូវបានគេអនុវត្ត និងប្រតិបត្តិជាក់ស្តែងនៅចំពោះមនុស្សទូទៅ ទើបព្យាការីមូហាំម៉ាត់គាត់អនុវត្តដោយផ្ទាល់នូវនីតិបញ្ញត្តិឥស្លាម ដើម្បីជាគំរូដល់អ្នកឥស្លាមជំនាន់ក្រោយ ទោះ ក្នុងន័យផ្តល់កិត្តិយសដល់ស្ត្រីមេម៉ាយ ដូចគាត់បានរៀបការជាមួយ (សាវហ្ទះ អ៊ុំសាឡាម៉ះ និងអ៊ុំហាពីហ្គះ) ឬក្នុងន័យមេត្តាដល់អ្នកដែលទើបចូលឥស្លាម ដូចជាគាត់បានរៀបការជាមួយសហ្វីយ៉ះ(صَفِيَّة) បន្ទាប់ពីឪពុករបស់នាង ជាបុគ្គលមានមុខមានមាត់បានចូលឥស្លាម។ គាត់ធ្វើនេះ ដើម្បីផ្តល់កិត្តិយសដល់ឪពុកនាងនៅចំពោះមុខពួកអ្នកដែលតាមព្យាបាទពួកគេ។

ទី៤- ដើម្បីភ្ជាប់ទំនាក់ទំនង និងចងមេត្រីភាពជាមួយប្រទេសផ្សេងៗ។ ដូចជា គាត់បានរៀបការជាមួយនាងម៉ារីយ៉ះ(مارِيَّا)ជនជាតិអេហ្សិប ដើម្បីពង្រឹងចំណងទាក់ទងជាមួយមហាប្រទេសដ៏ធំនេះ ហើយគាត់បានរៀបការជាមួយជូវ៉ៃរីយ៉ះ (جُوَيْرِيَّة) ដើម្បីទាក់ទាញឱ្យកុលសម្ព័ន្ធរបស់នាង ហ្គានូអាល់មុសតាឡឹក (بَنو المُصْطَلَق) ចូល

សាសនាឥស្លាម បន្ទាប់ពី ពួកគេបានក្លាយជាចំណាប់ខ្មាំងរបស់ព្យាការីមូហាំម៉ាត់ ក្រោយពេល ចម្បាំងនៅឯកុលសម្ព័ន្ធ ហ្គានូអាល់មុសតាឡឹក(بَنو المُصْطَلَق)។

***

ភាតព្វកិច្ចអ្នកមានជំនឿចំពោះប្រពន្ធៗរបស់គាត់

គោលគ្រឹះឥស្លាម និងគោលសំខាន់នៃជំនឿ គឺជឿជាក់ថាប្រពន្ធរបស់គាត់ទាំងអស់ជាមាតានៃពួកអ្នកមានជំនឿ ហើយពួកគេក៏ជាប្រពន្ធរបស់គាត់នាថ្ងៃបរលោក។ ដូចអល់ឡោះបានបន្ទូលថា:

﴿ ٱلنَّبِيُّ أَوۡلَىٰ بِٱلۡمُؤۡمِنِينَ مِنۡ أَنفُسِهِمۡۖ وَأَزۡوَٰجُهُۥٓ أُمَّهَٰتُهُمۡ ﴾سورة الأحزاب / الآية : ٦

មានន័យថា: (ព្យាការីមូហាំម៉ាត់ជិតដិតបំផុត និងជាទីស្រលាញ់ចំពោះពួកអ្នកមានជំនឿខ្លាំងក្លាជាងខ្លួនពួកគេផ្ទាល់ ហើយប្រពន្ធៗរបស់គាត់ជាមាតារបស់ពួកគេ)។ ចាំបាច់ត្រូវជូនពរចំពោះប្រពន្ធរបស់គាត់ អោយអល់ឡោះជាម្ចាស់សព្វព្រះទ័យ និងមេត្តាចំពោះពួកគេ ហើយលើកតំកើងពួកគេឱ្យស្អាតស្អំពីគុណវិបត្តិទាំងឡាយ ពុំត្រូវប៉ះពាល់ ប្រមាថដល់កិត្តិយស កេរ្តិ៍ឈ្មោះរបស់ពួកគេឡើយ។ ដូច្នេះទើបអល់ឡោះជាម្ចាស់បានដាក់ជាកាតព្វកិច្ចលើពួកអ្នកមានជំនឿឱ្យស្រលាញ់ពួកគេ ស្របតាមក្តីស្រលាញ់របស់ព្យាការីមូហាំម៉ាត់ក្នុងនាមគាត់ជាប្តីពួកគេ។ ក្តីស្រលាញ់នេះ ក៏ជាការសក្ការៈចំពោះអល់ឡោះដែលនឹងទទួលបានផលបុណ្យមហាសាល។ នរណាបាត់បង់ក្តីស្រលាញ់នេះ អ្នកនោះ ពិតជាខាតបង់ផលប្រយោជន៍ច្រើន

បំផុត។ ការស្រលាញ់ និងកត្តញ្ញូចំពោះពួកគេ ទុកស្មើនឹងការស្រលាញ់ និងកត្តញ្ញូចំពោះព្យាការីមូហាំម៉ាត់។ នរណាស្អប់ខ្ពើមពួកគេ គឺស្មើនឹងស្អប់ខ្ពើមចំពោះព្យាការីមូហាំម៉ាត់ និងបំពានលើសិទ្ធិរបស់គាត់ ហើយស្មើនឹងការប្រព្រឹត្តអំពើបាបកំរិតធ្ងន់។

***

លក្ខណៈខ្លះនៃរូបសម្បត្តព្យាការីមូហាំម៉ាត់

ព្យាការីមូហាំម៉ាត់មានសម្បុរសឆើត ពុំមែនសស្លេក ហើយចែងចាំងដូចពន្លឺ។ រង្វង់មុខភ្លឺថ្លាដូចរស្មីព្រះអាទិត្យ និងពន្លឺព្រះចន្ទ។ ផ្ទៃមុខស្អាតផូរផង់ហាក់បានរចនាពីប្រាក់ ឬពីគុជ មូលក្រឡង់ ។ ថ្ងាសធំទូលាយ ពេលញែកសក់ចេញ ឬពេលយប់ ឬពេលមកជួបមនុស្សម្នា ភ្លឺដូចចង្កៀងដែលកំពុងចែងចាំងពន្លឺ។ ចិញ្ចើមទាំងគូទ្រង់ក្រាស់ រាងក្រវង់ គល់ចិញ្ចើមមានរោមស្ដើងដុះជាប់គ្នា។ ភ្នែកទាំងគូធំៗ ស្អាត មុតថ្លា ប្រស្រីភ្នែកខ្មៅដូចនីល រោមភ្នែកវែងៗ សរសៃគ្រាប់ភ្នែកឆ្នារៗពណ៌ក្រហមព្រឿង ជាលក្ខណៈពិសេសរបស់គាត់។ ពុកចង្ការក្រាស់ពណ៌ខ្មៅ ប្រវែងមួយក្ដាប់ដៃ គាត់តែងថៃទាំវាជានិច្ច ដោយប្រើគ្រឿងក្រអូប។ គាត់ណែនាំងឱ្យគេកាត់ពុកមាត់ និងទុកពុកចង្ការ។ ទំរង់ក្បាលធំ សក់ខ្មៅ មិនរួញ មិនត្រង់ស្រលូន តែស្លូតអង្គារជី សក់វែងបំផុតប្រ៉ះស្មា បើសិនគាត់ទុកយូរពុំបានកាត់។ ស្មាទាំងពីរធំទូលាយ ដើមទ្រូងមានសាច់ដុំមាំ។ ដៃទាំងពីរវែងៗ ប្រអប់ដៃ មានសាច់ដុំធំៗ បាតដៃទាំងពីរទន់ល្មើយ។ បើគាត់ចាប់ដៃនរណាម្នាក់ក្លិនដៃរបស់គាត់ជាប់នឹងដៃអ្នកនោះ បើគាត់យកដៃស្ទាបលើក្បាលកូនក្មេង គេដឹងថា ក្មេងនោះ ជាប់ក្លិនរបស់គាត់

ពេញមួយថ្ងៃ។ រីឯកំពស់វិញ មិនខ្ពស់ពេក មិនទាបពេក មធ្យម។ រាងរៅពីមុខពីក្រោយ សមនឹងដងខ្លួន មិនធាត់ពេក មិនស្គមពេក។ បើគាត់អង្គុយក្នុងចំណោមមនុស្ស ស្មាទាំងពីរលេចឡើងជ្រងោ។ រូបសម្បត្តិរបស់គាត់ល្អឯកសមរូប សមរាង គ្មានទាស់ត្រង់ណាឡើយ។

***

អច្ឆរិយៈអមតៈរបស់គាត់ គម្ពីរអាល់គួរអាន

អាល់គួរអានជាបន្ទូលរបស់អល់ឡោះជាអច្ឆរិយៈត្រូវគេសក្ការៈតាមរយៈការសូត្រ និងប្រតិបត្តិតាម។ ពិតប្រាកដ អល់ឡោះជាម្ចាស់បានប្រទានចំពោះព្យាការីមូហាំម៉ាត់ តាមរយៈទេវតាជីព្រីលដែលមានសច្ចៈទៀងត្រង់។ ក្នុងគោលបំណងដើម្បីបង្រៀនមនុស្សលោកឱ្យស្គាល់ព្រះជាម្ចាស់របស់ពួកគេ ជាព្រះបង្កើតពួកគេ ហើយជាការចង្អុលបង្ហាញផ្លូវដល់មនុស្សទាំងមូល ឱ្យទទួលបានសិរីសួស្តីទាំងក្នុងលោកីយ៍ និងបរលោក។ ការមានជំនឿ និងប្រតិបត្តិតាមគម្ពីរអាល់គួរអានជាគោលជំនឿដ៏សំខាន់ ដែលអ្នកឥស្លាមម្នាក់ៗពុំទាន់ មានជំនឿពេញលក្ខណៈ លុះត្រាតែមានជំនឿចំពោះគម្ពីរនេះ។

ពិតប្រាកដ អល់ឡោះជាម្ចាស់បានប្រទានចំពោះគ្រប់ព្យាការីនីមួយៗនូវអច្ឆរិយៈផ្សេងៗ ដើម្បីគាំទ្រ និងជាភស្តុតាងលើសាសន៍របស់ពួកគេ តាមកាលៈទេសៈ និងមជ្ឈដ្ឋានរស់នៅរបស់ពួកគេក្នុងសម័យកាលនីមួយៗ។ អល់ឡោះជាម្ចាស់បានប្រទានចំពោះព្យាការីមូហាំម៉ាត់នូវអច្ឆរិយៈជាច្រើន ហើយអច្ឆរិយៈ ដ៏ឧត្តុង្គឧត្តមជាងគេ គឺ

ការប្រទានគម្ពីរអាល់គួរអានចុះមក ហើយប្រកាសអោយសាសន៍របស់គាត់ដែលជាកវី ពូកែខាងកំណាព្យកាព្យឃ្លោង និងពូកែខាងវោហារសាស្ត្រមកប្រកួតប្រជែង។ លើសពីនេះ ប្រកាសអោយសកលលោកទាំងមូល ទាំងមនុស្ស និងជិនបិសាចមកប្រកួតប្រជែង។ ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿ قُل لَّئِنِ ٱجۡتَمَعَتِ ٱلۡإِنسُ وَٱلۡجِنُّ عَلَىٰٓ أَن يَأۡتُواْ بِمِثۡلِ هَٰذَا ٱلۡقُرۡءَانِ لَا يَأۡتُونَ بِمِثۡلِهِۦ وَلَوۡ كَانَ بَعۡضُهُمۡ لِبَعۡضٖ ظَهِيرٗا ﴿٨٨﴾ ﴾ **سورة الإسراء / الآية: ٨٨**

មានន័យថា: (មូហាំម៉ាត់! ចូរប្រសាសន៍ចុះថា បើសិនជាមនុស្ស និងជិនបិសាចប្រមូលផ្តុំគ្នានិពន្ធអោយដូចគម្ពីរអាល់គួរអាន គឺពួកគេធ្វើមិនកើតជាដាច់ខាត ទោះជាពួកគេជួយជ្រោមជ្រែងគ្នាយ៉ាងណាក៏ដោយ)។

គម្ពីរអាល់គួរអានត្រូវប្រទានចុះមកជាបន្តបន្ទាប់ស្មើនឹងចន្លោះពេលនៃការផ្សព្វផ្សាយរបស់ព្យាការីមានរយៈកាល២៣ឆ្នាំ រហូតដល់បានបញ្ចុះមកចប់សព្វគ្រប់ ពេញលេញមុននឹងគាត់លាចាកលោក។

គម្ពីរអាល់គួរអានមានឈ្មោះដូចតទៅ:

១-អាល់គួរអាន(**القُرْآن**) ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿ إِنَّهُۥ لَقُرۡءَانٞ كَرِيمٞ ﴿٧٧﴾ ﴾ **سورة الواقعة / الآية: ٧٧**

មានន័យថា: (ពិតប្រាកដ ជាគម្ពីរអាល់គួរអានដ៏មហាឧត្តុង្គឧត្តម)។

២-គម្ពីរ ឬអាល់កីតាប(**الكِتَاب**) ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿ ذَٰلِكَ ٱلۡكِتَٰبُ لَا رَيۡبَۛ فِيهِۛ هُدٗى لِّلۡمُتَّقِينَ ﴿٢﴾ ﴾ **سورة البقرة / الآية: ٢**

មានន័យថាៈ (នោះជាគម្ពីរដែលគ្មានភាពមន្ទិលសង្ស័យ ក្នុងនោះជាសេចក្តីចង្អុលបង្ហាញសំរាប់ពួកអ្នកដែលគោរពវិន័យកោតខ្លាច)។

៣-សេចក្តីចង្អុលបង្ហាញ ឬសេចក្តីរំលឹក (**الذِّكْر**) ដូចទ្រង់បានមានព្រះបន្ទូលថាៈ

﴿ إِنَّا نَحْنُ نَزَّلْنَا ٱلذِّكْرَ وَإِنَّا لَهُۥ لَحَٰفِظُونَ ﴿٩﴾ ﴾ **سورة الحجر / الآية: ٩**

មានន័យថាៈ (ពិតប្រាកដ យើងបានប្រទានសេចក្តីរំលឹកចុះមក ហើយយើងជាអ្នកអភិរក្សសេចក្តីរំលឹកនេះអោយនៅគង់វង្សរហូត)។

៤-សេចក្តីវែកញែក ឬអាល់ហ្វូរកន (**الفُرْقان**) ដូចទ្រង់មានព្រះបន្ទូលៈ

﴿ تَبَارَكَ ٱلَّذِى نَزَّلَ ٱلْفُرْقَانَ عَلَىٰ عَبْدِهِۦ لِيَكُونَ لِلْعَٰلَمِينَ نَذِيرًا ﴿١﴾ ﴾ **سورة الفرقان / الآية: ١**

មានន័យថាៈ (ពរជ័យរបស់ទ្រង់ដ៏ឧត្តម ប្រយោជន៍របស់ទ្រង់ដ៏ច្រើនលើសលប់ និងព្រះលក្ខណៈរបស់ទ្រង់ដ៏សុក្រឹតនោះ គឺទ្រង់បានប្រទានគម្ពីរអាល់គួរអាន ដែលវែកញែករកខុសត្រូវ ចំពោះខ្ញុំបម្រើរបស់ទ្រង់ ព្យាការីមូហាំម៉ាត់ ដើម្បីតែងតាំងគេជាអ្នកនាំសារមកកាន់មនុស្ស និងជិន″បង់បត់ ឬបិសាច″ ហើយដាស់តឿនពួកគេអោយប្រុងប្រយ័ត្នពីទារុណកម្មរបស់ទ្រង់)។

៥-ពន្លឺ ឬអ័ណនូរ(**النُّور**) ដូចទ្រង់បានមានព្រះបន្ទូលថាៈ

﴿ فَـَٔامِنُوا۟ بِٱللَّهِ وَرَسُولِهِۦ وَٱلنُّورِ ٱلَّذِىٓ أَنزَلْنَا ۚ وَٱللَّهُ بِمَا تَعْمَلُونَ خَبِيرٌ ﴿٨﴾ ﴾ **سورة التغابن / الآية: ٨**

មានន័យថាៈ (ចូរពួកអ្នកមានជំនឿចុះចំពោះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ និងមានជំនឿចំពោះពន្លឺដែលព្រះបានប្រទានចុះមក ហើយអល់ឡោះទ្រង់ដឹងល្អិតល្អន់ពីអ្វីដែលពួកអ្នកធ្វើ)។

ពិតប្រាកដ អាល់គួរអាន ទាំងសំណួរ និងអត្ថន័យ គឺជាបន្ទូលរបស់អល់ឡោះ។ ជាមាគ៌ាប្រទានចុះពីលើមេឃមានប្រសិទ្ធិភាពសំរាប់មនុស្សជាតិទូទៅ។ ជាប្រភពឯកសារទីមួយពាក់ព័ន្ធនឹងរឿងរ៉ាវសាសនា។ អាល់គួរអានជាអាជ្ញាកណ្តាល ដែលពួកគេនាំគ្នាទៅរកការវិនិច្ឆ័យ។ ក្បួនច្បាប់ដែលមានចែងក្នុងអាល់គួរអានពុំមែនបញ្ចុះមកម្តងទាំងអស់នោះទេ តែត្រូវប្រទានចុះមកតាមលំដាប់ ក្នុងចន្លោះពេលទទួលសារពីព្រះជាម្ចាស់។ មានព្រះបន្ទូលខ្លះ ពង្រឹងពីគោលជំហរ និងស្មារតីរបស់ព្យាការីមូហាំម៉ាត់ ហើយព្រះបន្ទូលខ្លះ ដើម្បីអប់រំបណ្តុះបណ្តាលប្រជាជាតិឥស្លាម ដែលទើបនឹងចាប់កំណើតទាំងខាងចំណេះដឹង និងការអនុវត្ត។ ព្រះបន្ទូលខ្លះទៀត ប្រទានចុះមក នៅរាល់ពេលដែលមានហេតុការណ៍ កើតឡើងជាក់ស្តែងក្នុងជីវិតប្រចាំថ្ងៃរបស់ពួកអ្នកឥស្លាមតាមពេលវេលា សម័យកាលខុសៗគ្នា។ រាល់ពេលមានហេតុការណ៍ ឬបាតុភូតកើតឡើង គេប្រទានព្រះបន្ទូលចុះមកស្របទៅតាមនោះ ហើយបកស្រាយពីវិធានការច្បាប់របស់អល់ឡោះចំពោះហេតុការណ៍ទាំងនោះតាមតំរូវការសង្គមអ្នកឥស្លាមនាសម័យកាលនោះ។

គម្ពីរអាល់គួរអានមានលក្ខណៈពិសេសសំខាន់ៗចំនួនបីគឺ:

<u>**លក្ខណៈពិសេសទី១**</u>-ការអភិរក្ស មានន័យថា គម្ពីរអាល់គួរអានត្រូវអភិរក្សពីការកែប្រែ ផ្លាស់ប្តូរ ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿ إِنَّا نَحْنُ نَزَّلْنَا ٱلذِّكْرَ وَإِنَّا لَهُۥ لَحَٰفِظُونَ ٩ ﴾ **سورة الحجر / الآية: ٩**

មានន័យថាៈ (ពិតប្រាកដ យើងបានប្រទានសេចក្តីរំលឹកចុះមក ហើយយើងជាអ្នកអភិរក្សសេចក្តីរំលឹកនេះអោយនៅគង់វង្ស)។

ហេតុដូច្នេះ ទើបអល់ឡោះជាម្ចាស់បានចាត់ចែងសំរាប់អាល់គួរអានតាំងពីទ្រង់បានប្រទានចុះមក មានអ្នកអភិរក្សដោយការទន្ទេញចាំ ការកត់ត្រា ទាំងពួកសហាការី និងអ្នកជំនាន់ក្រោយ។ ការយកចិត្តទុកដាក់របស់អ្នកឥស្លាមចំពោះគម្ពីរអាល់គួរអាន ការកត់ត្រា ការចងក្រង ការទន្ទេញ និងការត្រួតពិនិត្យអក្ខរាវិរុទ្ធ មានកំរិតខ្ពស់បំផុតដែលគ្មានពាក្យអ្វីអធិប្បាយអោយសក្តិសមនឹងការយកចិត្តទុកដាក់របស់ពួកគេឡើយ។ គ្រប់តួរអក្សរ ពាក្យពេចន៍អាល់គួរអានត្រឹមត្រូវឥតខ្ចោះ នៅគង់វង្សរហូត គ្មានការកែប្រែឡើយ។

<u>**លក្ខណៈពិសេសទី២**</u>-គ្រោបលើខ្លឹមសាររួម និងសុក្រឹត។ ដូចទ្រង់បានមានព្រះបន្ទូលបញ្ជាក់ថាៈ

﴿ وَنَزَّلۡنَا عَلَيۡكَ ٱلۡكِتَٰبَ تِبۡيَٰنٗا لِّكُلِّ شَيۡءٖ وَهُدٗى وَرَحۡمَةٗ وَبُشۡرَىٰ لِلۡمُسۡلِمِينَ ٨٩ ﴾

سورة النحل / الآية : ٨٩

មានន័យថាៈ (ហើយយើងបានប្រទានគម្ពីរមកចំពោះអ្នកជាសេចក្តីបកស្រាយសំរាប់អ្វីគ្រប់យ៉ាង ជាសេចក្តីចង្អុលបង្ហាញ ជាក្តីមេត្តា និងជាដំណឹងល្អសំរាប់ពួកអ្នកឥស្លាម)។

គ្មានកិច្ចការរឿងរ៉ាវអ្វីដែលមនុស្សត្រូវការទាំងកិច្ចការសាសនា និងបញ្ហាលោកីយ៍ លើកលែងតែមានបកស្រាយយ៉ាងច្បាស់នៅក្នុងគម្ពីរអាល់គួរអាន ទោះដោយការចែងច្បាប់ ឬបង្កប់ក្នុងទ្រឹស្តីគោលទូទៅមួយ ដែលអល់ឡោះទ្រង់ពន្យល់បកស្រាយក្នុងគម្ពីររបស់ទ្រង់ដ៏

ឧត្តម ឬជាសេចក្តីយោងទៅលើប្រភពផ្សេងៗ ដូចជាយោងទៅលើលំអានរបស់ណាពី (**السُنَّة النَّبَوِيّة**) ឬធ្វើនីតិកម្មដោយសំអាងលើហេតុផលសមស្រប (**القِياسُ الصَّحيح**) ឬជាមតិឯកភាពរបស់ពួកសាសនវិទូឥស្លាម។ គ្មានបញ្ហាអ្វីមួយ ដែលអ្នកឥស្លាមត្រូវការ ពាក់ព័ន្ធនឹងសីលធម៌ ចរិយាធម៌ ជំនឿ សេដ្ឋកិច្ច នយោបាយ បញ្ហាបុគ្គលឬសង្គម ទាំងផ្នែកលោកីយ៍ និងបរលោក លើកលែងតែមានការបកស្រាយជារួម ឬពិស្តារក្នុងគម្ពីរអាល់គួរអាន។ លើសពីនេះ គម្ពីរអាល់គួរអានបានចែងផងដែរពីឫសគល់នៃបញ្ហាផ្សេងៗ ខ្លះទាក់ទងនឹងគោលជំនឿ ខ្លះទៀតពាក់ព័ន្ធនឹងគោលការណ៍ច្បាប់។ ដូច្នេះ អាល់គួរអានពិតជាគម្ពីរដែលក្តោបលើខ្លឹមសាររួម ហើយសុក្រឹត មានចែងអំពីរឿងរ៉ាវគ្រប់បែបយ៉ាងក្នុងជីវិត។

<u>លក្ខណៈពិសេសទី៣</u>-ជាគម្ពីរពិតឥតក្លែងក្លាយ អាល់គួរអានជាគម្ពីរគ្មានអ្វីគួរអោយសង្ស័យឡើយ។ ដូចទ្រង់បានមានព្រះបន្ទូលថាៈ

﴿ ذَٰلِكَ ٱلۡكِتَٰبُ لَا رَيۡبَۛ فِيهِۛ هُدٗى لِّلۡمُتَّقِينَ ٢ ﴾ **سورة البقرة / الآية : ٢**

មានន័យថាៈ (នោះជាគម្ពីរដែលគ្មានភាពមន្ទិលសង្ស័យ ក្នុងនោះជាសេចក្តីចង្អុលបង្ហាញសំរាប់ពួកអ្នកដែលគោរពវិន័យកោតខ្លាច)។

អាល់គួរអានជាគម្ពីរពិតឥតក្លែងក្លាយ ជាគម្ពីរដែលគួរអោយជឿទុកចិត្ត ពិតទាំងដំណឹងពីអតីតៈ បច្ចុប្បន្ន ឬអនាគត។ ដំណឹងអាល់គួរអានពុំមានការខ្វែង ឬផ្ទុយជាដាច់ខាតជាមួយនឹងការពិតជាក់ស្តែង ឬជាមួយនឹងប្រវត្តិសាស្រ្តសម័យដើម ឬជាមួយនឹងអ្វីដែលជារបកកំហើញផ្នែកវិទ្យាសាស្រ្តនាពេលអនាគត។ ពួកអ្នកមានជំនឿត្រូវ

បង្គាប់ឱ្យមានការជឿជាក់ចំពោះអ្វី ដែលមានចែងក្នុងគម្ពីរអាល់គួរអានពីប្រជាជាតិសម័យបុរាណ ពីដំណឹងពួកកព្យាការី មនុស្សជាតិស្រុកទេស រឿងនិទាន ដំណឹងជាក់ស្តែងក្នុងសង្គម ក្នុងភព គន្លងផ្កាយ ផែនដី មេឃ នៅក្នុងស្បូនស្ត្រី និងក្នុងខ្លួនមនុស្ស។ លើសពីនេះ ព្រះជាម្ចាស់ទ្រង់បានបន្ទូលប្រាប់ផងដែរក្នុងគម្ពីរអាល់គួរអានពីដំណឹងអនាគតកាលនៃទីអវសានរបស់លោកីយ៍ ឬនៅថ្ងៃបរលោក ជាសេចក្តីពិត ជាក់ស្តែង ពុំត្រូវស្ទាក់ស្ទើរក្នុងចិត្ត។ ពីព្រោះ ព្រះដែលបានប្រទានគម្ពីរអាល់គួរអានចុះមក ទ្រង់ជាអ្នកបង្កើតភពទាំងឡាយ និងបានបង្កើតមនុស្ស។ ដូច្នេះ ព្រះដែលជាអ្នកបង្កើត ទ្រង់មិនបន្ទូលប្រាប់ពីមនុស្ស និងភពទាំងឡាយ លើកលែងតែអ្វីនោះជាការពិតជាក់ស្តែង។ ដូចទ្រង់បានបន្ទូលបញ្ជាក់ថា:

﴿ أَلَا يَعْلَمُ مَنْ خَلَقَ وَهُوَ ٱللَّطِيفُ ٱلْخَبِيرُ ١٤ ﴾ سورة الملك / الآية : ١٤

មានន័យថា: (ព្រះជាម្ចាស់នៃសកលលោក ហើយទ្រង់ជាអ្នកបង្កើតពួកគេយ៉ាងសុក្រឹត និងល្អឥតខ្ចោះ តើទ្រង់មិនអាចជ្រាបពីរឿងសត្វលោក និងកិច្ចការរបស់ពួកគេទេឬ? ទ្រង់ពិតជាដឹងយ៉ាងល្អិតល្អន់ពីមនុស្សលោក និងក្តាប់ជុំនូវទង្វើរបស់ពួកគេ)។ ទ្រង់បន្ទូលទៀតថា:

﴿ وَتَمَّتْ كَلِمَتُ رَبِّكَ صِدْقًا وَعَدْلًا ۚ لَّا مُبَدِّلَ لِكَلِمَٰتِهِۦ ۚ وَهُوَ ٱلسَّمِيعُ ٱلْعَلِيمُ ١١٥ ﴾

سورة الأنعام / الآية : ١١٥

មានន័យថា: (ពាក្យបន្ទូលព្រះជាម្ចាស់របស់ឯង ពេញលក្ខណ: ប្រកបដោយភាពសច្ច: និងយុត្តិធម៌ គ្មាននរណាអាចផ្លាស់ប្តូរពាក្យ

បន្ទូលរបស់ទ្រង់ដ៏សុក្រឹតនេះឡើយ ហើយព្រះអង្គទ្រង់មហាលឺ មហាដឹង ទោះដោយបើកចំហ ឬលាក់បាំង)។

ជាគម្ពីរដ៏សច្ចៈ រាល់អ្វីដែលព្រះជាម្ចាស់បានបន្ទូលប្រាប់តាំងពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល សុទ្ធតែត្រឹមត្រូវ។ មានភាពយុត្តិធម៌ក្នុងការចែងច្បាប់ ទាំងផ្នែកឯកជន និងសាធារណៈ ទាំងទ្រឹស្តីគោល ឬមែកធាង ជាគម្ពីរពិតឥតក្លែងក្លាយ។

***

ទំនាក់ទំនងបទដ្ឋាន នឹងគម្ពីរអាល់គួរអាន

បទដ្ឋាន(السُّنَّة) ជាការប្រៀនប្រដៅ និងជាការត្រាស់បង្គាប់ទីពីរអំពីអល់ឡោះជាម្ចាស់ចំពោះព្យាការីរបស់ទ្រង់រួមមាន ពាក្យសម្តី និងសកម្មភាព។ ពាក្យសម្តី និងសកម្មភាពទាំងនោះបកស្រាយ បំភ្លឺ និងអធិប្បាយពីអាល់គួរអាន ហើយក៏ជាការអនុវត្តជាក់ស្តែងចំពោះឃ្លាប្រយោគក្នុងគម្ពីរអាល់គួរអានដែលក្តោបលើ កាតព្វកិច្ចសាសនា ការគោរពសក្ការៈ ការបង្គាប់ប្រើ ការប្រារព្ធពិធីផ្សេងៗ ការប្រារព្ធបុណ្យហ័ជ្ជ និងការប្រាស្រ័យទាក់ទងគ្នាតាមបែបឥស្លាម។ ដូច្នេះ ការអនុវត្តជាក់ស្តែងរបស់ព្យាការីមូហាំម៉ាត់ ជាការផ្ទេរពីការប្រៀនប្រដៅ និងការណែនាំទូន្មានក្នុងអាល់គួរអានជាក្បួនដែលចងក្រង ទៅជាការអនុវត្តក្នុងជីវិតពិត និងជាប្រព័ន្ធច្បាប់ដែលត្រូវបានប្រតិបត្តិ និងជាអរិយធម៌រីកចំរើនដែលមានវត្តមានពិតជាក់ស្តែង។ រហូតដល់មនុស្សគ្រប់រូបដឹង និងស្គាល់ច្បាស់ពីសាសនាឥស្លាម និងធាតុពិតនៃឥស្លាម

តាមរយៈការអនុវត្តរបស់ព្យាការីនេះឯង។ ទង្វើរបស់ព្យាការីពុំមែនជាការស្ម័គ្រចិត្ត តែជាការប្រតិបត្តិនូវកាតព្វកិច្ចដែលព្រះបានដាក់ជាបន្ទុកដាច់ខាតលើរូបគាត់។ ព្យាការីគាត់បានប្រតិបត្តិយ៉ាងពេញលក្ខណៈដូចដែលអល់ឡោះជាម្ចាស់ទ្រង់បានបង្គាប់ប្រើ។ ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿وَأَنزَلْنَآ إِلَيْكَ ٱلذِّكْرَ لِتُبَيِّنَ لِلنَّاسِ مَا نُزِّلَ إِلَيْهِمْ وَلَعَلَّهُمْ يَتَفَكَّرُونَ ﴿٤٤﴾ ﴾

سورة النحل / الآية: ٤٤

មានន័យថា: (មូហាំម៉ាត់! យើងបានប្រទានគម្ពីរអាល់គួរអានចុះមកចំពោះឯង ដើម្បីអោយឯងបកស្រាយប្រាប់មនុស្សលោកពីខ្លឹមសារ និងក្បួនច្បាប់ដែលមិនទាន់បានលាតត្រដាង ហើយដើម្បីអោយពួកគេគិតពិចារណា និងទទួលសេចក្តីចង្អុលបង្ហាញពីគម្ពីរនេះ)។

ដូច្នេះ គេចាត់ទុកពាក្យសម្តី ការប្រៀនប្រដៅ និងទង្វើរបស់ព្យាការីមូហាំម៉ាត់ជាការបំពេញបន្ថែមចំពោះអ្វីដែលមានចែងក្នុងគម្ពីរអាល់គួរអាន តែពុំមែនជាការបន្ថែមពីលើគម្ពីរអាល់គួរអានឡើយ។ គ្មានអ្នកឥស្លាមណាម្នាក់មិនត្រូវការបទដ្ឋានរបស់ព្យាការីនោះឡើយ។ ទាំងនេះ ស្របនឹងការទូន្មានរបស់ព្រះជាម្ចាស់ប្រើអោយអ្នកឥស្លាមទាំងឡាយចាំបាច់ត្រូវយកគំរូតាម និងប្រតិបត្តិតាមអ្នកនាំសាររបស់ព្រះអង្គ។ គម្ពីរអាល់គួរអានបានចែងជាច្បាប់ដូចតទៅ:

﴿ قُلْ إِن كُنتُمْ تُحِبُّونَ ٱللَّهَ فَٱتَّبِعُونِى يُحْبِبْكُمُ ٱللَّهُ وَيَغْفِرْ لَكُمْ ذُنُوبَكُمْ ۗ وَٱللَّهُ غَفُورٌ رَّحِيمٌ ﴿٣١﴾ ﴾

سورة آل عمران / الآية: ٣١

មានន័យថា: (មូហាំម៉ាត់! ចូរប្រាប់ពួកគេចុះថា បើពួកអ្នកទាំងអស់គ្នាស្រលាញ់អល់ឡោះជាម្ចាស់ ចូរប្រតិបត្តិតាមខ្ញុំនោះ អល់ឡោះទ្រង់នឹងស្រលាញ់ពួកអ្នក ទ្រង់នឹងអភ័យទោសនូវកំហុសរបស់ពួកអ្នក ហើយអល់ឡោះទ្រង់មហាអភ័យ មហាមេត្តា)។ ទ្រង់បានបន្ទូលថា:

﴿ يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُوٓاْ أَطِيعُواْ ٱللَّهَ وَرَسُولَهُۥ وَلَا تَوَلَّوۡاْ عَنۡهُ وَأَنتُمۡ تَسۡمَعُونَ ٢٠ ﴾

سورة الأنفال/ الآية: ٢٠

មានន័យថា: (ឱពួកអ្នកដែលមានជំនឿទាំងឡាយ ចូរប្រតិបត្តិចុះចំពោះអល់ឡោះជាម្ចាស់ និងអ្នកនាំសាររបស់ព្រះអង្គ ចូរកុំបោះបង់ការប្រតិបត្តិនេះឱ្យសោះ ថ្វីត្បិតពួកអ្នកកំពុងស្តាប់ការទូន្មាន)។

ទ្រង់បានបន្ទូលទៀតថា:

﴿ مَّن يُطِعِ ٱلرَّسُولَ فَقَدۡ أَطَاعَ ٱللَّهَۖ ٨٠ ﴾ **سورة النساء/ الآية: ٨٠**

មានន័យថា: (នរណាប្រតិបត្តិតាមអ្នកនាំសារ អ្នកនោះ ពិតជាបានប្រតិបត្តិតាមអល់ឡោះជាម្ចាស់)។

អល់ឡោះជាម្ចាស់ទ្រង់ពិតជាបានសរសើរ និងលើកតំកើងពីទង្វើរបស់ព្យាការីមូហាំម៉ាត់ និងអ្វីដែលគាត់បានប្រតិបត្តិ ហើយការប្រៀនប្រដៅ និងការទូន្មានរបស់គាត់ចំពោះមនុស្សលោកទាក់ទងនឹងកិច្ចការសាសនា ការរស់នៅ សុទ្ធតែល្អប្រសើរ និងជោគជ័យសំរាប់ពួកគេ។ ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿ يَأۡمُرُهُم بِٱلۡمَعۡرُوفِ وَيَنۡهَىٰهُمۡ عَنِ ٱلۡمُنكَرِ وَيُحِلُّ لَهُمُ ٱلطَّيِّبَٰتِ وَيُحَرِّمُ عَلَيۡهِمُ ٱلۡخَبَٰٓئِثَ وَيَضَعُ عَنۡهُمۡ إِصۡرَهُمۡ وَٱلۡأَغۡلَٰلَ ٱلَّتِي كَانَتۡ عَلَيۡهِمۡۚ فَٱلَّذِينَ ءَامَنُواْ بِهِۦ وَعَزَّرُوهُ وَنَصَرُوهُ وَٱتَّبَعُواْ ٱلنُّورَ ٱلَّذِيٓ أُنزِلَ مَعَهُۥٓ أُوْلَٰٓئِكَ هُمُ ٱلۡمُفۡلِحُونَ ١٥٧ ﴾ **سورة الأعراف/ الآية: ١٥٧**

មានន័យថា: (ព្យាការីមូហាំម៉ាត់ប្រើពួកគេអោយធ្វើល្អ និងហាមឃាត់ពួកគេពីអំពើអាក្រក់ អនុញ្ញាតចំពោះពួកគេនូវទ្រព្យដែលស្របច្បាប់ និងហាមប្រាមលើពួកគេនូវរបស់កខ្វក់ បន្ធូរបន្ថយចំពោះពួកគេនូវបន្ទុក ឬភារកិច្ចដ៏លំបាកទៅលើពួកគេ។ ដូច្នេះ ពួកអ្នកដែលមានជំនឿជឿជាក់ចំពោះព្យាការី បានជួយលើកស្ទួយ និងជួយគាំទ្រគេ ហើយពួកអ្នកប្រតិបត្តិតាមគម្ពីរអាល់គួរអាន និងអនុវត្តតាមបទដ្ឋានរបស់គេ ទាំងនោះ គឺជាពួកអ្នកដែលជោគជ័យ)។

និយាយពីរបៀបនៃការអនុវត្ត បទដ្ឋានរបស់ព្យាការីមូហាំម៉ាត់ មានតួនាទីបី ហើយសុទ្ធតែជាការត្រាស់បង្គាប់ពីអល់ឡោះជាម្ចាស់ចំពោះព្យាការីរបស់ព្រះអង្គ:

១-បញ្ជាក់បន្ថែមពីអ្វីដែលមានចែងក្នុងគម្ពីរអាល់គួរអាន។

២-ស្រាយបំភ្លឺពីអ្វីដែលមានចែងក្នុងគម្ពីរអាល់គួរអាន។

៣-ចែងច្បាប់ដាច់ដោយឡែកបន្ថែមពីលើក្បួនច្បាប់ដែលមានក្នុងគម្ពីរអាល់គួរអាន គឺបង្គាប់ប្រើចំពោះកាតព្វកិច្ចខ្លះ ឬជាច្បាប់ហាមប្រាមដែលពុំមានចែងក្នុងគម្ពីរអាល់គួរអាន។

***

១- មានប្រាជ្ញាឈ្លាសវៃ: ព្យាការីមូហាំម៉ាត់មានប្រាជ្ញាឈ្លាសវៃ ដែលមនុស្សទាំងឡាយពុំមានប្រាជ្ញាដូចគាត់។ គាត់មានគំនិតឈ្លាសវៃក្នុងការរៀបចំ ចាត់ចែងកិច្ចការមនុស្សលោក ទាំងផ្នែកផ្លូវចិត្ត និងផ្លូវកាយ គាត់ចេះដឹកនាំមនុស្សទូទៅ និងដោយចំពោះ ព្រមជាមួយអកប្បកិរិយាដ៏អស្ចារ្យ ចំណេះដឹងជ្រៅជ្រះ ដោយគ្មានការរៀនសូត្រពីមុន ឬឆ្លងកាត់ការអនុវត្ត ឬសិក្សាស្រាវជ្រាវសៀវភៅឯកសារ។ នេះបញ្ជាក់អោយឃើញថា គាត់បានទទួលការថៃរក្សា និងការជ្រើសតាំងពីព្រះជាម្ចាស់ អោយបំពេញកាតព្វកិច្ចមនុស្សជាតិដែលទ្រង់បានបញ្ជូនមក ដើម្បីបង្រៀនមនុស្សលោក។

២-ការអត់ធ្មត់: ព្យាការីមូហាំម៉ាត់ជាចៅហ្វាយនាយនៃពួកអ្នកអត់ធ្មត់ គាត់បានអត់ធ្មត់ចំពោះការបាត់បង់ឪពុកម្តាយ រស់ក្នុងនាមជាកុមារកំព្រា។ ក្រោយពេល ធ្វើការផ្សព្វផ្សាយបើកចំហ គាត់តាំងខ្លួនអត់ធ្មត់តស៊ូចំពោះអ្វីដែលគាត់បានទទួលរងនូវការធ្វើទុក្ខបុកម្នេញគ្រប់ប្រភេទពីសំណាក់ជាតិសាសន៍របស់គាត់។ គាត់ជាគំរូសំរាប់ការអត់ធ្មត់ពេលបាត់បង់អ្នកជាទីស្រលាញ់ គឺប្រពន្ធរបស់គាត់ខទីហ្ជះបានស្លាប់ និងកូនចៅទាំងអស់របស់គាត់ លើកលែងតែហ្វាតីម៉ះដែលនៅរស់ មារបស់គាត់អាពូតាឡិប និងហាំហ្សះ ក៏ស្លាប់ចោលគាត់ ក្នុងស្ថានភាពបែបនេះ គាត់នៅតែអត់ធ្មត់ ហើយរឹងប៉ឹងជានិច្ច។

៣-ចិត្តស្មោះត្រង់: រាល់កិច្ចការរបស់គាត់សុទ្ធតែផុសចេញពីទឹកចិត្ត ស្មោះ ដោយអនុវត្តទៅតាមបង្គាប់របស់អល់ឡោះជាម្ចាស់ ដូចទ្រង់ បានប្រៀនប្រដៅគាត់ថា:

﴿ قُلْ إِنَّ صَلَاتِي وَنُسُكِي وَمَحْيَايَ وَمَمَاتِي لِلَّهِ رَبِّ الْعَالَمِينَ ﴿١٦٢﴾ لَا شَرِيكَ لَهُ وَبِذَٰلِكَ أُمِرْتُ وَأَنَا أَوَّلُ الْمُسْلِمِينَ ﴿١٦٣﴾ ﴾ **سورة الأنعام / الآية: ١٦٢–١٦٣**

មានន័យថា: (មូហាំម៉ាត់! ចូរប្រសាសន៍ចុះថា: ពិតប្រាកដ ការថ្វាយ បង្គំរបស់ខ្ញុំ ការគោរពសក្ការៈរបស់ខ្ញុំ ការរស់រានមានជីវិតរបស់ខ្ញុំ និង ការស្លាប់របស់ខ្ញុំ ស្មោះដើម្បីអល់ឡោះ ជាម្ចាស់នៃសកលលោក។ គ្មានអ្នកចូលហ៊ុនសំរាប់ព្រះអង្គ បែបនេះគេប្រើខ្ញុំអោយប្រតិបត្តិ ហើយខ្ញុំជាអ្នកឥស្លាមមុនដំបូងគេបង្អស់)។

៤-អត្តចរិតល្អ និងមេត្រីភាព: ពេលគេសួរ អំពីអត្តចរិតរបស់ព្យាការី មូហាំម៉ាត់ ប្រពន្ធរបស់គាត់អាអ៊ីសះបាននិយាយថា: (អត្តចរិតរបស់ គាត់គឺគម្ពីរអាល់គួរអាន)។ បានសេចក្តីថា ព្យាការីមូហាំម៉ាត់ ប្រតិបត្តិ នូវរាល់កាតព្វកិច្ចមានចែងក្នុងគម្ពីរអាល់គួរអាន ហើយបញ្ឈប់នូវរាល់ បំរាមទាំងឡាយ។ គាត់អនុវត្ត និងប្រកាន់យកនូវតំលៃ និងភាពឧត្តុង្គ ឧត្តម ហើយបោះបង់ចោលនូវអំពើអាក្រក់ពាលា ទោះដោយកំបាំង ឬបើកចំហ។ ពិតប្រាកដ អល់ឡោះបានពណ៌នាពីលក្ខណៈសម្បត្តិ របស់គាត់ថា:

﴿ وَإِنَّكَ لَعَلَىٰ خُلُقٍ عَظِيمٍ ﴿٤﴾ ﴾ **سورة القلم / الآية: ٤**

មានន័យថា: (ឯងពិតជាបិតលើចរិយាសម្បត្តិដ៏ឧត្តុង្គឧត្តម)។ អាណាស ពិន ម៉ាលិក បានបំរើព្យាការីមូហាំម៉ាត់រយៈកាល១០ឆ្នាំទាំង

យប់ទាំថ្ងៃ ពេលនៅផ្ទះ ពេលធ្វើដំណើរ ហើយតាមរយៈការបំរើនេះ គាត់យល់ពីសុខទុក្ខរបស់ព្យាការី គាត់និយាយថា: (ព្យាការីមូហាំម៉ាត់ ជាមនុស្សដែលមានអត្តចរិតប្រសើរជាងគេបំផុត)។ គាត់បន្តទៀតថា: (ព្យាការីមូហាំម៉ាត់ពុំមែនជាមនុស្សពូកែជេរ ហើយក៏ពុំមែនជាមនុស្សពូកែនិយាយអាសអាភាស ហើយក៏ពុំមែនជាមនុស្សពូកែប្រទេចផ្តាសានោះដែរ)។

<u>**៥-ស្រលាញ់ការផ្សះផ្សារ:**</u> សះលិន ពិន សាក់ទិន បាននិយាយថា: ពួកអ្នកស្រុកគូហ្បាកបានបង្កហិង្សាគប់ដុំថ្មដាក់គ្នា រួចមានគេទៅប្រាប់ព្យាការីមូហាំម៉ាត់ពីបញ្ហានេះ គាត់បានមានប្រសាសន៍ថា: (ចូរនាំពួកយើងទៅ ដើម្បីទៅផ្សះផ្សារពួកគេអោយត្រូវរូវគ្នាឡើងវិញ)។

<u>**៦-ការរក្សាអណ្តាត:**</u> អាប់ឌុលឡោះ ពិន អាពីអាវហ្វាបាននិយាយថា: (ព្យាការីមូហាំម៉ាត់គាត់ច្រើនសូត្រធម៌រំលឹកព្រះ ហើយគាត់ស្អប់ការនិយាយលេងឥតបានការ គាត់ថ្វាយបង្គំយូរ គាត់ទេសនាតិច គាត់មិនដែលមើលងាយចំពោះការរួមដំណើរជាមួយស្ត្រីមេម៉ាយ ឬអ្នកទីទ័លក្រ គាត់តែងជួយបំពេញតំរូវការរបស់ពួកគេ)។

<u>**៧-ចំរើនការគោរពសក្ការ:**</u> អាអ៊ីសះប្រពន្ធរបស់គាត់បាននិយាយថា: ពិតប្រាកដ ព្យាការីមូហាំម៉ាត់គាត់ឈរថ្វាយបង្គំពេលយប់រហូតប្រេះបាតជើងទាំងពីរ។ អាអ៊ីសះនិយាយថា នៃអ្នកនាំសាររបស់ព្រះ! ហេតុអ្វីចាំបាច់ធ្វើបែបនេះ ព្រោះអល់ឡោះជាម្ចាស់ទ្រង់បានអភ័យទោសអោយ នូវកំហុសមុន និងក្រោយ? គាត់បានតបវិញថា: (តើខ្ញុំមិនពេញចិត្តនឹងក្លាយជាខ្ញុំរបស់ព្រះដែលដឹងគុណទេមែនទេ?)។

៨-ការអត់អោន និងភាពទន់ភ្លន់: អាពូហ៊ុរ៉យរ៉ោះបាននិយាយថា: តូហ្វៃល ពិន អាំរូ អ័តហ្វាវសីយ៍ និងក្រុមរបស់គេបានមកជួបព្យាការី មូហាំម៉ាត់ ហើយប្តឹងគាត់ថា: (ពិតប្រាកដ កុលសម្ព័ន្ធហ្វាវស៍បាន ប្រឆាំងជំទាស់ និងបដិសេធ ដូច្នេះ ចូរសុំពីអល់ឡោះអោយទ្រង់បង្ក វិនាសកម្មដល់ពួកគេ។ អ្នកខ្លះនិយាយថា សុំអោយកុលសម្ព័ន្ធហ្វាវស៍ វិនាសចុះ! ឯព្យាការីមូហាំម៉ាត់គាត់បានសុំថា: (ឱអល់ឡោះជាម្ចាស់! សូមទ្រង់ចង្អុលបង្ហាញផ្លូវដល់កុលសម្ព័ន្ធហ្វាវស៍ផង!)។ គាត់ពុំបាន បួងសួងសុំអោយពួកគេវិនាស គឺគាត់សុំបួងសួងអោយពួកគេទទួល បាននូវសេចក្តីចង្អុលបង្ហាញ។

៩-លះបង់ប្រយោជន៍លោកីយ៍: អាប់ឌុលឡោះ ពិន ម៉ាស្អ៊ូតបាន និយាយថា: ព្យាការីមូហាំម៉ាត់គេងលើកន្ទេល ពេលក្រោកពីដំណេក មានស្នាមកន្ទេលជាប់នឹងខ្លួនរបស់គាត់។ ពួកយើងនិយាយថា: នែ អ្នកនាំសាររបស់ព្រះ យើងខ្ញុំគួរតែក្រាលកំរាលអោយលោក! គាត់ និយាយថា: ខ្ញុំគ្មានបេតីចំពោះលោកីយ៍ ហើយលោកីយ៍គ្មានអ្វីគួរឱ្យខ្ញុំ បេតីដែរ ខ្ញុំនៅលោកីយ៍គ្មានប្រៀបបាននឹងអ្វីក្រៅពីអ្នកជិះសេះ ជ្រក សំរាកក្រោមម្លប់ឈើ រួចក៏ចាកចេញ និងបោះបង់ម្លប់នោះចោល)។ អាំរូ ពិន អាល់ហារិស និយាយថា: (ព្យាការីមូហាំម៉ាត់ពុំបានបន្សល់ នៅពេលគាត់លាចាកលោកនេះ នូវប្រាក់មួយកាក់ មួយសេន ហើយ គ្មានបន្សល់អ្នកបំរើប្រុស ឬស្រី គ្មានបន្សល់អ្វីទាំងអស់ក្រៅពី សេះ ទេសមួយក្បាល ដាវមួយដើម និងដីមួយក្បាលដាក់ជាទេយ្យទាន)។

<u>១០-ពេញចិត្តចង់អោយអ្នកដទៃបានល្អ:</u> សះលិន កូន សាក់ទិន បាននិយាយថា: ស្ត្រីម្នាក់បានយកអាវជាយមកជូនគាត់ គាត់សួរថា តើពួកអ្នកដឹងទេ អាវជាយជាអ្វី? មានគេឆ្លើយថា: គឺអាវបំពង់វែងមានប៉ាក់ជាយ។ ស្ត្រីនោះនិយាយថា ឱអ្នកនាំសាររបស់ព្រះ ខ្ញុំបានប៉ាក់អាវនេះដោយផ្ទាល់ដៃទុកជូនលោក។ គាត់បានទទួលយក ព្រោះគាត់ត្រូវការអាវនោះ។ គាត់បានពាក់អាវនោះមកជួបពួកយើង។ មានបុរសម្នាក់ក្នុងក្រុមបាននិយាយថា: ឱអ្នកនាំសាររបស់ព្រះ ខ្ញុំសុំអាវហ្នឹងពាក់វិញ! គាត់ឆ្លើយថា: បាន! គាត់បានអង្គុយមួយស្របក់ រួចត្រឡប់ទៅវិញ គាត់បានបត់អាវយកមកផ្ញើអោយបុរសនោះ។ ក្រុមនោះបាននិយាយទៅបុរសនោះថា: ឯងមិនគួរសុំពីគាត់សោះ ឯងដឹងហើយថាគាត់ពុំដែលបដិសេធចំពោះអ្នកដែលសុំគាត់នោះទេ។ បុរសនោះនិយាយថា: ខ្ញុំមិនសុំយកធ្វើអ្វីក្រៅពីទុករុំសពរបស់ខ្ញុំ ពេលខ្ញុំស្លាប់។ សះលិននិយាយថា អាវនោះពិតជាក្រណាត់រុំសពរបស់បុរសនោះមែន ពេលគេស្លាប់។

<u>១១-មានជំនឿ និងជឿទុកចិត្តខ្លាំងបំផុតចំពោះព្រះ</u> អាពូបាក្កើរ បាននិយាយរៀបរាប់ពីដំណើរគៀសខ្លួនទៅកាន់ម៉ាឌីណះ ខណៈពេលដែលកំពុងនៅក្នុងរូងភ្នំជាមួយព្យាការីមូហាំម៉ាត់ ក្រោយពេលរត់គេចខ្លួនពីពួកអ្នកមានជំនឿលើពហុទេព គាត់បាននិយាយថា: (យើងមើលឃើញចុងជើងពួកគេនៅពីលើក្បាលពួកយើង ខណៈដែលយើងពួននៅក្នុងរូងភ្នំ។ ខ្ញុំនិយាយថា: ឱអ្នកនាំសាររបស់ព្រះ! បើមាននរណាម្នាក់ក្នុងចំណោមពួកគេសំឡឹងមើលចុងជើងរបស់វានោះ វានឹងឃើញ

យើងនៅក្រោមបាតជើងវា។ គាត់តបវិញថា: នែអាពូហ្គាកើរ អ្វីដែលឯងគិតថា មានគ្នាតែពីរនាក់ គឺអល់ឡោះជាអ្នកទីបី)។

<u>១២-ចិត្តមេត្តាករុណា:</u> អាពីកតាហ្ទះបាននិយាយថា: (ព្យាការីមូហាំម៉ាត់បានចេញមកជួបពួកយើង ហើយគាត់ពរអូម៉ាម៉ះ កូន អាពិលអើស្ទដាក់លើស្មារបស់គាត់ គាត់ក៏ឈរថ្វាយបង្គំ ពេលគាត់អោន គាត់ដាក់ក្មេងនោះចុះក្រោម ពេលគាត់ងើប គាត់ពរក្មេងនោះវិញ)។

<u>១៣-ការសំរួលអោយងាយ:</u> អាណាស បាននិយាយថា: ព្យាការីមូហាំម៉ាត់គាត់បានមានប្រសាសន៍ថា: (ពិតប្រាកដ ខ្ញុំចាប់ផ្តើមថ្វាយបង្គំ ខ្ញុំមានបំណងចង់ថ្វាយបង្គំយូរ តែខ្ញុំលឺក្មេងយំ ខ្ញុំក៏បានបន្ថយការថ្វាយបង្គំទៅតាមអ្វីដែលខ្ញុំដឹងពីទុក្ខលំបាករបស់ម្តាយដែលមានកូនយំ)។

<u>១៤- ការគោរពវិន័យសាសនា និងភាពខ្ជាប់ខ្ជួន:</u> អាពូហ៊ូរ៉យរោះបាននិយាយថា ព្យាការីមូហាំម៉ាត់បានមានប្រសាសន៍ថា: (ខ្ញុំបានត្រឡប់ទៅផ្ទះ ហើយឃើញផ្លែល្មើមួយគ្រាប់ជ្រុះនៅលើកន្ទេល ខ្ញុំប្រុងរើសវាយកមកហូប តែខ្លាចក្រែងជាទ្រព្យទេយ្យទាន ទើបខ្ញុំយកវាទុកវិញ)។ ពីព្រោះ គេពុំអនុញ្ញាតអោយគាត់ហូបទ្រព្យទេយ្យទាននោះទេ ។

<u>១៥-ចូលចិត្តជួយសហការគ្នា:</u> អាអ៊ីសះប្រពន្ធរបស់គាត់បានឆ្លើយប្រាប់ ពេលគេសួរគាត់ថា: (តើព្យាការីមូហាំម៉ាត់ គាត់ធ្វើអ្វីនៅផ្ទះ? គាត់តបវិញថា: គាត់តែងជួយការងារគ្រួសសារ ពេលដល់ម៉ោងថ្វាយបង្គំ គាត់ចេញទៅថ្វាយបង្គំ)។ អាល់ហ្គារ៉ក ពិន អាហ្សិប បាននិយាយថា: (ខ្ញុំបានឃើញព្យាការីមូហាំម៉ាត់នៅថ្ងៃជីកព្រែក គឺគាត់បានជញ្ជូនអាចម៍ដីរហូតដល់ធុលីប្រឡាក់សក់ និងខ្លួនរបស់គាត់)។

១៦-សច្ចៈទៀងត្រង់: អាអ៊ីសះ ប្រពន្ធគាត់ បាននិយាយថាៈ (គ្មានចរិតណាគួរអោយស្អប់ចំពោះគាត់ខ្លាំងជាងការភូតកុហក បើមាននរណាម្នាក់និយាយកុហកគាត់ គាត់នៅស្អប់អ្នកនោះក្នុងចិត្ត រហូតដល់គាត់ដឹងថា អ្នកនោះព្រមសារភាពកំហុស ទើបគាត់លែងស្អប់)។

១៧-ទឹកមុខញញឹមរាក់ទាក់: អាប់ឌុលឡោះ ពិន អាល់ហារិសបាននិយាយថាៈ (ខ្ញុំមិនដែលឃើញនរណាញញឹមរួសរាយរាក់ទាក់ច្រើនជាងព្យាការីមូហាំម៉ាត់)។

១៨- ស្មោះត្រង់ និងគោរពពាក្យសន្យាៈ ភាពស្មោះត្រង់របស់គាត់មានតែមួយគ្មានគូប្រៀប។ ពួកអ្នកស្រុកម៉ឹក្កះដែលប្រឆាំងជាសត្រូវ នៅពេលគាត់ផ្សព្វផ្សាយសាសនាបើកចំហ ហើយបានធ្វើទុក្ខបុកម្នេញតាមព្យាបាទគាត់ ព្រមទាំងពួកអ្នកដើរតាមគាត់។ បើទោះជា មានការចងសត្រូវនឹងគ្នាក៏ដោយ ក៏ពួកគេនៅតែយករបស់ ឬឥវ៉ាន់មកផ្ញើទុកជាមួយគាត់។ ដល់ថ្នាក់ ពេលគាត់ចង់ភៀសខ្លួនទៅម៉ាឌីណះ បន្ទាប់ពីគាត់ទទួលរងនូវការបៀតបៀនគ្រប់ប្រភេទ គាត់ក៏បានប្រើអោយប្អូនជីដូនមួយរបស់គាត់ អាលី ពិន អាពីតាឡិប ពន្យារការភៀសខ្លួនចំនួនបីថ្ងៃ ដើម្បីចាំយកបញ្ញើដែលគេផ្ញើជាមួយគាត់ សងទៅម្ចាស់ដើមគេវិញ។

១៩- ក្លាហាន មិនរារែកៈ អាលីគាត់បាននិយាយថាៈ (ពិតប្រាកដ ខ្ញុំបង្ហាញពីសភាពរបស់ពួកយើងនៅថ្ងៃចម្បាំងហ្គាទើរ ពួកយើងរត់ទៅអែបនឹងព្យាការីមូហាំម៉ាត់ ហើយគាត់នៅជិតសត្រូវជាងពួកយើង គាត់ជាមនុស្សក្លាហានជាងគេនាថ្ងៃនោះ)។

២០-ចិត្តសប្បុរស ចិត្តទូលាយ: អិពិន អាប្ពាសនិយាយថា: (ព្យាការីមូហាំម៉ាត់ មានចិត្តសប្បុរសជាងគេ ហើយសប្បុរសខ្លាំងបំផុតនៅខែបួស ខណ:ដែលទេវតាជីព្រីលមកជួបគាត់រៀងរាល់យប់ខែបួសដើម្បីសូត្រអាល់គួរអានជាមួយព្យាការីមូហាំម៉ាត់។ គាត់មានចិត្តសប្បុរសនិងទូលាយជាងខ្យល់បក់នាំទឹកភ្លៀងទៅទៀត)។ ចាពៀរ ពិន អាប់ឌុលឡោះបាននិយាយថា: (គេមិនដែលសុំអ្វីមួយពីព្យាការីមូហាំម៉ាត់ ហើយគាត់ថា: ទេ នោះឡើយ)។

២១- ភាពខ្មាសអៀន: អាពូសាអ៊ីត អាល់ខុតទ្រីនិយាយថា: (ព្យាការីមូហាំម៉ាត់ គាត់ខ្មាសអៀនជាងកូនក្រមុំដែលនៅក្នុងផ្ទះ បើគាត់ឃើញអ្វីមួយគួរអោយស្អប់ ពួកយើងដឹងតាមសភាពប្រែប្រួលនៃទឹកមុខរបស់គាត់)។

២២-ការអោនលំទោន: ព្យាការីមូហាំម៉ាត់ជាមនុស្សអោនលំទោនជាងគេបំផុត។ ដោយការអោនលំទាន ឬការដាក់ខ្លួនខ្លាំងពេករបស់គាត់ ទើបអ្នកមកពីក្រៅចូលក្នុងវិហារ មិនស្គាល់ថា នរណាម្នាក់ជារូបគាត់ក្នុងចំណោមពួកសហាការីរបស់គាត់។ អាណាស ពិន ម៉ាលិកបាននិយាយថា: (ខណ:ដែលពួកយើងអង្គុយជាមួយព្យាការីមូហាំម៉ាត់ក្នុងវិហារ មានបុរសម្នាក់ជិះអូដ្ឋចូលមក ឱ្យអូដ្ឋក្រោមចុះ ហើយចងនៅមុខវិហារ រួចស្រែកសួរពួកគេថា: តើនរណាម្នាក់ជាមូហាំម៉ាត់? ព្យាការីគាត់កំពុងទម្រេតខ្លួនក្នុងចំណោមពួកសហាការីរបស់គាត់។ ពួកយើងក៏ឆ្លើយថា: នោះបុរសសម្បុរសកំពុងអង្គុយផ្អែកនៅទីនោះ)។ គាត់ពុំដែលលើកខ្លួនអោយខ្ពស់ជាងសហាការី និងពួកអ្នកអង្គុយជា

មួយគាត់ឡើយ។ ព្យាការីមូហាំម៉ាត់គាត់ពុំដែលធ្វើឫកក្រអឺត ឬឆ្មើង ឆ្មៃក្នុងការរួមដំណើរជាមួយពួកអ្នកទីទ័លក្រ អ្នកទន់ខ្សោយ អ្នកខ្វះខាត គាត់តែងជួយបំពេញតំរូវការរបស់ពួកគេ។

<u>២៣-ការអាណិតស្រលាញ់:</u> អាពូម៉ាស្ហ៊ូត អាល់អ័ណស្ហរីយ៍និយាយថា: (មានបុរសម្នាក់មកជួបព្យាការីមូហាំម៉ាត់ ហើយនិយាយថា ឱអ្នកនាំសាររបស់អល់ឡោះ! ខ្ញុំមកថ្វាយបង្គំពេលព្រឹកយឺត ព្រោះមានអ្នកខ្លះថ្វាយបង្គំយូរៗពេក។ គាត់ថា: ខ្ញុំមិនដែលឃើញព្យាការីមូហាំម៉ាត់ខឹងអ្វីខ្លាំងជាងការទូន្មាននៅថ្ងៃនោះឡើយ។ គាត់បានប្រសាសន៍ថា: នែមនុស្សទាំងឡាយ ក្នុងចំណោមពួកអ្នក មានអ្នកដែលត្រូវគេអាក់អន់ចិត្ត ដូច្នេះ នរណាធ្វើអ៊ីមុាំថ្វាយបង្គំ ចូរអ្នកនោះ ត្រូវថ្វាយបង្គំអោយល្មមកុំយូរពេក ព្រោះមានអ្នកខ្លះចាស់ជរា អ្នកខ្លះទន់ខ្សោយ ហើយខ្លះទៀត មានការបន្ទាន់)។

<u>២៤- ភាពអំណត់ និងចិត្តប្រណី:</u> អាណាស ពិន ម៉ាលិក និយាយថា: (ខ្ញុំបានរួមដំណើរជាមួយព្យាការីមូហាំម៉ាត់ គាត់ពាក់អាវផាយផលិតនៅតំបន់ណ័ចរ៉ន មានជាយក្រាស់។ មានជនជាតិអារ៉ាប់ពនេចរម្នាក់បានសំដៅមករកគាត់ រួចចាប់ក្របូចអាវពីក្រោយ ទាញកន្ត្រាក់យ៉ាងខ្លាំង រហូតខ្ញុំឃើញស្មារបស់គាត់រលាស់ស្បែកមុតនឹងជាយអាវផាយរបស់គាត់ ដោយសារគេចាប់កន្ត្រាក់ខ្លាំងពេក ហើយបុរសនោះនិយាយថា: សូមប្រគល់មកអោយខ្ញុំ ទ្រព្យរបស់អល់ឡោះដែលនៅជាមួយអ្នក។ ព្យាការីមូហាំម៉ាត់បែរមករកបុរសនោះ ហើយសើចរួចប្រើគេឱ្យយកទ្រព្យមកអោយបុរសនោះ)។ ឧទាហរណ៍ជាក់ស្តែង

ពីចិត្តប្រណីរបស់គាត់ គឺនៅពេលគាត់រំដោះបានទឹកដីម៉ឹក្កះ គាត់បានប្រមូលទាំងអស់ពួកអ្នកស្រុក ក្នុងចំណោមពួកគេ មានអ្នកខ្លះធ្លាប់ធ្វើបាបគាត់ ហើយរករឿងដេញគាត់ចេញពីស្រុកកំណើត។ គាត់បានប្រសាសន៍ខណ:ដែលពួកគេជុំគ្នានៅវិហារថា: (តើពួកអ្នកបានឃើញខ្ញុំធ្វើយ៉ាងម៉េចខ្លះចំពោះពួកអ្នក? ពួកគេឆ្លើយថា ល្អ.. ជាបងប្អូនល្អ ជាក្មួយល្អ។ ព្យាការីមូហាំម៉ាត់បានប្រសាសន៍ទៅពួកគេថា: សូមអញ្ជើញទៅវិញចុះ ពួកអ្នកទាំងអស់គ្នា សុទ្ធតែមានសេរីភាព)។

<u>២៥-យុត្តិធម៌ និងសច្ចធម៌:</u> ព្យាការីមូហាំម៉ាត់គាត់ប្រកាន់នូវភាពយុត្តិធម៌ចំពោះគ្រប់កិច្ចការទាំងឡាយក្នុងជីវិត ហើយយុត្តិធម៌ក្នុងការអនុវត្តច្បាប់របស់អល់ឡោះ។ អាអ៊ីសះបាននិយាយថា: ពិតប្រាកដពួកគូរេស្សមានកង្វល់នឹងរឿងស្ត្រីម្នាក់ មកពីកុលសម្ព័ន្ធម៉ឹខហ្ស៊ូមដែលបានលួចគេ។ ពួកគេនិយាយថា: តើមាននរណាហ៊ាននិយាយសំរួលជាមួយព្យាការីមូហាំម៉ាត់ពីរឿងស្ត្រីម្នាក់នេះ? គ្មាននរណាហ៊ាននិយាយជាមួយព្យាការីមូហាំម៉ាត់ ក្រៅពីអ៊ូសាម៉ះ ពិន ហេ្សត ព្រោះជាអ្នកជិតដិតជាមួយគាត់។ អ៊ូសាម៉ះក៏និយាយរឿងនេះប្រាប់ព្យាការីមូហាំម៉ាត់។ គាត់បានប្រសាសន៍តបវិញថា: (តើឯងហ៊ានការពារអ្នកដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌរបស់អល់ឡោះមែនទេ? បន្ទាប់មកគាត់បានក្រោកឈរ ហើយថ្លែងថា: ពិតប្រាកដ ពួកមនុស្សសម័យមុនវិនាសដោយសារ បើកាលណាចោរលួចចេញពីត្រកូលខ្ពស់ត្រូវរួចពីទោស តែបើចោរលួចចេញពីវណ្ណៈតូចទាប ត្រូវគេចាប់មកកាត់

ទោស។ សូមស្បថចំពោះអល់ឡោះជាម្ចាស់! បើសិនជា ហ្វាតីម៉ះកូនស្រីរបស់ខ្ញុំទៅលួចគេនោះ ខ្ញុំនឹងកាត់ដៃរបស់នាង)។

២៦-កោតខ្លាចចំពោះអល់ឡោះ ព្យាការីមូហាំម៉ាត់ជាមនុស្សដែលកោតខ្លាចចំពោះអល់ឡោះខ្លាំងជាងគេបំផុត។ អាប់ឌុលឡោះ ពិនម៉ាស្ហ៊ូតបាននិយាយថាៈ (ព្យាការីមូហាំម៉ាត់បានប្រើខ្ញុំថា ចូរសូត្រឱ្យខ្ញុំស្តាប់។ ខ្ញុំថាៈ តើខ្ញុំសូត្រអោយលោកស្តាប់ ហើយលោកត្រូវគេប្រទានគម្ពីរចុះមកឱ្យឬ?។ គាត់តបវិញថា បាទ។ ខ្ញុំបានសូត្រស៊ូរោះ អ័ណនីសាក រហូតដល់អាយ៉ាត់ៈ

﴿ فَكَيْفَ إِذَا جِئْنَا مِن كُلِّ أُمَّةٍۭ بِشَهِيدٍ وَجِئْنَا بِكَ عَلَىٰ هَٰٓؤُلَآءِ شَهِيدًا ﴿٤١﴾ ﴾

سورة النساء / الآية: ٤١

មានន័យថាៈ (តើស្ថានភាពរបស់មនុស្សយ៉ាងម៉េចទៅវិញ នៅថ្ងៃបរលោក ខណៈដែលអល់ឡោះទ្រង់នាំមកពីគ្រប់ប្រជាជាតិនីមួយៗនូវអ្នកនាំសារម្នាក់ជាសាក្សីលើទង្វើរបស់ពួកគេ ហើយអល់ឡោះក៏នាំព្យាការីមូហាំម៉ាត់មកធ្វើជាសាក្សីលើប្រជាជាតិរបស់ខ្លួន និងលើពួកអ្នកនាំសារសម័យមុន បញ្ជាក់ប្រាប់ថា ពួកគេពិតជាបានបំពេញកាតព្វកិច្ចផ្សព្វផ្សាយសាររបស់ព្រះដល់ប្រជាជាតិរបស់ខ្លួន)។

គាត់បានប្រសាសន៍ថាៈ ឈប់ត្រឹមហ្នឹងចុះ ខ្ញុំបែរទៅរកគាត់ ស្រាប់តែឃើញគាត់យំស្រក់ទឹកភ្នែក។

២៧-ចង់អោយអ្នកដទៃបានល្អ ទោះជាសត្រូវរបស់ខ្លួនៈ អាអ៊ីសះប្រពន្ធរបស់គាត់បាននិយាយថាៈ ខ្ញុំបាននិយាយទៅកាន់ព្យាការីមូហាំម៉ាត់ថាៈ តើមានថ្ងៃណាដែលអាក្រក់ចំពោះលោកជាងថ្ងៃច្បាំងអូហុឌ

ទេ? គាត់បានប្រសាសន៍ថា: (ថ្ងៃដែលអាក្រក់បំផុតសំរាប់ខ្ញុំ គឺថ្ងៃអាកោហ្គះ ខណៈដែលខ្ញុំបានបង្ហាញខ្លួននៅចំពោះមុខ អិពិន អាប់ទីយ៉ាលីល ពិន អាប់ទីកូឡាល ហើយគេមិនព្រមឆ្លើយតបនឹងអ្វីដែលជាប្រាថ្នារបស់ខ្ញុំ។ ខ្ញុំក៏ចាកចេញទាំងទុក្ខសោក ក្រៀមក្រំ ដើរអត់ដឹងខ្លួនសោះ លុះមកដល់តំបន់កើរនុស្សាអាឡិប ខ្ញុំងើយទៅលើមេឃ ស្រាប់តែឃើញផ្ទាំងពពកបាំងពីលើខ្ញុំ ខ្ញុំលំឡឹងមើល ក៏ឃើញទេវតាជីព្រីលហៅខ្ញុំ ហើយនិយាយថា: ពិតប្រាកដ អល់ឡោះជាម្ចាស់ទ្រង់បានលឺសម្តីសាសន៍របស់អ្នក និងការប្រតិកម្មរបស់ពួកគេ ចំពោះអ្នក។ ទ្រង់បានបញ្ជូនទេវតាភ្នំមក ហើយអ្នកអាចបញ្ជាគេតាមចិត្ត។ ទេវតាភ្នំបានហៅខ្ញុំ ហើយស្វាគមន៍ខ្ញុំ រួចនិយាយថា: នៃមូហាំម៉ាត់ ចង់អោយយើងធ្វើយ៉ាងម៉េចចំពោះពួកគេ តើចង់អោយយើងយកភ្នំទាំងពីរសង្កត់ពីលើពួកគេ ឬយ៉ាងណា? គាត់បានតបចំពោះទេវតាភ្នំថា: តែខ្ញុំសង្ឃឹមថា កូនចៅជំនាន់ក្រោយរបស់ពួកគេនឹងគោរពសក្ការៈចំពោះអល់ឡោះ ហើយមិនយកពហុទេពមកគោរពរួមជាមួយទ្រង់ឡើយ)។

<u>២៨-ស្និទ្ធស្នាល និងជិតដិតជាមួយសហការី:</u> គាត់ធ្លាប់ប្រលែងលេងជាមួយសហការីរបស់គាត់។ អាណាស ពិន ម៉ាលិកនិយាយថា:(គាត់ជាមនុស្សដែលមានចរិយាសម្បត្តិប្រពៃជាងគេ កាលនោះខ្ញុំមានប្អូនប្រុសម្នាក់ គេហៅវាថា អាពូអ៊ូមែរ(**أبو عُمَير**)។ ខ្ញុំគិតថា គាត់បាននិយាយថា អាពូអ៊ូមែរនៅតូចនៅឡើយ។ គាត់ថា នៅពេលដែលព្យាការីមកដល់ឃើញគេ ក៏និយាយថា នៃអាពូអ៊ូមែរ តើនូហ្គែរ (សត្វស្លាប)កំពុងធ្វើអ្វី? គាត់ថា អាពូអ៊ូមែរកំពុងប្រលែងលេងជាមួយសត្វស្លាបនោះ)។

២៩-ប្រឹក្សាជាមួយសហការី សុំយោបល់ចំពោះគ្រប់កិច្ចការដែលគ្មានចែងក្នុងច្បាប់: អាពូហ៊្វ័យរ៉េះបាននិយាយថា: (ខ្ញុំមិនដែលឃើញនរណាប្រឹក្សាជាមួយសហការីរបស់ខ្លួនច្រើនជាងព្យាការីមូហាំម៉ាត់នោះឡើយ)។

៣០- ដឹងគុណ និងតបស្នងចំពោះអំពើល្អ: ខ្លួនគាត់ផ្ទាល់បានមានប្រសាសន៍ថា: (នរណាធ្វើអំពើល្អចំពោះពួកអ្នក ចូរតបស្នងចំពោះគេ បើឥតមានអ្វីតបស្នង ចូរបួងសួងសុំអោយគេ ដើម្បីអោយពួកអ្នកដឹងថាពួកអ្នកបានតបស្នងចំពោះគេ)។ អាអ៊ីសះនិយាយថា: (ព្យាការីមូហាំម៉ាត់គាត់ទទួលយកអំណោយ ហើយគាត់តបស្នងវិញនូវអ្វីដែលសក្តិសមនឹងអំណោយនោះ)។

៣១-ពេញចិត្តនឹងភាពល្អស្អាត និងក្លិនក្រអូប: អាណាសបាននិយាយថា: (ខ្ញុំមិនដែលកាន់សូត្រ ឬសំពត់សូត្រណាទន់ជាងបាតដៃរបស់ព្យាការីមូហាំម៉ាត់ ហើយខ្ញុំមិនដែលហិតក្លិនអ្វីក្រអូបជាងក្លិនរបស់ព្យាការីមូហាំម៉ាត់)។

៣២-ធ្វើការដោយខ្លួនឯង: អាអ៊ីសះបាននិយាយខណៈគេសួរគាត់ថា: តើនៅផ្ទះព្យាការីមូហាំម៉ាត់គាត់ធ្វើអ្វីខ្លះ? គាត់តបវិញថា:(គាត់ដូចជាមនុស្សទូទៅដែរ គាត់បោកសម្អាតសំលៀកបំពាក់ រឹតទឹកដោះពពែ គាត់ធ្វើការងារដោយខ្លួនឯង)។ ដោយសារ ចរិយាដ៏សែនប្រពៃរបស់គាត់ មិនត្រឹមតែបំរើខ្លួនឯងប៉ុណ្ណោះទេ តែថែមទាំងបំរើអ្នកដទៃទៀតផង។ អាអ៊ីសះប្រពន្ធរបស់គាត់និយាយពេលគេសួរគាត់ថា តើនៅផ្ទះ

ព្យាការីមូហាំម៉ាត់គាត់ធ្វើអ្វីខ្លះ? គាត់ឆ្លើយថាៈ គាត់ជួយកិច្ចការគ្រួសារ ពេលលឺគេអាហ្សានគាត់ចេញទៅថ្វាយបង្គំ)។

***

ភស្តុតាងបញ្ជាក់ពីសច្ចភាពនៃសារ និងភាពក្លាយជាព្យាការី

១-ពិតប្រាកដណាស់ ព្យាការីមូហាំម៉ាត់ គាត់ជាអនក្ខរជនមិនចេះអាន មិនចេះសរសេរ គាត់កើតក្នុងសង្គមមិនចេះអក្សរ។ តិចតួចណាស់អ្នកដែលចេះអក្សរ ទាំងនេះដើម្បីកុំអោយមានមន្ទិលចំពោះបញ្ហាការបញ្ចុះព្រះបន្ទូល។ ជាអំណះអំណាងមោឃៈដែលចោទថា ព្យាការីមូហាំម៉ាត់បានតាក់តែង ឬនិពន្ធដោយខ្លួនឯង។ អល់ឡោះជាម្ចាស់ទ្រង់បានមានព្រះបន្ទូលថាៈ

﴿ وَمَا كُنتَ تَتْلُوا۟ مِن قَبْلِهِۦ مِن كِتَـٰبٍ وَلَا تَخُطُّهُۥ بِيَمِينِكَ ۖ إِذًا لَّٱرْتَابَ ٱلْمُبْطِلُونَ ﴿٤٨﴾ ﴾

سورة العنكبوت / الآية : ٤٨

មានន័យថាៈ (នៃមូហាំម៉ាត់ ភាពពិតនៃអច្ឆរិយៈរបស់ឯង គឺឯងពុំបានអានសៀវភៅណាមួយឡើយ ហើយពុំបានសរសេរអក្សរនឹងដៃស្ដាំរបស់ឯងមុននឹងបញ្ចុះព្រះគម្ពីរ ហើយពួកគេជ្រាបច្បាស់ពីរឿងនេះ បើសិនជា ឯងបានអានសៀវភៅ ឬធ្លាប់ចេះសរសេរមុននឹងព្រះបានអោយអ្នកត្រាស់ដឹងនោះ ពួកអ្នកបដិសេធនឹងកើតមន្ទិលសង្ស័យថា ឯងបានរៀនចេះ ឬសរសេរចំលងពីសៀវភៅដទៃ)។ ព្យាការីមូហាំម៉ាត់បាននាំមកនូវអ្វីដែលពួកអារ៉ាប់អសមត្ថភាពធ្វើអោយដូច ហើយធ្វើអោយពួកគេរំជើបរំជួលនឹងពាក្យកាព្យ និងវោហារស័ព្ទរបស់គាត់

ហើយអច្ឆរិយៈដ៏អមតៈរបស់គាត់ គឺគម្ពីរអាល់គួរអាន។ ដូចគាត់បានមានប្រសាសន៍ថាៈ

عَنْ أَبِي هُرَيْرَةَ أَنَّ رَسُولَ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ: (مَا مِنْ الْأَنْبِيَاءِ نَبِيٌّ إِلَّا وَقَدْ أُعْطِيَ مِنْ الْآيَاتِ مَا مِثْلُهُ آمَنَ عَلَيْهِ الْبَشَرُ وَإِنَّمَا كَانَ الَّذِي أُوتِيتُ وَحْيًا أَوْحَاهُ اللَّهُ عَزَّ وَجَلَّ إِلَيَّ وَأَرْجُو أَنْ أَكُونَ أَكْثَرَهُمْ تَبَعًا يَوْمَ الْقِيَامَةِ) رواه الإمام أحمد

មានន័យថាៈ (គ្មានព្យាការីណាម្នាក់ លើកលែងតែគេប្រទានអោយនូវភស្តុតាង ឬអច្ឆរិយៈដែលដូចនឹងលក្ខណៈរបស់គេ ដើម្បីឱ្យមនុស្សជឿជាក់ចំពោះគេ តែចំពោះខ្ញុំវិញ គេប្រទានអោយខ្ញុំនូវព្រះបន្ទូលដែលព្រះត្រាស់បង្គាប់មកចំពោះខ្ញុំ ហើយខ្ញុំសង្ឃឹមថា មានបរិវារដើរតាមច្រើនជាងគេនៅថ្ងៃបរលោក)។

បើទោះជា សាសន៍របស់គាត់ពូកែខាងកំណាព្យកាព្យឃ្លោងមានវោហារខាងផ្នែកភាសាក៏ដោយ ក៏គម្ពីរអាល់គួរអានបានប្រកាសឱ្យពួកគេនិពន្ធអោយដូចគម្ពីរនេះ បន្ទាប់មក ប្រកាសអោយពួកគេនិពន្ធឱ្យបានមួយជំពូកដូចអាល់គួរអាន។ ទ្រង់បានមានព្រះបន្ទូលថាៈ

﴿ وَإِن كُنتُمْ فِي رَيْبٍ مِّمَّا نَزَّلْنَا عَلَىٰ عَبْدِنَا فَأْتُوا بِسُورَةٍ مِّن مِّثْلِهِ وَادْعُوا شُهَدَاءَكُم مِّن دُونِ اللَّهِ إِن كُنتُمْ صَادِقِينَ ﴿٢٣﴾ ﴾ **سورة البقرة/الآية: ٢٣**

មានន័យថាៈ (បើពួកអ្នកនៅកើតមន្ទិលសង្ស័យចំពោះអ្វីដែលយើងបានប្រទានចុះមក ដូច្នេះ ចូរនិពន្ធអោយបានមួយជំពូកអោយដូចគម្ពីរអាល់គួរអាន។ ចូរអំពាវនាវហៅបក្ខពួកដែលគាំទ្រពួកអ្នក ក្រៅពីព្រះអល់ឡោះជាម្ចាស់អោយមកជួយចុះ បើការអះអាងរបស់ពួកអ្នកត្រឹមត្រូវពិតប្រាកដមែននោះ)។

មិនតែប៉ុណ្ណោះ   គម្ពីរនេះប្រកាសឱ្យមនុស្សទូទៅមកប្រកួតប្រជែង។ ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿ قُل لَّئِنِ ٱجۡتَمَعَتِ ٱلۡإِنسُ وَٱلۡجِنُّ عَلَىٰٓ أَن يَأۡتُواْ بِمِثۡلِ هَٰذَا ٱلۡقُرۡءَانِ لَا يَأۡتُونَ بِمِثۡلِهِۦ وَلَوۡ كَانَ بَعۡضُهُمۡ لِبَعۡضٖ ظَهِيرٗا ٨٨ ﴾ **سورة الإسراء / الآية: ٨٨**

មានន័យថា: (មូហាំម៉ាត់ចូរប្រសាសន៍ចុះថា បើមនុស្ស បិសាច រួបរួមគ្នានិពន្ធអោយដូចគម្ពីរអាល់គួរអាន គឺពួកគេពុំអាចនិពន្ធអោយដូចជាដាច់ខាត បើទោះជា ពួកគេជួយជ្រោមជ្រែងគ្នាយ៉ាងណាក៏ដោយ)។

២-ព្យាការីមូហាំម៉ាត់នៅតែបន្តការអំពាវនាវរបស់គាត់   ថ្វីត្បិតមានការប្រឈមមុខនឹងការលំបាក និងឧបសគ្គ ដែលតែងកើតមានរវាងគាត់ និងសាសន៍របស់គាត់ រហូតដល់ថ្នាក់ប្រើឧបាយកលចង់ធ្វើឃាតគាត់ ដើម្បីបញ្ឈប់នូវសកម្មភាពអំពាវនាវរបស់គាត់។ ជាមួយនឹងស្ថានភាពបែបនេះ គាត់នៅតែបន្តតាមផ្លូវអំពាវនាវអោយមករកសាសនាថ្មីដែលគេបានបញ្ជូនមក ហើយអត់ធ្មត់ចំពោះអ្វីដែលគាត់ជួបប្រទះនូវផលលំបាក ការនឿយហត់ ការគៀបសង្កត់ពីសំណាក់សាសន៍របស់គាត់ ក្នុងផ្លូវផ្សព្វផ្សាយសាសនារបស់អល់ឡោះ។ បើសិនជា គាត់ជាមនុស្សបោកប្រាស់ ភូតកុហក តែគាត់ជាមនុស្សស្អាតស្អំ គឺគាត់នឹងបោះបង់ចោលមិនអំពាវនាវបន្ត ហើយគិតបារម្ភពីខ្លួនឯង ខ្លាចវិនាស ដោយផ្អែកទៅលើអ្វីដែលគាត់បានឃើញសាសន៍របស់គាត់ប្រមូលផ្តុំគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹងគាត់ ហើយភាពមុះមុតរបស់ពួកគេនឹងបំផ្លាញសកម្មភាពអំពាវនាវរបស់គាត់ជាមិនខាន។

៣-ជាទូទៅ តាមនិស្ស័យរបស់មនុស្ស ចូលចិត្តត្រេកត្រអាលនឹងជីវិតរស់នៅមានតាំងពី ទ្រព្យសម្បត្តិ ចំណីអាហារ និងការការប្រពន្ធ ហើយគេស្វះស្វែង ប្រឹងប្រែង ដើម្បីសំរេចនូវការត្រេកត្រអាលនេះ ដោយប្រើមធ្យោបាយគ្រប់បែបយ៉ាង ក៏ប៉ុន្តែ ខុសគ្នា នៅត្រង់អ្នកខ្លះរកបានដោយស្របច្បាប់ ហើយខ្លះទៀតរកបានដោយខុសច្បាប់។ បើយើងបានជ្រាប និងយល់ពីនិស្ស័យបែបនេះ យើងអាចនិយាយបានថា ពិតប្រាកដ ព្យាការីមូហាំម៉ាត់នៅដំណាក់កាលដំបូងនៃការអំពាវនាវរបស់គាត់ សាសន៍របស់គាត់បានចរចាជាមួយគាត់ ហើយយកចិត្តគាត់គ្រប់បែបយ៉ាង និងប្រើទ្រព្យសម្បត្តិលួងលោមគាត់ ហើយសន្យាថា នឹងបំពេញជូននូវគ្រប់ក្តីប្រាថ្នាតំរូវការ និងជួយសំរេចបំណងរបស់គាត់។ បើគាត់ចង់ក្លាយជាចៅហ្វាយនាយ ពួកគេនឹងលើកអោយធ្វើចៅហ្វាយ បើចង់បានប្រពន្ធ នឹងលើកប្រពន្ធដែលស្អាតបំផុតអោយគាត់ បើចង់បានទ្រព្យសម្បត្តិ នឹងប្រគល់ទ្រព្យសម្បត្តិអោយ តែត្រូវគោរពតាមលក្ខខណ្ឌរបស់ពួកគេ គឺបោះបង់ការផ្សព្វផ្សាយសាសនាដែលគាត់កំពុងធ្វើការអំពាវនាវ។ គាត់ឆ្លើយតបចំពោះពួកគេដោយចិត្តជឿជាក់ និងពឹងពាក់ចំពោះការទូន្មានរបស់ព្រះជាម្ចាស់ថាៈ (សូមស្បថចំពោះអល់ឡោះ! បើទោះជាពួកគេយកព្រះអាទិត្យមកដាក់លើដៃស្តាំខ្ញុំ ហើយយកព្រះចន្ទមកដាក់លើដៃឆ្វេងខ្ញុំ ហើយចង់អោយខ្ញុំបោះបង់កិច្ចការនេះ គឺខ្ញុំមិនបោះបង់ជាដាច់ខាត លុះត្រាណាអល់ឡោះជាម្ចាស់ទ្រង់ធ្វើឱ្យសាសនានេះទទួលជោគជ័យ ឬ

ខ្ញុំសុខចិត្តវិនាសដោយបុព្វហេតុសាសនា។ បើគាត់ជាមនុស្ស បោកប្រាស់ តែគាត់ស្អាតស្អំពីចរិតបែបនេះ នោះគាត់នឹងយល់ព្រមតាមសំណើរបស់ពួកគេ ហើយគាត់ចាប់យកឱកាសដ៏កម្រនេះ ពីព្រោះអ្វីដែលពួកគេផ្តល់អោយ សុទ្ធតែមានតំលៃលើសពីអ្វីដែលមនុស្សមានមហិច្ឆតា នៅខិតខំប្រឹងប្រែង និងលោភលន់ចង់បានទៅទៀត។

៣-តាមធម្មតា រាល់បុគ្គលដែលកាន់តំណែងជាមេដឹកនាំ ឬចៅហ្វាយនាយ តែងក្តោបក្តាប់អ្វីៗទាំងអស់ ដូចជា ផលប្រយោជន៍ និងមន្ត្រីក្រោមឱវាទ ទុកសំរាប់បម្រើប្រយោជន៍ផ្ទាល់ខ្លួន។ រីឯព្យាការីមូហាំម៉ាត់ គាត់ជ្រាបច្បាស់ថា លោកីយ៍ពុំមែនជាលំនៅអចិន្ត្រៃយ៍និងអមតៈ។ អាប់ឌុលឡោះ ពិន ម៉ាស្អ៊ូត និយាយថាៈ ព្យាការីមូហាំម៉ាត់គាត់គេងលើកន្ទេល ហើយពេលក្រោកឡើងមានស្នាមកន្ទេលជាប់នឹងខ្លួន។ ខ្ញុំនិយាយថាៈ សូមយកឱពុកម្តាយមកធានា! បើលោកប្រាប់ខ្ញុំមុន ខ្ញុំនឹងក្រាលកម្រាលជូនលោក ដើម្បីកុំអោយឈឺខ្នង។ គាត់បានមានប្រសាសន៍ថា (ខ្ញុំគ្មានបេតីចំពោះលោកីយ៍ ហើយលោកីយ៍គ្មានអ្វីគួរអោយខ្ញុំបេតីដែរ ខ្ញុំនៅលោកីយ៍គ្មានប្រៀបបាននឹងអ្វីក្រៅពី អ្នកជិះសេះ ជ្រកសំរាកក្រោមម្លប់ឈើ ហើយក៏ចាកចេញ និងបោះបង់ម្លប់នោះចោល)។ សាំម៉ាកបាននិយាយថាៈ ខ្ញុំបានលឺ អ័ណនូកម៉ាន ពិន បាស្សៀរ និយាយថាៈ ជាការពិតណាស់ ពួកអ្នកមានចំណីអាហារ និងគ្រឿងបរិភោគហូបតាមចិត្ត។ ពិតប្រាកដ ខ្ញុំបានឃើញព្យាការីមូហាំម៉ាត់ ឥតមាន

អ្វីសោះ សូម្បីតែផ្លែល្មើអន់ក៏គ្មានហូបចំអែតក្រពះផង។ អាពីហ៊ូរ៉យរ៉ោះបាននិយាយថា: (ក្រុមគ្រួសារព្យាការីមូហាំម៉ាត់ពុំដែលហូបឆ្អែតបីថ្ងៃជាប់គ្នា រហូតដល់គាត់លាចាកលោក)។ បើទោះជាឧបទ្វីបអារ៉ាប់ កាលសម័យនោះ នៅក្រោមអំណាច និងការគ្រប់គ្រងរបស់គាត់ ហើយគាត់ជាមនុស្សមានគុណូបការៈធំធេងក្នុងការកសាងភាពរីកចំរើនដល់មនុស្សក៏ដោយ ក៏មានពេលខ្លះ គាត់ឥតមានចំណីអាហារហូបគ្រប់គ្រាន់។ នេះពុំមែនមានន័យថា គាត់មិនអាចទទួលបាននូវអ្វីដែលគាត់ត្រូវការនោះទេ។ ជាការពិតណាស់ ទ្រព្យសម្បត្តិ និងរបស់មានតំលៃជាច្រើនគេយកមកជូនគាត់នៅនឹងមុខក្នុងវិហារ គាត់គ្មានរំភើបអ្វីបន្តិចឡើយ គាត់មិនសម្រាក លុះត្រាណា គាត់បានយកទ្រព្យរបស់ទាំងនោះទៅចែកចាយអ្នកទីទ័លក្រ ខ្វះខាតឱ្យអស់សិន ទើបសំរាក។ ពួកសហការីរបស់គាត់មួយចំនួនជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ហើយពួកគេដណ្តើមគ្នាបំរើគាត់ ពួកគេហ៊ានលះបង់នូវគ្រប់វត្ថុមានតំលៃដើម្បីគាត់។ តែព្យាការីមូហាំម៉ាត់ គាត់យល់ច្បាស់ពីសច្ចភាពនៃលោកីយ៍ គាត់បានប្រសាសន៍ថា: (សូមស្បថចំពោះអល់ឡោះជាម្ចាស់! លោកីយ៍បើប្រៀបនឹងថ្ងៃបរលោកបីដូចជាគេយកម្រាមដៃចង្អុលជ្រលក់ទៅក្នុងទឹកទន្លេ រួចពិនិត្យមើល ពេលដកម្រាមដៃមកវិញ តើមានអ្វីជាប់មកខ្លះ?)។

៤- ពិតប្រាកដ ព្យាការីមូហាំម៉ាត់ មានហេតុការណ៍ខ្លះពិបាកខ្លាំងមែនទែន គាត់ត្រូវការបកស្រាយ និងបំភ្លឺ តែគាត់មិនអាចប្រឈមដោះ

ស្រាយបាន ដោយសារ គ្មានព្រះបន្ទូលបញ្ចុះមក។ ដូច្នេះ គាត់បិត នៅមួយរយៈមុននឹងព្រះបន្ទូលបញ្ចុះមកក្នុងសភាពកើតទុក្ខ ខ្វល់ខ្វាយ រង់ចាំព្រះបន្ទូលពីអល់ឡោះជាម្ចាស់ដើម្បីស្រាយបំភ្លឺពីហេតុផលនៃហេតុការណ៍ទាំងនោះ។

៥-ព្យាការីមូហាំម៉ាត់គាត់មិនលើកឋានៈខ្លួន ខ្ពស់លើសមនុស្សទាំងឡាយនោះទេ។ គាត់មិនទទួលចំពោះការគោរពដែលបង្ហាញពីការលើកតំកើងគាត់។ អាណាសបាននិយាយពីសហាការីរបស់ព្យាការីមូហាំម៉ាត់ថា: (គ្មានបុគ្គលណាដែលជាទីស្រលាញ់ចំពោះពួកគេជាងព្យាការីមូហាំម៉ាត់ គាត់បន្តទៀតថា: កាលណាពួកគេឃើញគាត់ ពួកគេមិនក្រោកឈរគោរពគាត់ទេ ដោយសារពួកគេដឹងថាគាត់មិនពេញចិត្តចំពោះទង្វើបែបនេះ)។

៦- ច្បាប់ទម្លាប់ ក្បួនតម្រាដែលឥស្លាមនាំមកតាមរយៈពាក្យសម្ដីរបស់ព្យាការីមូហាំម៉ាត់ទាក់ទងខាងផ្នែកគោរពសក្ការៈ ការប្រាស្រ័យទាក់ទង ការរៀបអាពាហ៍ពិពាហ៍ ផ្នែកសេដ្ឋកិច្ច នយោបាយ និងការធ្វើសង្គ្រាម។ល។ គឺធ្វើឱ្យមនុស្សជាតិទូទៅគ្មានសមត្ថភាពនឹងនាំមកឱ្យដូចបានឡើយ។ តើសមហេតុផលដែរទេ បុរសម្នាក់ដែលជាអនក្ខរជន មិនចេះអាន មិនចេះសរសេរ អាចនាំមកនូវក្បួនច្បាប់ដ៏សុក្រឹតដែលរៀបចំកិច្ចការលោកីយ៍ទាំងមូល? តើនេះមិនបញ្ជាក់ពីសច្ចភាពនៃការតែងតាំងគាត់ជាព្យាការី និងសាររបស់គាត់ឬយ៉ាងណា? គាត់ពុំដែលនិយាយតាមមនោវិតក្កនោះទេ។

***

គោលគ្រឹះសំខាន់ដែលសក្តិសមនឹងក្លាយជាអ្នកឥស្លាម មានជំនឿចំពោះអល់ឡោះជាម្ចាស់ ប្រតិបត្តិតាមអ្នកនាំសាររបស់ទ្រង់ គឺត្រូវសច្ចាពាក្យទាំងពីរដោយពោលថា:

(أَشْهَدُ أَلاَّ إِلَهَ إِلاَّ اللَّهُ وَأَشْهَدُ أَنَّ مُحَمَّداً رَسُوْلُ اللَّهِ)

មានន័យថា: (ខ្ញុំសូមសច្ចាថា: គ្មានព្រះដែលត្រូវគោរពសក្ការៈយ៉ាងពិតប្រាកដ លើកលែងតែអល់ឡោះ និងសូមសច្ចាថា មូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ)។

ការសច្ចាថា មូហាំម៉ាត់ជាអ្នកនាំសាររបស់ទ្រង់ពុំមែនជាពាក្យគ្រាន់តែគ្រលាស់លើអណ្តាតប៉ុណ្ណោះទេ តែចាំបាច់ត្រូវអនុវត្តឱ្យស្របនឹងតំរូវការ និងខ្លឹមសាររបស់វា។ កាតព្វកិច្ចសំខាន់ ដែលពាក្យថា មូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះទាមទារចង់បាននោះគឺ:

១- ជឿជាក់ចំពោះសារដែលព្យាការីមូហាំម៉ាត់បាននាំមក ជឿថា សារនេះសំរាប់មនុស្សទូទៅ។ ពុំមែនជាសារដែលដាក់មកចំពោះតែមនុស្សមួយក្តាប់តូចប៉ុណ្ណោះទេ។ តែជាសារទូទៅគ្មានដែនកំណត់ ចំពោះតែតំបន់ណាមួយ ឬសម័យណាមួយនោះទេ គឺរហូតដល់ថ្ងៃបរលោក ហើយការដែលព្រះជាម្ចាស់តែងតាំងគាត់ គឺជាក្តីមេត្តាដល់មនុស្សលោកទាំងឡាយ ។ ដូចទ្រង់បានមានព្រះបន្ទូល:

﴿ وَمَآ أَرۡسَلۡنَٰكَ إِلَّا رَحۡمَةٗ لِّلۡعَٰلَمِينَ ١٠٧ ﴾ سورة الأنبياء / الآية: ١٠٧

មានន័យថា: (យើងគ្មានបានបញ្ជូនអ្នកឯងមក លើកលែងតែជាក្តីមេត្តាដល់សកលលោកទាំងមូល)។

ទ្រង់បានមានព្រះបន្ទូលទៀតថាៈ

﴿ تَبَارَكَ ٱلَّذِي نَزَّلَ ٱلْفُرْقَانَ عَلَىٰ عَبْدِهِۦ لِيَكُونَ لِلْعَـٰلَمِينَ نَذِيرًا ۝١ ﴾ سورة الفرقان / الآية: ١

មានន័យថាៈ (ពរជ័យរបស់ទ្រង់ដ៏ឧត្តម ប្រយោជន៍របស់ទ្រង់ដ៏ច្រើនលើសលប់ និងព្រះលក្ខណៈរបស់ទ្រង់ដ៏សុក្រឹតនោះ គឺទ្រង់បានប្រទានគម្ពីរអាល់គួរអាន ដែលវែកញែករកខុសត្រូវ ចំពោះខ្ញុំបម្រើរបស់ទ្រង់ព្យាការីមូហាំម៉ាត់ ដើម្បីតែងតាំងគេជាអ្នកនាំសារមកកាន់មនុស្ស និងជិន ″បង់បត់ ឬបិសាច″ ហើយដាស់តឿនពួកគេអោយប្រុងប្រយ័ត្នពីទារុណកម្មរបស់ទ្រង់)។

២- ជឿជាក់ចំពោះភាពខ្ជាប់ខ្ជួនគ្មានកំហុសរបស់គាត់ចំពោះអ្វីដែលគាត់បានទទួលពីអល់ឡោះជាម្ចាស់។ ដូចទ្រង់បានបន្ទូលថាៈ

﴿ وَمَا يَنطِقُ عَنِ ٱلْهَوَىٰٓ ۝٣ إِنْ هُوَ إِلَّا وَحْىٌ يُوحَىٰ ۝٤ ﴾ سورة النجم / الآية: ٣-٤

មានន័យថាៈ (ហើយគេពុំមែននិយាយចេញពីមនោវិត័ក ទំនើងចិត្ត។ គម្ពីរអាល់គួរអាន និងប្រសាសន៍របស់គាត់ សុទ្ធតែជាការត្រាស់បង្គាប់ពីអល់ឡោះចំពោះព្យាការីរបស់ទ្រង់)។

៣- ត្រូវជឿជាក់ជាដាច់ខាតថា គាត់គឺជាអ្នកនាំសារចុងក្រោយ និងចុងបញ្ចប់ ហើយប្រសើរលើសអ្នកនាំសារទាំងឡាយ។ គ្មានអ្នកនាំសារ និងគ្មានព្យាការីបន្ទាប់ពីគាត់។ អ្នកណាអះអាងក្រៅពីនេះ អ្នកនោះ ពិតជាខ្វាត់បង់ពីសាសនាឥស្លាម។ដូចទ្រង់មានបន្ទូលថាៈ

﴿ مَّا كَانَ مُحَمَّدٌ أَبَآ أَحَدٍ مِّن رِّجَالِكُمْ وَلَـٰكِن رَّسُولَ ٱللَّهِ وَخَاتَمَ ٱلنَّبِيِّـۧنَ ۗ وَكَانَ ٱللَّهُ بِكُلِّ شَىْءٍ عَلِيمًا ۝٤٠ ﴾

سورة الأحزاب / الآية: ٤٠

មានន័យថា: (មូហាំម៉ាត់ពុំមែនជាឪពុករបស់នរណាម្នាក់ក្នុងចំណោមពួកអ្នក តែគេជាអ្នកនាំសាររបស់អល់ឡោះ និងជាព្យាការីចុងបញ្ចប់របស់ទ្រង់ គ្មានការតែងតាំងព្យាការីបន្ទាប់ពីគេលុះដល់ថ្ងៃបរលោក ហើយអល់ឡោះទ្រង់ដឹងជ្រាបពីទង្វើរបស់ពួកអ្នក គ្មានអ្វីលាក់បាំងនឹងទ្រង់ឡើយ)។

គាត់បានមានប្រសាសន៍ថា:

عن أبي هريرة رضي الله عنه أن النبي صلى الله عليه وسلم قال: (فُضِّلْتُ عَلَى الأَنْبِيَاءِ بِسِتٍّ: أُعْطِيْتُ جَوَامِعَ الْكَلِمِ وَنُصِرْتُ بِالرُّعْبِ وَأُحِلَّتْ لِيَ الْغَنَائِمُ وَجُعِلَتْ لِيَ الأَرْضُ طَهُوْرًا وَمَسْجِدًا وَأُرْسِلْتُ إِلَى الْخَلْقِ كَافَّةً وَخُتِمَ بِيَ النَّبِيُّوْنَ) رواه مسلم

មានន័យថា: (គេប្រទានឱ្យខ្ញុំ ប្រសើរលើសពួកព្យាការីសម័យមុនដោយប្រាំមួយប្រការគឺ: មានពោះហារខ្លឹមក្តោបអត្ថន័យទូលំទូលាយ ឈ្នះដោយសត្រូវចាញ់ប្រៀប ខ្ញុំមានសិទ្ធិយកទ្រព្យជ័យភណ្ឌ ដីទាំងមូលជាវត្ថុសំអាត និងជាកន្លែងថ្វាយបង្គំ គេតែងតាំងខ្ញុំជាអ្នកនាំសារមកកាន់មនុស្សលោកទាំងមូល ហើយខ្ញុំជាព្យាការីទីបញ្ចប់)។

៤- ត្រូវជឿជាក់ជាដាច់ខាតថា សាសនាឥស្លាមពិតជាពេញលេញនិងគ្រប់លក្ខណៈ ហើយព្យាការីមូហាំម៉ាត់បានធ្វើការផ្សព្វផ្សាយទាំងស្រុង ចប់សព្វគ្រប់ គ្មានចន្លោះប្រហោងត្រង់ណាដែលត្រូវបន្ថែម ឬបន្ថយនោះឡើយ។ ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿ ٱلْيَوْمَ أَكْمَلْتُ لَكُمْ دِينَكُمْ وَأَتْمَمْتُ عَلَيْكُمْ نِعْمَتِي وَرَضِيتُ لَكُمُ ٱلْإِسْلَٰمَ دِينًا ﴾

سورة المائدة / الآية : ٣

មានន័យថា: (ថ្ងៃនេះ យើងបានបំពេញសំរាប់ពួកអ្នកនូវសាសនារបស់ពួកអ្នក គឺសាសនាឥស្លាមទទួលបានសម្រេចជោគជ័យ និងចេញជាក្បួនច្បាប់សាសនាដ៏សុក្រឹត។ យើងបានបំពេញគ្រប់គ្រាន់ទៅលើពួក

អ្នកនូវពរជ័យរបស់យើង ដោយសង្គ្រោះពួកអ្នកអោយរួចផុតពីស្បែអន្ធការនៃភាពអវិជ្ជា ទៅរកពន្លឺរស្មីនៃជំនឿ យើងទទួលស្គាល់ឥស្លាមជាសាសនាសំរាប់ពួកអ្នក)។

៥- ត្រូវមានជំនឿយ៉ាងជាក់លាក់ថា ព្យាការីមូហាំម៉ាត់បានបំពេញបេសកកម្មដែលជាបន្ទុកអំពីអល់ឡោះជាម្ចាស់ ហើយបានផ្សព្វផ្សាយ និងពន្យល់ណែនាំដល់ប្រជាជាតិរបស់គាត់ គ្មានគុណប្រយោជន៍អ្វីនីមួយៗ លើកលែងតែគាត់ចង្អុលបង្ហាញ និងបង្គាប់ប្រើអោយគេប្រតិបត្តិ ហើយគ្មានផលអាក្រក់នីមួយៗ លើកលែងតែ គាត់បានហាមឃាត់។ ដូចប្រសាសន៍របស់គាត់ក្នុងការប្រារព្ធបុណ្យហ័ជ្ជលាជំណើរ (**حَجَّة الوَداع**) គាត់បានឡើងថ្លែងចំពោះមហាជនរាប់ពាន់នាក់ថា: (តើមិនមែនទេឬខ្ញុំពិត ជាបានពន្យល់ណែនាំអស់ហើយ?) ពួកគេឆ្លើយថា បាទ! គាត់បន្តថា: (សូម ព្រះជាម្ចាស់ជាសាក្សី)។

៦- ត្រូវមានជំនឿយ៉ាងជាក់លាក់ថា ក្បួនច្បាប់ដែលគេបានប្រទានចុះមក ត្រូវទទួលស្គាល់ជាផ្លូវការពីអល់ឡោះជាម្ចាស់ ក្រោយពីគាត់បានលាចាកលោក។ ពុំត្រូវគោរពសក្ការៈ ថ្វាយបង្គំចំពោះទ្រង់ក្រៅពីក្បួនច្បាប់នេះឡើយ។ អល់ឡោះទ្រង់មិនទទួលស្គាល់ជាដាច់ខាតនូវរាល់ក្បួនច្បាប់ផ្សេងពីនេះ។ ទ្រង់នឹងកាត់ទោសមនុស្សលោកតាមករណីនីមួយៗដែលចាំបាច់។ ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿ وَمَن يَبْتَغِ غَيْرَ ٱلْإِسْلَٰمِ دِينًا فَلَن يُقْبَلَ مِنْهُ وَهُوَ فِى ٱلْءَاخِرَةِ مِنَ ٱلْخَٰسِرِينَ ﴿٨٥﴾ ﴾

سورة آل عمران / الآية : ٨٥

មានន័យថា: (នរណាស្វែងរកសាសនាក្រៅពីឥស្លាម ដែលជាការប្រគល់ខ្លួនជូនអល់ឡោះជាម្ចាស់ ដោយជំនឿឯកទេវៈ គោរព និងប្រណិប័តន៍ចំពោះទ្រង់ ព្រមទាំងប្រតិបត្តិតាមព្យាការី មូហាំម៉ាត់ជាអ្នកនាំសារចុងក្រោយបង្អស់របស់ទ្រង់។ ដូច្នេះ គេមិនទទួលស្គាល់អ្នកនោះជាដាច់ខាត ហើយនៅថ្ងៃបរលោកនឹងឋិតក្នុងចំណោមពួកអ្នកដែលខាតបង់)។

៧- ចាំបាច់ត្រូវគោរពប្រណិប័តន៍ចំពោះព្យាការីមូហាំម៉ាត់។ ដូចទ្រង់បាន មានព្រះបន្ទូលថា:

﴿ وَمَن يُطِعِ ٱللَّهَ وَٱلرَّسُولَ فَأُوْلَٰٓئِكَ مَعَ ٱلَّذِينَ أَنۡعَمَ ٱللَّهُ عَلَيۡهِم مِّنَ ٱلنَّبِيِّـۧنَ وَٱلصِّدِّيقِينَ وَٱلشُّهَدَآءِ وَٱلصَّٰلِحِينَۚ وَحَسُنَ أُوْلَٰٓئِكَ رَفِيقٗا ٦٩ ﴾ **سورة النساء / الآية: ٦٩**

មានន័យថា: (នរណាស្តាប់តាមបង្គាប់របស់អល់ឡោះ និងការទូន្មានអ្នកនាំសាររបស់ទ្រង់ ពួកគេជាពួកអ្នកដែលមានឋានៈឧត្តុង្គឧត្តមបានរួមជាសហការីជាមួយពួកអ្នកដែលទ្រង់បានប្រទានឋានសួគ៌ដល់ពួកគេ រួមមាន ពួកព្យាការី ពួកអ្នកប្រកាន់សច្ចភាព ពួកអ្នកពលី ពួកអ្នកមានកុសលធម៌ ពួកគេនឹងបានរួមជាសហការីដ៏មានមេត្រីភាព)។

គឺការគោរពតាមការបង្គាប់ប្រើរបស់គាត់ និងជៀសវាងពីបំរាមរបស់គាត់។ ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿ وَمَآ ءَاتَىٰكُمُ ٱلرَّسُولُ فَخُذُوهُ وَمَا نَهَىٰكُمۡ عَنۡهُ فَٱنتَهُواْۚ ٧ ﴾ **سورة الحشر / الآية: ٧**

មានន័យថា: (ហើយអ្វីដែលអ្នកនាំសារបានពាំនាំមកជូនពួកអ្នក ចូរពួកអ្នកទទួលយកចុះ ហើយអ្វីដែលគេហាមឃាត់ពួកអ្នក ចូរបោះបង់ចោលចុះ)។

បន្ទាប់មក ទ្រង់បានពន្យល់ប្រាប់ពីកម្មផលនៃអំពើប្រព្រឹត្តិល្មើសចំពោះព្យាការីមូហាំម៉ាត់ ដូចទ្រង់បានបន្ទូលថា:

﴿ وَمَن يَعْصِ ٱللَّهَ وَرَسُولَهُۥ وَيَتَعَدَّ حُدُودَهُۥ يُدْخِلْهُ نَارًا خَٰلِدًا فِيهَا وَلَهُۥ عَذَابٌ مُّهِينٌ ﴿١٤﴾ ﴾ سورة النساء / الآية: ١٤

មានន័យថា: (អ្នកណាប្រព្រឹត្តល្មើសនឹងអល់ឡោះ ល្មើសនឹងអ្នកនាំសាររបស់ទ្រង់ ហើយបំពានលើព្រំខ្ទាតរបស់ទ្រង់ នោះទ្រង់នឹងទម្លាក់គេទៅក្នុងភ្លើងនរកដ៏អមតៈ ហើយគេនឹងរងទារុណកម្មយ៉ាងខ្លោចផ្សាជាទីបំផុត)។

៨- ពេញចិត្តនឹងសេចក្តីសំរេចរបស់គាត់ ពុំត្រូវបដិសេធចំពោះអ្វីដែលគាត់បានចែងជាច្បាប់។ ដូចអល់ឡោះទ្រង់មានព្រះបន្ទូលថា:

﴿ فَلَا وَرَبِّكَ لَا يُؤْمِنُونَ حَتَّىٰ يُحَكِّمُوكَ فِيمَا شَجَرَ بَيْنَهُمْ ثُمَّ لَا يَجِدُوا۟ فِىٓ أَنفُسِهِمْ حَرَجًا مِّمَّا قَضَيْتَ وَيُسَلِّمُوا۟ تَسْلِيمًا ﴿٦٥﴾ ﴾ سورة النساء / الآية: ٦٥

មានន័យថា: (អល់ឡោះជាម្ចាស់បានស្បថនឹងព្រះអង្គឯងថា ពួកគេពុំទាន់មានជំនឿពិតនោះទេ លុះត្រាតែពួកគេយកជម្លោះរវាងពួកគេមកអោយឯងកាត់ក្តី ពេលឯងនៅមានជីវិត ហើយសំរេចតាមលំអានរបស់ឯង ពេលឯងស្លាប់។ បន្ទាប់ពីកាត់ក្តីរួច ពួកគេគ្មានការទិតៀន ហើយពួកគេស្តាប់បង្គាប់ឯងយ៉ាងខ្ជាប់ខ្ជួន)។

ម្យ៉ាងវិញទៀត ត្រូវទុកក្បួនច្បាប់ និងសេចក្តីសម្រេចរបស់គាត់ជាអាទិភាពលើក្បួនច្បាប់ផ្សេងដទៃឯទៀត។ ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿ أَفَحُكْمَ ٱلْجَٰهِلِيَّةِ يَبْغُونَ ۚ وَمَنْ أَحْسَنُ مِنَ ٱللَّهِ حُكْمًا لِّقَوْمٍ يُوقِنُونَ ﴿٥٠﴾ ﴾ سورة المائدة / الآية: ٥٠

មានន័យថា: (តើពួកគេចង់បានច្បាប់ព្រៃយកមកប្រើប្រាស់ឬ? តើមាននរណាយុត្តិធម៌ជាងអល់ឡោះ ក្នុងការកាត់ក្តីសម្រាប់ពួកអ្នកដែលមានជំនឿជឿជាក់ចំពោះព្រះអង្គ)។

៩- គ្រាប់តាមបទដ្ឋាន(**سُنَّة**)របស់គាត់ ធ្វើតាមលំអានរបស់គាត់ ដើរតាមមាគ៌ារបស់គាត់ ហើយទុកជាគំរូសម្រាប់យកតម្រាប់តាម។ ដូចទ្រង់បានមានព្រះបន្ទូលថា:

﴿ قُلْ إِن كُنتُمْ تُحِبُّونَ ٱللَّهَ فَٱتَّبِعُونِى يُحْبِبْكُمُ ٱللَّهُ وَيَغْفِرْ لَكُمْ ذُنُوبَكُمْ ۗ وَٱللَّهُ غَفُورٌ رَّحِيمٌ ﴿٣١﴾ ﴾

سورة آل عمران / الآية: ٣١

មានន័យថា: (មូហាំម៉ាត់ ចូរប្រសាសន៍ចុះថា បើពួកអ្នកស្រលាញ់អល់ឡោះពិត ចូរប្រណិប័តន៍តាមខ្ញុំ និងជឿចំពោះខ្ញុំទាំងផ្ទៃកកំបាំង និងចំហានោះអល់ឡោះទ្រង់នឹងសព្វព្រះទ័យចំពោះពួកអ្នក ទ្រង់នឹងជម្រះបាបកម្មរបស់ពួកអ្នក។ ពិតប្រាកដណាស់ អល់ឡោះទ្រង់មហាអភ័យ មហាមេត្តា)។ ទ្រង់បានមានព្រះបន្ទូលទៀតថា:

﴿ لَّقَدْ كَانَ لَكُمْ فِى رَسُولِ ٱللَّهِ أُسْوَةٌ حَسَنَةٌ لِّمَن كَانَ يَرْجُوا۟ ٱللَّهَ وَٱلْيَوْمَ ٱلْءَاخِرَ ﴾

سورة الأحزاب / الآية: ٢١

មានន័យថា: (នៃពួកអ្នកមានជំនឿទាំងឡាយ! ពិតប្រាកដ សំរាប់ពួកអ្នកមានអ្នកនាំសារអល់ឡោះជាគំរូដ៏ល្អ ទាំងកាយ វាចា ចិត្ត ដើម្បីឱ្យពួកអ្នកយកគំរូតាម ចូរប្រកាន់អោយបានខ្ជាប់ខ្ជួន តាមលំអានរបស់គេ។ ពិតប្រាកដអ្នកដែលប្រតិបត្តិតាម មានតែពួកអ្នកដែលមានក្តីសង្ឃឹមចំពោះអល់ឡោះ និងថ្ងៃបរលោកប៉ុណ្ណោះ)។

ព្យាការីមូហាំម៉ាត់ គាត់បានមានប្រសាសន៍ថា: (ចូរប្រកាន់តាមលំអានរបស់ខ្ញុំ និងលំអានរបស់ពួកខលិហ្វដែលទទួលនូវក្តីចង្អុលបង្ហាញ ហើយខាំនឹងធ្មេញថ្គាមអោយជាប់" ប្រកាន់អោយបានខ្ជាប់ខ្ជួន"។ ចូរប្រុងប្រយ័ត្នពីការប្រឌិតថ្មី ពីព្រោះរាល់ការប្រឌិតថ្មីជាអំពើពិដអះ ហើយអំពើពិដអះទាំងឡាយសុទ្ធតែវង្វេង)។

១០- ត្រូវបួងសួង ជូនពរគាត់ នៅពេលគេរំលឹកពីឈ្មោះរបស់គាត់។ ដូចអល់ឡោះទ្រង់បានមានព្រះបន្ទូលថា:

﴿ إِنَّ ٱللَّهَ وَمَلَٰٓئِكَتَهُۥ يُصَلُّونَ عَلَى ٱلنَّبِيِّۚ يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ صَلُّواْ عَلَيۡهِ وَسَلِّمُواْ تَسۡلِيمًا ٥٦ ﴾

سورة الأحزاب / الآية : ٥٦

មានន័យថា: (ពិតប្រាកដ អល់ឡោះជាម្ចាស់ និងពួកទេវតា កំពុងជូនពរចំពោះព្យាការីមូហាំម៉ាត់។ នៃពួកអ្នកមានជំនឿទាំងឡាយ! ចូរជូនពរ និងសាឡាមស្វាគមន៍ចុះចំពោះគេ គឺព្យាការីមូហាំម៉ាត់)។

ព្យាការីមូហាំម៉ាត់គាត់បានមានប្រសាសន៍ថា: (អ្នកដែលកំណាញ់ គឺអ្នកដែលគេរំលឹកឈ្មោះខ្ញុំនៅចំពោះមុខ ហើយពុំព្រមជូនពរចំពោះខ្ញុំ)។

១១- ស្រលាញ់ និងគោរពដ៏ជ្រាលជ្រៅចំពោះគាត់ ត្រូវស្រលាញ់គាត់លើសពីអ្នកដទៃ ពីព្រោះគាត់មានគុណូបការៈបន្ទាប់ពីអល់ឡោះជាម្ចាស់ក្នុងការចង្អុលបង្ហាញមនុស្សអោយយល់ពីសាសនាដ៏ត្រឹមត្រូវ ជាផ្លូវឆ្ពោះទៅរកសុភមង្គលក្នុងលោកីយ៍ និងបរមសុខនៅបរលោក។ គាត់បានមានប្រសាសន៍ថា:

عَنْ أَنَس بْنِ مَالِكٍ رَضِيَ اللَّهُ عَنْهُ عَنْ النَّبِيِّ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ قَالَ : (ثَلَاثٌ مَنْ كُنَّ فِيهِ وَجَدَ حَلَاوَةَ الْإِيمَانِ مَنْ كَانَ اللَّهُ وَرَسُولُهُ أَحَبَّ إِلَيْهِ مِمَّا سِوَاهُمَا وَمَنْ أَحَبَّ عَبْدًا لَا يُحِبُّهُ إِلَّا لِلَّهِ عَزَّ وَجَلَّ وَمَنْ يَكْرَهُ أَنْ يَعُودَ فِي الْكُفْرِ بَعْدَ إِذْ أَنْقَذَهُ اللَّهُ مِنْهُ كَمَا يَكْرَهُ أَنْ يُلْقَى فِي النَّارِ) صحيح البخاري

មានន័យថា: (បីប្រការ នរណាមានបីប្រការនេះក្នុងខ្លួន អ្នកនោះនឹងស្គាល់រសជាតិនៃជំនឿ គឺភាពរីករាយ និងសេចក្តីសុខនៅក្នុងចិត្ត។ ទីមួយ អ្នកដែលស្រលាញ់អល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ខ្លាំងជាងស្រលាញ់អ្វីៗទាំងអស់។ ស្រលាញ់ត្រង់នេះ ពុំមែនជាការស្រលាញ់ធម្មតា តែជាការស្ម័គ្រចិត្តជ្រើសរើស ការគោរពប្រតិបត្តិចំពោះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ ជាជាងការធ្វើតាមទំនើងចិត្តខ្លួនឯង។ល។ ទីពីរ អ្នកដែលស្រលាញ់មនុស្សម្នាក់គ្មានហេតុផលអ្វី ក្រៅពី ស្រលាញ់ក្នុងនាមអល់ឡោះ បានសេចក្តីថាស្រលាញ់ដោយចិត្តជ្រះ ថ្លាក្នុងនាមអល់ឡោះ ពុំមែនតាមអំណាចចិត្ត ពេលពេញចិត្តផ្សេង ពេលទាស់ចិត្តផ្សេង។ ទីបី អ្នកដែលស្អប់មិនចង់ក្លាយជាមនុស្សគ្មាន ជំនឿ "កាហ្វៀរ" បន្ទាប់ពីអល់ឡោះទ្រង់បានសង្គ្រោះគេអោយរួចផុតពី អំពើនេះ បីដូចជាស្អប់មិនចង់អោយគេយកទៅបោះទម្លាក់ក្នុងភ្នក់ភ្លើងដែលកំពុងឆេះ គឺភ្លើងនៅលោកីយ៍យើងនេះ)។

១២-ជួយអំពាវនាវ និងផ្សព្វផ្សាយសាសនានេះដល់មនុស្សលោក ផ្តល់ដំណឹងចំពោះនរណាដែលមិនទាន់ជ្រាប និងស្តារឡើងវិញនូវ លំអាន (**سُنّة**)របស់គាត់ដោយប៉ិនប្រសប់ និងប្រើធម៌មិត្រជាក់ គឺបង្រៀនអ្នក ដែលមិនចេះ រំលឹកអ្នកភ្លេចស្មារតី ជួយគាំទ្រអ្នកដើរតាម ដោយអនុវត្ត តាមបន្ទូលរបស់អល់ឡោះជាម្ចាស់ថា:

﴿ ٱدۡعُ إِلَىٰ سَبِيلِ رَبِّكَ بِٱلۡحِكۡمَةِ وَٱلۡمَوۡعِظَةِ ٱلۡحَسَنَةِۖ وَجَٰدِلۡهُم بِٱلَّتِي هِيَ أَحۡسَنُۚ ١٢٥ ﴾

سورة النحل / الآية : ١٢٥

មានន័យថា: (នែមូហាំម៉ាត់ និងពួកអ្នកដែលដើរតាមឯង ចូរអំពាវនាវមនុស្ស មករកសាសនារបស់ព្រះជាម្ចាស់ដ៏ត្រឹមត្រូវនេះ ដោយគតិបណ្ឌិត ដែលអល់ឡោះទ្រង់បានគ្រាស់បង្គាប់ក្នុងគម្ពីរ និងលំអានរបស់ឯង ចូរប្រើសំដីណាដែលសក្តិសមនឹងពួកគេ ទូន្មានពាក្យល្អៗ និងប្រៀនប្រដៅពួកគេអោយពេញចិត្តតែអំពើល្អ ហើយជៀសវាងពីអំពើអាក្រក់ និងជជែកចុះជាមួយពួកគេ ដោយសន្តិវិធី)។

ព្យាការីមូហាំម៉ាត់គាត់បានមានប្រសាសន៍ថា:

عَنْ عَبْدِ اللَّهِ بْنِ عَمْرٍو قَالَ قَالَ رَسُولُ اللَّهِ صَلَّى اللَّهُ عَلَيْهِ وَسَلَّمَ : (بَلِّغُوا عَنِّي وَلَوْ آيَةً) رواه البخاري

មានន័យថា: (ចូរពួកអ្នកជួយផ្សព្វផ្សាយផងចុះអំពីខ្ញុំ សូម្បីតែមួយប្រយោគ)។

***

ការផ្សាយរបស់

ការិយាល័យអង្គការ វ៉ាមី ប្រចាំនៅកម្ពុជា

បោះពុម្ពលើកទី ១

صلى الله عليه وسلم

ប្រសាសន៍រ៉ស៊ូលុលឡោះ

ពិតប្រាកដ ខ្ញុំជាក្ដីមេត្តា ដែលប្រទានអំពីព្រះអល់ឡោះជាម្ចាស់

مع نبي الرحمة

من إصدارات مكتب الندوة بكمبوديا

الطبعة الأولى

2011 G - 1432 H